ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អសជ

អាជ្ញាធរសវនកម្មជាតិ

# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
# ការិយបរិច្ឆេទ២០២០

លេខៈ ១៥

ឆ្នាំ២០២២

# **អារម្ភកថា**

សេដ្ឋកិច្ចកម្ពុជានាឆ្នាំ២០២០ ត្រូវបានវាយតម្លៃថាមានកំណើនអវិជ្ជមាន -**៣,១%**។ ផ.ស.ស សម្រាប់មនុស្សម្នាក់ៗ ធ្លាក់ចុះមកត្រឹម **១ ៦៥៣** ដុល្លារអាមេរិកក្នុងឆ្នាំ២០២០ ពី **១ ៧០០** ដុល្លារអាមេរិកក្នុងឆ្នាំ២០១៩។ ទន្ទឹមនឹងនេះ អត្រាអតិផរណាមធ្យមបានកើនឡើងក្នុងអត្រា**២,៩%** ក្នុងឆ្នាំ២០២០ ពីអត្រា **១,៨%** ក្នុងឆ្នាំ២០១៩ និងអត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំស្ថិតក្នុងកម្រិត**៤ ០៨០**រៀល ក្នុងមួយដុល្លារអាមេរិក។ កំណើនសេដ្ឋកិច្ចអវិជ្ជមានក្នុងឆ្នាំ២០២០ បង្កឡើងដោយវិបត្តិនៃជំងឺកូវីដ-១៩ ដែលបានបណ្តាលឱ្យវិស័យជំរុញកំណើនសំខាន់ៗទទួលរងផលប៉ះពាល់រួមមាន៖ (១)-វិស័យកសិកម្មត្រូវបានវាយតម្លៃថានឹងមានកំណើនវិជ្ជមានក្នុងរង្វង់០,៥% (២)-វិស័យឧស្សាហកម្មមានកំណើនអវិជ្ជមានក្នុងរង្វង់ (-១,២%) និង(៣)-វិស័យសេវាកម្មត្រូវបានវាយតម្លៃថា មានកំណើនអវិជ្ជមានក្នុងរង្វង់ (-៦,២%)។ រាជរដ្ឋាភិបាលកម្ពុជាបន្តអនុវត្តនូវគោលនយោបាយសំខាន់ៗ ព្រមជាមួយនឹងគោលនយោបាយវិត្តារកម្មថវិកា រួមមាន៖ ទី១-បន្តថែរក្សាឱ្យបានដាច់ខាតនូវសន្តិសុខ ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈសម្រាប់ការរស់នៅដោយសុខក្សេមក្សាន្តរបស់ប្រជាជន ព្រមទាំងការការពារឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដី មិនឱ្យកម្លាំងណាមកបំពាន និងបំផ្លាញបានឡើយ ទី២-បន្តធានាអនុវត្តគោលនយោបាយ ដើម្បីជំរុញកំណើនការងារ សមធម៌ និងប្រសិទ្ធភាព ក្នុងគោលដៅបែងចែកផ្លែផ្កានៃកំណើនប្រកបដោយសមធម៌ដល់គ្រប់ស្រទាប់នៃប្រជាជន ទី៣-បន្តធានានូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ ដើម្បីសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចរឹងមាំប្រកបដោយបរិយាបន្ន និងចីរភាពក្នុងបរិការណ៍នៃភាពមិនច្បាស់លាស់ និងហានិភ័យជាយថាហេតុ ព្រមទាំងធានាបាននូវអត្រាអតិផរណាដែលអាចគ្រប់គ្រងបាន និងស្ថិរភាពអត្រាប្តូរប្រាក់ ទី៤-បន្តគាំទ្រដល់ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការកែទម្រង់វិស័យកងកម្លាំងប្រដាប់អាវុធ ព្រមទាំងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ទី៥-បន្តជំរុញការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា២០១៨-២០២៥ ដែលរួមមានការដាក់ឱ្យអនុវត្តសាកល្បងនូវក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ២០២០-២០២២ និងក្របខណ្ឌថវិការយៈពេលមធ្យមឆ្នាំ២០២០-២០២២ ទី៦-បន្តជំរុញការអនុវត្តយុទ្ធសាស្ត្រគៀរគរចំណូល២០១៩-២០២៣ ទី៧-ដាក់ឱ្យអនុវត្តក្របខណ្ឌចំណាយអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាពទាំងក្នុងកម្រិតវិភាជ និងទាំងកម្រិតប្រតិបត្តិការ និងបច្ចេកទេសក្នុងបរិការណ៍នៃការកើនឡើងនូវភាពមិនច្បាស់លាស់និងហានិភ័យមកលើសេដ្ឋកិច្ចកម្ពុជា ទី៨-បន្តគិតគូរលើការដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិលក្នុងកម្រិតសមស្របដោយផ្អែកទៅលើសមិទ្ធកម្ម ឬគុណាធិបតេយ្យ ដើម្បីបន្តពង្រឹងសមត្ថភាពស្ថាប័ន និងអភិបាលកិច្ចក្នុងគោលដៅធានាប្រសិទ្ធភាព ស័ក្តិសិទ្ធភាព គណនេយ្យភាព និងតម្លាភាពនៃការផ្តល់សេវាសាធារណៈ ទី៩-បន្តអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ មានជាអាទិ៍ ការថែទាំសុខភាពមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន របបថែទាំសុខភាពសម្រាប់កម្មករ និយោជិត និងរបបឧបត្ថម្ភមាតុភាពសម្រាប់កម្មការិនី ព្រមទាំងរបបសន្តិសុខផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈជាដើម ទី១០-បន្តអនុវត្តដោយម៉ត់ចត់នូវយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ២០១៩-២០២៣ ទី១១-បន្តគាំទ្រដល់ការ

អនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ២០១៦-២០២៥ និងយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥ ទី១២-ពន្លឿនការអនុវត្តឱ្យបានខ្លាំងក្លានូវវិធានការនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា២០១៥-២០២៥ តាមរយៈការគាំទ្រការអភិវឌ្ឍវិស័យឯកជន និងការបង្កើនវិនិយោគសាធារណៈលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដោយផ្តោតលើការតភ្ជាប់ក្នុងវិស័យដឹកជញ្ជូន និងវិស័យថាមពល ក៏ដូចជាការតភ្ជាប់ក្នុងវិស័យឌីជីថល ក្នុងបរិបទនៃបដិវត្តន៍ឧស្សាហកម្មទី៤ ពិសេសការបន្តកាត់បន្ថយថ្លៃអគ្គិសនី ទី១៣-បន្តជំរុញការអភិវឌ្ឍធនធានមនុស្សតាមរយៈការបន្តលើកកម្ពស់គុណភាពនៃការអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ទាំងកម្រិតទាប មធ្យម និងខ្ពស់ ដើម្បីផ្គត់ផ្គង់ពលករជំនាញប្រកបដោយផលិតភាពខ្ពស់ ស្របតាមតម្រូវការទីផ្សារ ទី១៤-បន្តលើកកម្ពស់សេវាសុខាភិបាលតាមរយៈការបង្កើនការវិនិយោគបន្ថែម ទាំងលើអគារមន្ទីរពេទ្យ សម្ភារបរិក្ខារ និងសមត្ថភាពមន្ត្រីសុខាភិបាល ទី១៥-បន្តជំរុញការអភិវឌ្ឍវិស័យកសិកម្មដោយផ្តោតលើផលិតភាព ពិពិធកម្ម ការកែច្នៃកសិផល និងពាណិជ្ជូបនីយកម្ម និងទី១៦-គាំទ្រដល់ការរៀបចំកិច្ចប្រជុំកំពូលអាស៊ីអឺរ៉ុបឱ្យទទួលបានជោគជ័យតាមការគ្រោងទុក។ ជាក់ស្តែង ចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០២០ អនុវត្តបានទាបជាងច្បាប់ហិរញ្ញវត្ថុ **១០,៤%** និងចំណូលសារពើពន្ធអនុវត្ត បានទាបជាងច្បាប់ហិរញ្ញវត្ថុ **៨,៤%** ហើយបានថយចុះ **១២,៣%** ធៀបនឹងការអនុវត្តឆ្នាំ២០១៩ ចំពោះចំណូលថវិការបស់រាជធានី ខេត្តឆ្នាំ២០២០ អនុវត្តបានទាបជាងច្បាប់ហិរញ្ញវត្ថុ ៣,៣% ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក ឆ្នាំ២០២០ អនុវត្តបានទាបជាងច្បាប់ហិរញ្ញវត្ថុ ០,៥% និងចំណូលថវិការបស់រដ្ឋបាលឃុំ សង្កាត់ អនុវត្តបានទាបជាងច្បាប់ហិរញ្ញវត្ថុ ១០,៣%។ រីឯចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២០ មានការថយចុះ ៣,០% ធៀបនឹងការអនុវត្តឆ្នាំ២០១៩ ចំពោះចំណាយថវិការាជធានី ខេត្ត អនុវត្តបានទាបជាងច្បាប់ហិរញ្ញវត្ថុ ១៥,០% ចំណាយថវិការដ្ឋបាលក្រុង ស្រុក អនុវត្តបានទាបជាងច្បាប់ហិរញ្ញវត្ថុ ៤,០% និងចំណាយថវិការបស់រដ្ឋបាលឃុំ សង្កាត់ ក៏អនុវត្តបានទាបជាងច្បាប់ហិរញ្ញវត្ថុ ៣០,៩% ដែរ។ ការគ្រប់គ្រងថវិកាឆ្នាំ២០២០ គោរពបានទាំងកាលវសាន ទាំងខ្លឹមសារនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ព្រមទាំងបានបង្ហាញឱ្យឃើញថា ក្នុងបរិការណ៍ដែលសេដ្ឋកិច្ចសកល និងស្ថានភាពម៉ាក្រូសេដ្ឋកិច្ច កំពុងវិវត្តឆាប់រហ័ស និងចល័តយ៉ាងលឿនពិបាកប៉ាន់ប្រមាណឱ្យបានច្បាស់លាស់ដោយសារផលប៉ះពាល់ធ្ងន់ធ្ងរនៃការរីករាលដាលនៃជំងឺកូវីដ-១៩។ រាជរដ្ឋាភិបាលបានធ្វើការវាយតម្លៃឡើងវិញលើផលប៉ះពាល់នៃការរីករាលដាលនៃជំងឺកូវីដ-១៩ មកលើក្របខណ្ឌច្បាប់ថវិកាជាតិឆ្នាំ២០២០ និងបានសម្រេចបង្វែរទិសនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈពី "**ថវិកាវិក្លារកម្ម**" ដើម្បីលើកកម្ពស់កំណើនទៅជា "ថវិការឹតបន្តឹងសំដៅបង្កើនប្រសិទ្ធភាពចំណាយ" ដើម្បីឆ្ពោះទៅដោះស្រាយការងារអាទិភាពចំពោះមុខតាមរយៈការធ្វើវិចារណកម្មក្នុងគោលបំណងបម្រើឱ្យការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ រក្សាលំនឹងសេដ្ឋកិច្ច និងទ្រទ្រង់ការងារកែទម្រង់របស់រាជរដ្ឋាភិបាល ក៏ដូចជាបម្រើឱ្យការត្រៀមខ្លួន និងការពង្រឹងសមត្ថភាពផ្ទៃក្នុងឱ្យបានល្អសម្រាប់ត្រៀមទប់ទល់នឹងបញ្ហាប្រឈម និងហានិភ័យទាំងក្នុង និងក្រៅប្រទេស ពិសេសដើម្បីគោលដៅនៃការអនុវត្តឱ្យចេញជាលទ្ធផលជាក់ស្តែងប្រកបដោយប្រសិទ្ធភាពនូវ**កម្មវិធីនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣** របស់រាជរដ្ឋាភិបាល សំដៅឈានទៅសម្រេចបាននូវបំណងប្រាថ្នារយៈពេលវែងរបស់ប្រជាជនកម្ពុជា ក្នុងការក្តាប់យកមកវិញនូវមោទនភាពជាតិ និងការកសាងជាតិមួយដ៏រស់រវើក មានអនាគតដ៏រុងរឿងភ្លឺស្វាងត្រចះ

ត្រចង់ និងជារដ្ឋអធិបតេយ្យមួយរឹងមាំ ដែលគោរពខ្ជាប់ខ្ជួនតាមគោលការណ៍ប្រជាធិបតេយ្យ និងនីតិរដ្ឋ និងមានសន្តិភាពពេញលេញ ព្រមទាំងមានកិត្យានុភាពខ្ពស់ត្រដែតលើឆាកអន្តរជាតិ។ ទោះបីជារាជរដ្ឋាភិបាលបានជួបនូវការលំបាកខាងលើដែលពុំធ្លាប់ជួបប្រទះពីមុនៗមកក៏ដោយ ក៏រាជរដ្ឋាភិបាលនៅតែអាចគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានល្អ ទាំងការគ្រប់គ្រងចំណូល ការគ្រប់គ្រងចំណាយថវិកា ការគ្រប់គ្រងបំណុល និងការធ្វើកិច្ចបញ្ជិកាគណនេយ្យ។

សមិទ្ធផលទាំងនេះ បានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តយ៉ាងមោះមុតជាងពេលណាៗទាំងអស់ក្នុងការសម្រេចឱ្យបាននូវគោលដៅ និងវិធានការទាំងឡាយ ក្នុងការបន្តរក្សាសុខសន្តិភាព ស្ថិរភាព ឯករាជ្យជាតិ និងអធិបតេយ្យភាព ដែលជាបំណងប្រាថ្នារួមរបស់ប្រជាជនកម្ពុជាទាំងមូល ដើម្បីបន្តកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំ ក្នុងគោលដៅពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកម្ពុជា។ ទន្ទឹមគ្នានេះដែរ ថវិកាឆ្នាំ២០២០ គឺពិតជាដើរតួនាទីជាឧបករណ៍នៃគោលនយោបាយរបស់រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ក្នុងការរក្សា ការពារ និងពង្រឹងថែមទៀតនូវសមិទ្ធផលដ៏ធំធេងដែលកម្ពុជាសម្រេចបានកន្លងមក ក៏ដូចជាក្នុងការបន្តបុកគ្រឹះសម្រាប់បម្រើឱ្យការអភិវឌ្ឍរបស់កម្ពុជាតទៅមុខទៀត។

សរុបមក ថវិកាឆ្នាំ២០២០ ពិតជាឧបករណ៍គោលនយោបាយដ៏មានប្រសិទ្ធភាព ដែលអាចជួយដល់រាជរដ្ឋាភិបាល ឱ្យអាចសម្រេចបាននូវគោលដៅជាយុទ្ធសាស្ត្ររបស់ជាតិ ពិសេសគឺអាចឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះរាល់បញ្ហាប្រឈម និងហានិភ័យនានា ហើយពិតជាសម្រេចបានតាមការប្រសិទ្ធនាមថា ជា **"ថវិកាយុទ្ធសាស្ត្រនៃការផ្តួបកម្លាំងសរុប ដើម្បីទប់ទល់នឹងបញ្ហាប្រឈម និងហានិភ័យ ទាំងក្នុង និងក្រៅប្រទេសតាមរយៈការពង្រឹងសមត្ថភាពផ្ទៃក្នុង ដោយជំរុញឱ្យបានខ្លាំងក្លានូវការកែទម្រង់ស៊ីជម្រៅ និងមុតស្រួច ដើម្បីធានាសុខសន្តិភាព ស្ថិរភាព និងចីរភាពនៃកំណើនសេដ្ឋកិច្ច សំដៅលើកកម្ពស់សុខមាលភាពជូនប្រជាជន លើមាគ៌ាឆ្ពោះទៅរកចក្ខុវិស័យឆ្នាំ២០៣០ និងឆ្នាំ២០៥០"**។

អាជ្ញាធរសវនកម្មជាតិ ជាស្ថាប័នសវនកម្មកំពូលមួយ ដែលត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងខែមីនា ឆ្នាំ២០០០ ក្រោមឆន្ទៈ និងការប្តេជ្ញាដ៏មោះមុតរបស់រាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ក្នុងគោលបំណងបំពេញមុខងារត្រួតពិនិត្យ វាយតម្លៃ និងផ្តល់អនុសាសន៍កែលម្អរាល់ចំណុចខ្វះខាតរបស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន អង្គភាពពាក់ព័ន្ធនានា រួចធ្វើរបាយការណ៍ស្តីពីលទ្ធផលសវនកម្មផ្ញើជូនរដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាល សំដៅចូលរួមចំណែកពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចប្រតិបត្តិការការងារឱ្យកាន់តែល្អប្រសើរ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

អាជ្ញាធរសវនកម្មជាតិ ផ្សព្វផ្សាយរបាយការណ៍សវនកម្មនេះជាសាធារណៈដោយអនុលោមតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា។ របាយការណ៍នេះលើកឡើងនូវលទ្ធផលនៃការធ្វើសវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុលោមតាមបទប្បញ្ញត្តិ និងកិច្ចប្រតិបត្តិការការងារក្នុងការិយបរិច្ឆេទ២០២០ របស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានាមួយចំនួន។

ការខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់ ការតស៊ូ អត់ធ្មត់ ពុះពារឆ្លងកាត់ការលំបាករបស់ថ្នាក់ដឹកនាំ និងមន្ត្រីសវនកម្មនៃអាជ្ញាធរសវនកម្មជាតិ ព្រមទាំងមានការជួយឧបត្ថម្ភគាំទ្រពីគ្រប់

មជ្ឈដ្ឋានទាំងផ្នែកស្មារតី និងសម្ភារ បាននាំឱ្យអាជ្ញាធរសវនកម្មជាតិមានសក្តានុពលក្នុងការអនុវត្តការងារ និងសម្រេចបានជាបន្តបន្ទាប់នូវផែនការយុទ្ធសាស្ត្ររបស់ខ្លួន។ ចំពោះមុខ អាជ្ញាធរសវនកម្មជាតិនឹងបន្តខិតខំបន្ថែមទៀត ដោយធ្វើការពង្រីកវិសាលភាពសវនកម្ម ពង្រឹងសមត្ថភាពមន្ត្រី និងបង្កើនគុណភាពសវនកម្ម ដើម្បីឈានទៅសម្រេចភារកិច្ចតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា និងគោលការណ៍សវនកម្មទូទៅ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការស្ថានភាពសេដ្ឋកិច្ច និងគោលនយោបាយរបស់ប្រទេសជាតិផងដែរ ព្រមទាំងចូលរួមយ៉ាងសកម្មនូវកំណែទម្រង់មុតស្រួចស៊ីជម្រៅលើគ្រប់វិស័យរបស់រាជរដ្ឋាភិបាល ពិសេសកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ក្នុងនាមអាជ្ញាធរសវនកម្មជាតិ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ដែលជានិច្ចកាលតែងតែគាំទ្រអាជ្ញាធរសវនកម្មជាតិ ទាំងស្មារតី និងសម្ភារ។ សូមគោរពថ្លែងអរគុណជាពិសេសចំពោះ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលជានិច្ចកាលជួយគាំទ្រដល់អាជ្ញាធរសវនកម្មជាតិជាអនេកប្បការ ព្រមទាំងផ្តល់អនុសាសន៍ដ៏មានតម្លៃឥតគណនាសម្រាប់ធ្វើជាត្រីវិស័យដល់អាជ្ញាធរសវនកម្មជាតិគ្រប់ពេលវេលាគ្រប់កាលៈទេសៈ។ ម្យ៉ាងវិញទៀត ខ្ញុំក៏សូមអរគុណ និងកោតសរសើរចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់នៃអាជ្ញាធរសវនកម្មជាតិ ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ធ្វើឱ្យសម្រេចបាននូវជោគជ័យ គួរឱ្យកត់សម្គាល់។ ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំក៏សូមថ្លែងអំណរគុណដល់អង្គភាពរងសវនកម្មនានា និងសាធារណៈជនទាំងឡាយដែលបានសហការ គាំទ្រ និងលើកទឹកចិត្តចំពោះរាល់ការងារបម្រើឱ្យវិស័យសវនកម្មសាធារណៈនាពេលកន្លងមក។ ជាមួយគ្នានេះដែរ ខ្ញុំក៏សូមអរគុណផងដែរដល់ដៃគូអភិវឌ្ឍន៍ និងស្ថាប័នសវនកម្មកំពូលនានា ដែលបានផ្តល់ការគាំទ្រ និងឧបត្ថម្ភផ្សេងៗក្នុងកិច្ចដំណើរការអភិវឌ្ឍស្ថាប័ន។

អាជ្ញាធរសវនកម្មជាតិមានសង្ឃឹមយ៉ាងមុតមាំថា អាជ្ញាធរសវនកម្មជាតិនឹងសម្រេចនូវលទ្ធផលថ្មីៗថែមទៀតដែលបង្ហាញពីការចូលរួមចំណែកក្នុងការលើកស្ទួយ និងការអភិវឌ្ឍប្រទេសជាតិជាទីគោរព និងស្រលាញ់នៃយើងទាំងអស់គ្នា។

ថ្ងៃ ពុធ ៧កើត ខែ ផល្គុន ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ២០២២

**អគ្គសវនករ**

**សោម គីមសួគ៌**

# មាតិកា

ទំព័រ

**សេចក្តីសង្ខេប** ................................................................ ១
**១. សេចក្តីផ្តើម** ................................................................ ៥
១.១.លក្ខណៈទូទៅ ................................................................ ៥
១.២.ការអនុវត្ត និងដែនកំណត់សវនកម្ម ................................................................ ៥
១.៣.គោលបំណងនៃការផ្សព្វផ្សាយ ................................................................ ៥
**២. ការគ្រប់គ្រងថវិកា** ................................................................ ៦
២.១.មូលដ្ឋានគតិយុត្តនៃការអនុវត្តថវិកា ................................................................ ៦
២.២.កិច្ចប្រតិបត្តិការថវិកា ................................................................ ៦
**៣. លទ្ធផលសវនកម្ម** ................................................................ ១១
**៣.១.ការគ្រប់គ្រងថវិកាថ្នាក់ជាតិ** ................................................................ ១១
៣.១.១.ការធ្វើសវនកម្មសម្រាប់កម្មវិធីសវនកម្មឆ្នាំ២០២០ ................................................................ ១១
៣.១.២.ការកត់ត្រាប្រាក់ពន្ធតែមប្រើសារពើពន្ធ ................................................................ ១១
៣.១.៣.ចំណូលផ្សេងៗ និងបង្វែររង់ចាំដំណោះស្រាយ ................................................................ ១២
៣.១.៤. ការកំណត់តម្លៃគិតពន្ធទំនិញល្មើសនៅទាបជាងតម្លៃចម្លងការ ................................................................ ១៣
៣.១.៥.កង្វះខាតការតាមដាន និងផ្ទៀងផ្ទាត់ចំណូល ................................................................ ១៤
៣.១.៦.ការបង់ចំណូលចូលថវិកាជាតិឆ្លងឆ្នាំ ................................................................ ១៤
៣.១.៧. ក្រុមហ៊ុនចូលរួមដេញថ្លៃមានសកម្មភាពអាជីវកម្មមិនស្របទៅនឹងកម្មវត្ថុនៃការដេញថ្លៃ ................................................................ ១៥
៣.១.៨.ការអនុវត្តចំណាយរដ្ឋទេយ្យបុរេប្រទានកម្មវិធីមិនទាន់បានត្រឹមត្រូវតាមគោលការណ៍ចំណាយ ................................................................ ១៦
៣.១.៩.ការកត់ត្រាគណនីចំណាយថវិកាបុរេប្រទានមិនទាន់មានលក្ខណៈសមស្រប ................................................................ ១៧
៣.១.១០.ការអនុវត្តគម្រោងកិច្ចលទ្ធកម្មលើសផែនការលទ្ធកម្មប្រចាំឆ្នាំ ................................................................ ១៨
៣.១.១១.ការបំបែកបណ្ណចំណាយដើម្បីគេចវេសនីតិវិធីលទ្ធកម្ម ................................................................ ១៨
៣.១.១២.ពេលវេលានៃការអនុវត្តកិច្ចលទ្ធកម្មពុំស្របតាមផែនការលទ្ធកម្មប្រចាំឆ្នាំ ................................................................ ១៩
៣.១.១៣.ការអនុវត្តប្រកាសអន្តរក្រសួងលេខ ២៦១ ស.អ.យ មិនទាន់បានពេញលេញ ................................................................ ២០
៣.១.១៤.កង្វះខាតយន្តការក្នុងការតាមដានគណនីអតីតយុទ្ធជន ................................................................ ២០
៣.១.១៥.ការពុំបានទុករយៈពេលគ្រប់១០ថ្ងៃសម្រាប់ជំទាស់តវ៉ាក្រោយចេញលិខិតសម្រេចប្រគល់កិច្ចសន្យា ................................................................ ២១
៣.១.១៦.កង្វះវិធានការចំពោះសំណង់ដែលបានសាងសង់ដោយពុំបានស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសាងសង់ ................................................................ ២២

៣.១.១៧.កង្វះខាតក្នុងការប្រកាសក្រមសីលធម៌សម្រាប់ការអនុវត្តវិធីសាស្ត្រ
លទ្ធកម្មដោយឡែក ........................................................ ២៣
៣.១.១៨.កង្វះខាតក្នុងការរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តការងារ
ការអនុវត្តគម្រោងលទ្ធកម្មតបណ្តាញអគ្គិសនី និងប្រព័ន្ធទឹក........................ ២៣
៣.១.១៩.ការចំណាយរដ្ឋទេយ្យបុរេប្រទានពុំទាន់សមស្រប ................................ ២៤
**៣.២.ការគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ**........................................ ២៥
៣.២.១. ការកត់ត្រាប្រាក់ពន្ធតែមប្រើសារពើពន្ធពុំទាន់សមស្រប................................ ២៥
៣.២.២.ការផ្តល់សេវាចំពោះឯកសារស្នើសុំបង់ពន្ធប្រថាប់ត្រារបស់អ្នកជាប់ពន្ធ
មួយចំនួន........................................................................ ២៥
៣.២.៣.ការប្រមូលពន្ធដីធ្លីមិនបានប្រើប្រាស់............................................ ២៦
៣.២.៤.ការប្រមូលចំណូលពីសោហ៊ុយសេវាសំណង់ពុំទាន់អស់លទ្ធភាព ........................ ២៦
៣.២.៥.ការគ្រប់គ្រងស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈនៅមានកម្រិត............................ ២៨
៣.២.៦.ការបំបែកគម្រោងចំណាយដើម្បីតម្រូវតាមសិទ្ធិសម្រេច ................................ ២៩
៣.២.៧.ការពុំបានប្រមូលម្ហូបប្រភេទទំនិញបញ្ចូលក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំ............. ៣០
៣.២.៨. ការផ្តល់ទម្រង់ពាក្យស្នើសុំសេវារដ្ឋបាលជូនប្រជាពលរដ្ឋ ............................ ៣០
៣.២.៩.កិច្ចលទ្ធកម្មសាធារណៈមួយចំនួនពុំមានអនុលោមភាពពីក្រសួងមហាផ្ទៃ ......... ៣១
៣.២.១០.ភាពយឺតយ៉ាវក្នុងធ្វើប្លង់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ................................ ៣២
**៤.ការពិនិត្យទៅលើវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍សវនកម្ម** ........................ ៣៤
៤.១.ភាពយឺតយ៉ាវក្នុងការព្យួរទុកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម ............................ ៣៤
៤.២.ក្រុមហ៊ុនសហគ្រាសមួយចំនួនមិនបានមកធ្វើបច្ចុប្បន្នភាព.................................... ៣៤
៤.៣.ការផ្ទេរក្រុមហ៊ុនសហគ្រាសពីអ្នកជាប់ពន្ធតូចទៅអ្នកជាប់ពន្ធមធ្យម.................... ៣៥
៤.៤.ការប្រមូលពន្ធប៉ាតង់ពុំទាន់បានពេញលេញ .................................................. ៣៦
៤.៥.ការប្រមូលព័ត៌មានសហគ្រាសមួយចំនួនដែលបានចុះបញ្ជីតាមក្រសួង ស្ថាប័ន....... ៣៦
៤.៦.ការកាន់កាប់កិច្ចបញ្ជិកាគណនេយ្យរបស់អ្នកជាប់ពន្ធ........................................ ៣៦
៤.៧.ក្រុមហ៊ុនសហគ្រាសមួយចំនួនពុំទាន់បានបំពេញកាតព្វកិច្ចសារពើពន្ធ ............... ៣៧
៤.៨.របាយការណ៍សវនកម្មរបស់សវនករឯករាជ្យ ................................................. ៣៨
៤.៩.ការប្រើប្រាស់វិក្កយបត្រ ................................................................. ៤១
៤.១០.ការត្រួតពិនិត្យលើលិខិតប្រកាសពន្ធ .................................................... ៤២
៤.១១.ការប្រមូលពន្ធអចលនទ្រព្យ .............................................................. ៤៣
៤.១២.ការទូទាត់ប្រាក់កក់ដែលបាននាំចូលដោយជំពាក់បែបបទយឺតយ៉ាវ.................. ៤៣
៤.១៣.ការយឺតយ៉ាវក្នុងការដោះស្រាយកំណត់ហេតុល្មើសច្បាប់គយ ........................ ៤៤
៤.១៤.ការទូទាត់ និងការកត់ត្រាចំណាយ....................................................... ៤៥

៤.១៥.ការត្រួតពិនិត្យភាពត្រឹមត្រូវនៃអាណត្តិបើកប្រាក់ ........ ៤៦
៤.១៦.ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ........ ៤៧
៤.១៧.ការធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ ........ ៤៨
**៥.សេចក្ដីសន្និដ្ឋាន** ........ ៤៩

# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់ការិយបរិច្ឆេទ២០២០

## សេចក្តីសង្ខេប

អាជ្ញាធរសវនកម្មជាតិជាស្ថាប័នសាធារណៈដែលឯករាជ្យអំពីកិច្ចប្រតិបត្តិការនៃការងារ និងមានភារកិច្ចចំពោះការអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល។ ស្ថាប័ននេះត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០។ អនុលោមតាមមាត្រា២ មាត្រា៣ មាត្រា២៩ និងមាត្រា៣៧នៃច្បាប់នេះ អាជ្ញាធរសវនកម្មជាតិមានកាតព្វកិច្ចធ្វើសវនកម្ម និងផ្សព្វផ្សាយលទ្ធផលសវនកម្មដែលចាំបាច់។

សម្រាប់ការិយបរិច្ឆេទ២០២០ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្មលើបណ្តាក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ គម្រោងផ្សេងៗ និងសម្បទានវិនិយោគមួយចំនួនដែលមានលទ្ធផលសង្ខេបខាងក្រោម៖

### ក. កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

ចំណូលថវិកាថ្នាក់ជាតិអនុវត្តបានចំនួន **២៨ ៥០០ ៣៧២,៥**លានរៀល ស្មើនឹង **២៦,១៣%** នៃផ.ស.ស គឺទាបជាងច្បាប់ហិរញ្ញវត្ថុ **៦,២%** ហើយថយចុះ **៨,២%** ធៀបនឹងការអនុវត្តឆ្នាំ២០១៩។ ចំណូលថវិកានេះគឺជាលទ្ធផលនៃកិច្ចប្រឹងប្រែងយូរឆ្នាំរបស់រាជរដ្ឋាភិបាលលើការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការរួមចំណែកពីសកម្មភាពសវនកម្ម និងអធិការកិច្ចហិរញ្ញវត្ថុដោយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។ ការអនុវត្តចំណូលគយ និងរដ្ឋាករសម្រេចបានលទ្ធផលល្អប្រសើរតាមរយៈយុទ្ធសាស្ត្រគៀរគរចំណូល២០១៩-២០២៣ យុទ្ធសាស្ត្រកំណែទម្រង់ និងទំនើបកម្មគយ២០១៩-២០២៣ និងផែនការយុទ្ធសាស្ត្រផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល ដូចជា ការពង្រឹងប្រសិទ្ធភាពការងារបច្ចេកទេស និងការអនុវត្តនីតិវិធីគយ ការពង្រឹងអនុលោមភាព និងប្រសិទ្ធភាពការងារបង្ការ និងបង្ក្រាបអំពើរត់គេចពន្ធ ការពង្រឹងយន្តការគ្រប់គ្រងហានិភ័យនិងសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ ការពង្រឹងវប្បធម៌អនុលោមភាពរបស់វិស័យឯកជន ការពង្រីកការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ការអភិវឌ្ឍនិងការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ និងការពង្រឹងអភិបាលកិច្ចអង្គភាពគយ និងការអភិវឌ្ឍស្ថាប័ន។

ការប្រមូលចំណូលពន្ធអាករបានលទ្ធផលដ៏ល្អប្រសើរនេះអាចសម្រេចទៅបាន ដោយសារៈ (១)-ភាពរឹងមាំនៃកំណើនសេដ្ឋកិច្ចដែលជំរុញឱ្យមានសកម្មភាពអាជីវកម្មសំខាន់ៗជាច្រើនរីកចម្រើនយ៉ាងឆាប់រហ័ស (២)-តាមរយៈការដាក់ចេញនូវវិធានការគន្លឹះនានាប្រកបដោយប្រសិទ្ធភាពខ្ពស់ និងការបន្តលើកកម្ពស់អនុលោមភាពអ្នកជាប់ពន្ធដោយការធ្វើទំនើបកម្ម និងសាមញ្ញកម្មសេវាអ្នកជាប់ពន្ធ (៣)-ការបន្តកែសម្រួលគោលនយោបាយសារពើពន្ធ និងវិធានការរដ្ឋបាលសំដៅធ្វើឱ្យប្រសើរឡើងនូវបរិយាកាសសង្គមសេដ្ឋកិច្ច ធុរកិច្ច និងការទាក់ទាញវិនិយោគទុនពីបរទេស។

ដោយឡែក ចំណូលមិនមែនសារពើពន្ធមានកំណើនខ្ពស់ បានមកពីចំណូលម្តងម្កាលមួយចំនួន ដូចជា៖ ការបង់ភាគលាភពីសហគ្រាសសាធារណៈ និងការបង់ចំណូលពាក់ព័ន្ធនឹងវិស័យកាស៊ីណូ ដែលរួមមានទាំងការបង់កាតព្វកិច្ចកាស៊ីណូ ការសងបំណុល និងការទិញសិទ្ធិផ្តាច់មុខ ដែលបានប៉ះប៉ូវដល់ការធ្លាក់ចុះនៃប្រភពចំណូលសំខាន់ៗ រួមមានចំណូលពីផលទុននៃសកម្មភាពទេសចរណ៍ជាដើម។ លើសពីនេះ ក្នុងន័យចូលរួមជំរុញដល់កំណើនចំណូលមិនមែនសារពើពន្ធ រដ្ឋបាលចំណូលមិនមែនសារពើពន្ធបានពង្រឹងប្រសិទ្ធភាពអភិបាលកិច្ចតាមរយៈការអនុវត្តវិធានការគន្លឹះដូចជា៖ (១)-ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) (២)-ការជំរុញការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងអនុវត្តការបង់ប្រាក់តាមប្រព័ន្ធធនាគារ និង(៣)-ការជំរុញការអនុវត្តប្រកាសរួមស្តីពីការផ្តល់សេវាសាធារណៈ និងលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈជារួម។

តាមលទ្ធផលនៃការធ្វើសវនកម្មបានបង្ហាញឱ្យឃើញថា នៅមានការកត់សម្គាល់មួយចំនួនដែលចាំបាច់ត្រូវធ្វើឱ្យប្រសើរឡើងថែមទៀត មានជាអាទិ៍៖ ការធ្វើសវនកម្មសម្រាប់កម្មវិធីសវនកម្មឆ្នាំ២០២០ ការកត់ត្រាប្រាក់ពន្ធតែមប្រ៍សារពើពន្ធ ចំណូលផ្សេងៗ និងបង្វែររង់ចាំដំណោះស្រាយ ការប្រកាសតម្លៃគិតពន្ធលើទំនិញស្រានាំចូលខុសយថាប្រភេទ ការកំណត់តម្លៃគិតពន្ធទំនិញល្មើសនៅទាបជាងតម្លៃចម្លងការ កង្វះខាតការតាមដាននិងផ្ទៀងផ្ទាត់ចំណូល ការបង់ចំណូលចូលថវិកាជាតិឆ្លងឆ្នាំភាពយឺតយ៉ាវក្នុងការព្យួរទុកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម ក្រុមហ៊ុនសហគ្រាសមួយចំនួនមិនបានមកធ្វើបច្ចុប្បន្នភាព ការផ្ទេរក្រុមហ៊ុនសហគ្រាសពីអ្នកជាប់ពន្ធតូចទៅអ្នកជាប់ពន្ធមធ្យម ការប្រមូលពន្ធប៉ាតង់ពុំទាន់បានពេញលេញ ការប្រមូលព័ត៌មានសហគ្រាសមួយចំនួនដែលបានចុះបញ្ជីតាមក្រសួង ស្ថាប័នការកាន់កាប់កិច្ចបញ្ជិកាគណនេយ្យរបស់អ្នកជាប់ពន្ធ ក្រុមហ៊ុនសហគ្រាសមួយចំនួនពុំទាន់បានបំពេញកាតព្វកិច្ចសារពើពន្ធ របាយការណ៍សវនកម្មរបស់សវនករឯករាជ្យ ការប្រើប្រាស់វិក្កយបត្រ ការត្រួតពិនិត្យលើលិខិតប្រកាសពន្ធ ការប្រមូលពន្ធអចលនទ្រព្យ ការទូទាត់ប្រាក់កក់ដែលបាននាំចូលដោយជំពាក់បែបបទយឺតយ៉ាវ និងការយឺតយ៉ាវក្នុងការដោះស្រាយកំណត់ហេតុល្មើសច្បាប់គយ។

ចំណាយថវិកាថ្នាក់ជាតិអនុវត្តបានចំនួន**២៩ ៥០២ ៧៤៦,៥** លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុ**៧,៣%** ហើយស្មើនឹង**២៧,០៥%** នៃផ.ស.ស គឺមានការកើនឡើង**៨,០%** ធៀបនឹងការអនុវត្តឆ្នាំ២០១៩។ ចំណាយថវិកានេះ បានបន្តធានាដល់ការអនុវត្តគោលនយោបាយគាំពារសង្គម បន្តការអនុវត្តកម្មវិធីកែទម្រង់នានា ពង្រីកវិសាលភាពនៃការផ្តល់សេវាសាធារណៈ និងវិនិយោគលើធនធានមនុស្សព្រមជាមួយនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ក្នុងន័យជំរុញពិពិធកម្មសេដ្ឋកិច្ច និងលើកកម្ពស់ភាពប្រកួតប្រជែង។ ក្នុងឆ្នាំ២០២០ មានការធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសំដៅបម្រើដល់កិច្ចការជាអាទិភាព រួមមាន ការផ្តល់ឥណទានដល់ធនាគារអភិវឌ្ឍន៍ជនបទ ដើម្បីទូទាត់ចំណាយបំពេញតម្រូវការឥណទានរបស់រោងម៉ាស៊ីនកិនស្រូវក្នុងការប្រមូលទិញស្រូវពីប្រជាកសិករ និងដើម្បីបំពេញលក្ខខណ្ឌតម្រូវក្នុងការស្នើសុំអាជ្ញាបណ្ណជាធនាគារពាណិជ្ជ ប្រតិបត្តិការបន្ថែមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការទូទាត់ចំណាយវិនិយោគលើការសាងសង់រោងចក្រផលិតអគ្គិសនី។

ចំពោះចំណាយចរន្តផ្តោតលើការដំឡើងបៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ សំដៅលើកកម្ពស់ជីវភាពមន្ត្រីសាធារណៈ និងការអនុវត្តកម្មវិធីនានាក្នុងគោលនយោបាយគាំពារសង្គម ដែលរួមមានកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ កម្មវិធីមូលនិធិសមធម៌ផ្តល់សេវាព្យាបាលដោយឥតគិតថ្លៃ និងការឧបត្ថម្ភមាតុភាពដល់កម្មករនិយោជិត។ ដោយឡែកចំណាយមូលធនផ្តោតលើការវិនិយោគ បានចូលរួមចំណែកក្នុងការអភិវឌ្ឍគម្រោងវិនិយោគ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលមានគុណភាពខ្ពស់ និងទំហំធំនៅក្នុងវិស័យអាទិភាព ជាពិសេសផ្តោតលើការតភ្ជាប់ក្នុងវិស័យដឹកជញ្ជូន ថាមពល និងឌីជីថល។

ជារួម ការអនុវត្តចំណាយក្នុងឆ្នាំ២០២០ ត្រូវបានវាយតម្លៃថាកាន់តែមានប្រសិទ្ធភាពខ្ពស់ តាមរយៈការបន្តបោះជំហានយ៉ាងមុតមាំក្នុងកិច្ចការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីបន្តពង្រឹងប្រសិទ្ធភាពគ្រប់គ្រង និងបែងចែកធនធានហិរញ្ញវត្ថុសាធារណៈ និងតម្រង់ខ្លួនឆ្ពោះទៅសម្រេចបាននូវប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម។ ការអនុវត្តគោលនយោបាយចំណាយថវិកាឆ្នាំ២០២០ សម្រេចបានលទ្ធផលល្អ ធៀបនឹងច្បាប់ហិរញ្ញវត្ថុ ដោយបានបំពេញតួនាទីជាឧបករណ៍ដ៏មានប្រសិទ្ធភាព ក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលតាមការគ្រោងទុក និងដោះស្រាយបាននូវអាទិភាព គោលនយោបាយថ្មីៗ ឆ្លើយតបទៅនឹងសភាពការណ៍បន្ទាន់ និងគាំទ្រដល់ការកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ដូចជា៖ ការសម្រេចបានការអនុវត្តគោលនយោបាយដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ការបង្កើននូវប្រសិទ្ធភាពចំណាយតាមរយៈវិធានការបង្កើនប្រសិទ្ធភាពក្នុងការវិភាជ និងក្នុងការពិនិត្យផ្តល់ធានាចំណាយ ដោយធានាបាននូវចំណាយចំមុខសញ្ញាមានភាពចាំបាច់ តម្លៃសមរម្យ បរិមាណត្រឹមត្រូវ គុណភាពសមរម្យ និងទាន់ពេលវេលា ក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈក្នុងឆ្នាំ២០២០ រាជរដ្ឋាភិបាលសន្សំសំចៃថវិកាបានមួយចំនួន យន្តការផ្ទេរមុខងារពីក្រសួង ស្ថាប័ន ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិបាននឹងកំពុងដំណើរការអនុវត្ត ឱនភាពទូទៅនៃថវិកា ត្រូវបានកាត់បន្ថយឱ្យមកស្ថិតនៅក្នុងកម្រិតដែលបានរួមចំណែកយ៉ាងចម្បងក្នុងការធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចក្នុងរយៈពេលមធ្យម និងរយៈពេលវែងដែលឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការបន្តអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវការគ្រប់គ្រងបំណុលសាធារណៈស្របតាមយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈឆ្នាំ២០១៩-២០២៣ របស់រាជរដ្ឋាភិបាល ជាពិសេសតាមគោលការណ៍គន្លឹះទាំង៥ គោលនយោបាយក្នុងការពង្រីក និងការលើកកម្ពស់ការអភិវឌ្ឍនៅរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ តាមរយៈការចែករំលែកចំណូលថវិកាដែលមានប្រភពពីចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្ត ជូនរដ្ឋបាលក្រុង ស្រុកចំនួន៣% និងរដ្ឋបាលឃុំ សង្កាត់ចំនួន១% សម្រាប់ការអភិវឌ្ឍមូលដ្ឋាន។

ទោះបីជាការអនុវត្តចំណាយថវិកានេះបានល្អប្រសើរក៏ដោយ ក៏នៅមានចំណុចគួរឱ្យកត់សម្គាល់មួយចំនួន ដូចជា៖ ការប្រគល់ទទួលបញ្ចូលទំនិញតាមកិច្ចលទ្ធកម្មសាធារណៈមិនទាន់មានលក្ខណៈសមស្រប ក្រុមហ៊ុនចូលរួមដេញថ្លៃមានសកម្មភាពអាជីវកម្មមិនស្របទៅនឹងកម្មវត្ថុនៃការដេញថ្លៃ ការអនុវត្តចំណាយរជ្ជទេយ្យបុរេប្រទានកម្មវិធីមិនទាន់បានត្រឹមត្រូវតាមគោលការណ៍ចំណាយ

ការទូទាត់ចំណាយបុរេប្រទានពុំទាន់បានសមស្រប ការកត់ត្រាគណនីចំណាយថវិកាបុរេប្រទានមិនទាន់មានលក្ខណៈសមស្រប ការអនុវត្តគម្រោងកិច្ចលទ្ធកម្មលើសផែនការលទ្ធកម្មប្រចាំឆ្នាំ ការបំបែកបណ្ដុំចំណាយដើម្បីគេចវេសនីតិវិធីលទ្ធកម្ម ពេលវេលានៃការអនុវត្តកិច្ចលទ្ធកម្មពុំស្របតាមផែនការលទ្ធកម្មប្រចាំឆ្នាំ ការអនុវត្តប្រកាសអន្តរក្រសួងលេខ២៦១ ស.អ.យ មិនទាន់បានពេញលេញ កង្វះខាតយន្តការក្នុងការតាមដានគណនីអតីតយុទ្ធជន ការពុំបានទុករយៈពេលគ្រប់១០ថ្ងៃ សម្រាប់ជំទាស់តវ៉ាក្រោយចេញលិខិតសម្រេចប្រគល់កិច្ចសន្យា កង្វះវិធានការចំពោះសំណង់ដែលបានសាងសង់ដោយពុំបានស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសាងសង់ កង្វះខាតក្នុងការប្រកាសក្រមសីលធម៌សម្រាប់ការអនុវត្តវិធីសាស្ត្រលទ្ធកម្មដោយឡែក កង្វះខាតក្នុងការរៀបចំរបាយការណ៍ស្ដីពីវឌ្ឍនភាពនៃការអនុវត្តការងារការអនុវត្តគម្រោងលទ្ធកម្មតបណ្ដាញអគ្គិសនី និងប្រព័ន្ធទឹក ការចំណាយវដ្ដទេយ្យបុរេប្រទានពុំទាន់សមស្រប ការទូទាត់ និងការកត់ត្រាចំណាយ ការត្រួតពិនិត្យភាពត្រឹមត្រូវនៃអាណត្តិបើកប្រាក់ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ។

កិច្ចប្រតិបត្តិការថវិកាអនុវត្តក្រៅរតនាគារជាតិ ត្រូវបានគ្រោងទុកដោយមានតុល្យភាពចំណូលសរុបស្មើនឹងចំណាយសរុប។ កិច្ចប្រតិបត្តិការនេះអនុវត្តបានចំនួន**៥ ១៨៧ ៧៤៣,៨** លានរៀល ស្មើនឹង **៨៥,៧%** នៃច្បាប់ហិរញ្ញវត្ថុដែលមានចំនួន**៦ ០៥៣ ១៩០,០**លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន **៨៦៥ ៤៤៦,២** លានរៀល។

## ខ. កិច្ចប្រតិបត្តិការថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

ចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្តអនុវត្តបានចំនួន**២ ២១១ ១៤៦,៦** លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុ**៣,៣%** និងចំណាយថវិការបស់រដ្ឋបាលរាជធានីខេត្ត អនុវត្តបានចំនួន**១ ៩៤២ ៤៨៧,៥**លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុ**១៥,០%**។ ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក អនុវត្តចំនួន**២៧២ ៩៦៣,៤** លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុ**០,៥%** និងចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក អនុវត្តបានចំនួន**២៦៣ ៥០៤,៩** លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុ**៤,០%**។ រីឯចំណូលថវិការបស់រដ្ឋបាលឃុំ សង្កាត់ អនុវត្តចំនួន**៨៤៦ ២៣០,៣** លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុ **១០,៣%** និងចំណាយថវិការបស់រដ្ឋបាលឃុំសង្កាត់ អនុវត្តបានចំនួន**៦៥១ ៧៣០,៦**លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុ**៣០,៩%**។

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញមានចំណុចគួរឱ្យកត់សម្គាល់ដូចជាៈ ការកត់ត្រាប្រាក់ពន្ធតែមប្រើសារពើពន្ធពុំទាន់សមស្រប ការផ្តល់សេវាចំពោះឯកសារស្នើសុំបង់ពន្ធប្រថាប់ត្រារបស់អ្នកជាប់ពន្ធមួយចំនួន ការប្រមូលពន្ធដីធ្លីមិនបានប្រើប្រាស់ ការប្រមូលចំណូលពីសោហ៊ុយសេវាសំណង់ពុំទាន់អស់លទ្ធភាព ការគ្រប់គ្រងស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈនៅមានកម្រិត ការបំបែកគម្រោងចំណាយដើម្បីតម្រូវតាមសិទ្ធិសម្រេច ការពុំបានប្រមូលផ្ដុំប្រភេទទំនិញបញ្ចូលក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំ ការផ្ដល់ទម្រង់ពាក្យស្នើសុំសេវារដ្ឋបាលជូនប្រជាពលរដ្ឋ កិច្ចលទ្ធកម្មសាធារណៈមួយចំនួនពុំមានអនុលោមភាពពីក្រសួងមហាផ្ទៃ និងភាពយឺតយ៉ាវក្នុងធ្វើប្លង់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ។

## ១. សេចក្តីផ្តើម

### ១.១. លក្ខណៈទូទៅ

ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ តម្រូវឱ្យអាជ្ញាធរសវនកម្មជាតិមានភារកិច្ច អនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល ធ្វើសវនកម្មលើកិច្ចបញ្ជិកាគណនេយ្យ គណនី ប្រព័ន្ធគ្រប់គ្រង ការត្រួតពិនិត្យកិច្ចប្រតិបត្តិការ និងកម្មវិធីរបស់បណ្តាក្រសួង ស្ថាប័ន ភ្នាក់ងារ អាជ្ញាធរ ធនាគារជាតិ ស្ថាប័នហិរញ្ញវត្ថុរដ្ឋ និងស្ថាប័នហិរញ្ញវត្ថុចម្រុះឯកជន សហគ្រាសសាធារណៈ គ្រឹះស្ថាន សាធារណៈ រដ្ឋបាលរាជធានីខេត្ត រដ្ឋបាលមូលដ្ឋាន អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្មចំពោះ រាជរដ្ឋាភិបាលតាមកិច្ចសន្យា និងបណ្តាអង្គការផ្សេងៗទៀតដែលរាជរដ្ឋាភិបាលបានផ្តល់ជំនួយហិរញ្ញវត្ថុ បន្ថែមលើទុនផ្ទាល់ និងឥណទាន រួមមានទាំងការលើកលែងពន្ធអាករគ្រប់ប្រភេទ ព្រមទាំងសម្បទាន ផ្សេងៗទៀតទៅអង្គការដែលមិនរកប្រាក់ចំណេញ និងសហគ្រាសវិនិយោគឯកជន។

ក្រៅពីការងារខាងលើនេះ អាជ្ញាធរសវនកម្មជាតិមានភារកិច្ចធ្វើសវនកម្មបញ្ជាក់លើសេចក្តី ព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ និងធ្វើរបាយការណ៍ សវនកម្មជូនទៅរដ្ឋសភា ព្រឹទ្ធសភាដោយផ្ទាល់ និងធ្វើជូនទៅរាជរដ្ឋាភិបាល ដើម្បីជ្រាបជាព័ត៌មាន ព្រម ទាំងផ្សព្វផ្សាយនូវលទ្ធផលសវនកម្មដែលចាំបាច់។

### ១.២. ការអនុវត្ត និងដែនកំណត់សវនកម្ម

ចាប់តាំងពីអាជ្ញាធរសវនកម្មជាតិបានដំណើរការការងារនៅចុងឆ្នាំ២០០១ រហូតមកដល់ឆ្នាំ ២០២១ អាជ្ញាធរសវនកម្មជាតិបានអនុវត្តភារកិច្ចធ្វើសវនកម្មនៅតាមបណ្តាក្រសួង ស្ថាប័ន រដ្ឋបាល រាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ គម្រោង និងសម្បទានវិនិយោគផ្សេងៗ ជា ពិសេសគឺការធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការ គ្រប់គ្រងឆ្នាំនីមួយៗ។ សម្រាប់ការិយបរិច្ឆេទ២០២០ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្ម និងរៀបចំ របាយការណ៍ ដែលខ្លឹមសារសំខាន់ៗមួយចំនួនក្នុងរបាយការណ៍ទាំងនោះត្រូវបានដកស្រង់មកបង្ហាញ ក្នុងចំណុចទី៣ នៃរបាយការណ៍សម្រាប់ផ្សព្វផ្សាយជាសាធារណៈនេះ។

អាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មដោយអនុលោមតាមស្តង់ដារសវនកម្មសាធារណៈនៃ ព្រះរាជាណាចក្រកម្ពុជា និងគោលការណ៍សវនកម្មទូទៅដែលតម្រូវឱ្យមានការរៀបចំផែនការ និងអនុវត្ត ការងារសវនកម្មដោយផ្អែកលើមូលដ្ឋាននៃការត្រួតពិនិត្យវាយតម្លៃលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់ គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុលោមតាមបទប្បញ្ញត្តិ និងកិច្ចប្រតិបត្តិការការងាររបស់ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធនានា ព្រមទាំងការធ្វើតេស្តលើឯកសារផ្សេងៗ ដើម្បីទទួលបានភស្តុតាងសវនកម្មសម ស្របសម្រាប់ធ្វើសេចក្តីសន្និដ្ឋាន និងផ្តល់អនុសាសន៍កែលម្អដល់អង្គភាពរងសវនកម្មទាំងនោះ។

### ១.៣. គោលបំណងនៃការផ្សព្វផ្សាយ

ការផ្សព្វផ្សាយរបាយការណ៍សវនកម្មជាសាធារណៈ មានគោលបំណងចូលរួមចំណែក ជាមួយស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ ដើម្បីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចប្រតិបត្តិ

ការការងាររបស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានា តាមរយៈការចង្អុលបង្ហាញនូវចំណុចខ្វះខាតក្នុងការអនុវត្តកន្លងមក និងផ្តល់អនុសាសន៍កែលម្អនូវចំណុចខ្វះខាតទាំងនោះ សំដៅធ្វើឱ្យការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកាន់តែប្រសើរឡើងថែមទៀត។

អាជ្ញាធរសវនកម្មជាតិមិនទទួលខុសត្រូវអំពីផលប៉ះពាល់ណាមួយចំពោះក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន ក្រុមហ៊ុន សហគ្រាស ឬបុគ្គលពាក់ព័ន្ធនានា ក្នុងករណីដែលមានតតីយជនទាំងឡាយណាយកខ្លឹមសារក្នុងរបាយការណ៍ផ្សព្វផ្សាយជាសាធារណៈនេះទៅធ្វើការបកស្រាយ ឬប្រើប្រាស់ខុសគោលដៅ។

## ២. ការគ្រប់គ្រងថវិកា

### ២.១. មូលដ្ឋានគតិយុត្តនៃការអនុវត្តថវិកា

កិច្ចដំណើរការនៃថវិកាឆ្នាំ២០២០ ត្រូវបានប្រព្រឹត្តទៅដោយផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួន ដែលមានជាអាទិ៍ ៖

- ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨
- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១២១៩/០២៥ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩
- ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ២០១១
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស២ចុះថ្ងៃទី ០១៧/០៥០៨/រកម/៤ ខែឧសភា ឆ្នាំ២០០៨
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខជស/រកម/០៣០១/១៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១
- អនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ

### ២.២. កិច្ចប្រតិបត្តិការថវិកា

កិច្ចប្រតិបត្តិការថវិកាឆ្នាំ២០២០ ត្រូវបានរៀបចំឡើងដោយផ្អែកតាមលទ្ធផលនៃការអនុវត្តចំណូល ចំណាយតាមរយៈរតនាគារជាតិ រតនាគាររាជធានី ខេត្ត និងលទ្ធផលនៃការអនុវត្តគម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសដែលអនុវត្តក្រៅរតនាគារជាតិ ដូចមានបង្ហាញក្នុងតារាងខាងក្រោម ៖

## ក/ កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

*ឯកតា : លានរៀល*

| បរិយាយ | ឆ្នាំ២០២០ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| **I. សរុបចំណូល** | **៣០ ៣៩៥ ៨៥៥,0** | **២៨ ៥០០ ៣៧២,៥** | **៩៣,៨%** |
| -ចំណូលចរន្ត | ២៣ ៨៩៩ ៣២៤,0 | ២១ ៤២០ ៩៨៩,១ | ៨៩,៦% |
| -ចំណូលមូលធន | ៤៤៣ ៣៤១,0 | ១ ៨៩១ ៦៣៩,៦ | ៤២៦,៧% |
| +ចំណូលមូលធនក្នុងប្រទេស | ១៩៣ ៣៤១,0 | ១៨៥ ២៤៣,៨ | ៩៥,៨% |
| +ចំណូលមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទាន ដោយដៃគូអភិវឌ្ឍ | ២៥០ 000,0 | ១ ៧០៦ ៣៩៥,៨ | ៦៨២,៦% |
| -ចំណូលមូលធនសម្រាប់គម្រោងដោយ ហិរញ្ញប្បទានក្រៅប្រទេស | ៦ ០៥៣ ១៩០,0 | ៥ ១៨៧ ៧៤៣,៨ | ៨៥,៧% |
| **II. សរុបចំណាយ** | **៣១ ៨៣៣ ៩៩៨,១** | **២៩ ៥០២ ៧៤៦,៥** | **៩២,៧%** |
| -ចំណាយចរន្ត | ១៧ ៩៥១ ០២៧,១* | ១៧ ៣៤៥ ៣៤៤,១ | ៩៦,៦% |
| -ចំណាយមូលធន | ៧ ៨២៩ ៧៨១,0 | ៦ ៩៦៩ ៦៥៨,៦ | ៨៩,0% |
| +វិនិយោគសាធារណៈដោយហិរញ្ញប្បទាន ក្នុងប្រទេស | ៦ ៧២៣ ៨៥៩,0 | ៥ ៨៨៧ ៤១៩,៧ | ៨៧,៦% |
| +ការទូទាត់ការខ្ចី | ១ ១០៥ ៩២២,0 | ១ ០៨២ ២៣៨,៩ | ៩៧,៩% |
| -ចំណាយមូលធនសម្រាប់គម្រោងដោយ ហិរញ្ញប្បទានក្រៅប្រទេស | ៦ ០៥៣ ១៩០,0 | ៥ ១៨៧ ៧៤៣,៨ | ៨៥,៧% |

**កំណត់សម្គាល់:** កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិឆ្នាំ២០២០ ដកស្រង់ចេញពីច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០

* តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាចំនួន១ ២៧៥ ៦០០,០លានរៀល ដោយយោងការធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ដែលមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១។

## ខ-កិច្ចប្រតិបត្តិការថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

### ខ១/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលរាជធានី ខេត្ត

*ឯកតា : លានរៀល*

| បរិយាយ | ឆ្នាំ២០២០ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| **I. សរុបចំណូលថវិកា** | **២ ២៨៦ ៥៩១,០** | **២ ២១១ ១៤៦,៦** | **៩៦,៧%** |
| -ចំណូលចរន្ត | ២ ២៣១ ៦៦៧,០ | ២ ១៥៦ ០៧៩,៣ | ៩៦,៦% |
| •ចំណូលសារពើពន្ធ | ២ ០៨៦ ៣០៨,០ | ១ ៩៤២ ៧៨៩,៦ | ៩៣,១% |
| •ចំណូលពុំមែនសារពើពន្ធ | ១៤៥ ៣៥៩,០ | ២១៣ ២៨៩,៧ | ១៤៦,៧% |
| -ឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | ៥៤ ៩២៤,០* | ៥៥ ០៦៧,៣** | ១០០,៣% |
| **II. សរុបចំណាយថវិកា** | **២ ២៨៦ ៥៨៥,០*** ** | **១ ៩៤២ ៤៨៧,៥** | **៨៥,០%** |
| -ចំណាយចរន្ត | ១ ៧៩២ ២២៩,០ | ១ ៤៩៧ ៤៦២,៤ | ៨៣,៦% |
| -ចំណាយមូលធន | ៤៩៤ ៣៥៦,០ | ៤៤៥ ០២៥,១ | ៩០,០% |

<u>**កំណត់សម្គាល់**</u> កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលរាជធានី ខេត្តឆ្នាំ២០២០ ដកស្រង់ចេញពីច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០

* តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាចំនួន ៧ ៩០០លានរៀល ដោយយោងការធ្វើនិយ័តកម្មឥណទានថវិកាជូនសាលាខេត្តសៀមរាប (មូលនិធិអភិរក្ស និងអភិវឌ្ឍន៍តំបន់អង្គរ)

** តួលេខនេះរួមមាន៖ ចំណូលឧបត្ថម្ភធនពីថ្នាក់ជាតិចំនួន ៤៧ ១៦៧,៣លានរៀល និងចំណូលឧបត្ថម្ភធនពីមូលនិធិថ្នាក់ជាតិចំនួន ៧ ៩០០លានរៀល។ ចំពោះចំណូលឧបត្ថម្ភធនពីថ្នាក់ជាតិ បានបូកបញ្ចូលនូវចំណូលថវិកាចំនួន ១៤៣,៣លានរៀល យោងការធ្វើនិយ័តកម្មឥណទានថវិការបស់រដ្ឋបាលក្រុង ស្រុកផ្តល់ជូនរដ្ឋបាលខណ្ឌសម្រាប់ការធ្វើសមាហរណកម្មរចនាសម្ព័ន្ធការិយាល័យជំនាញ១៩ វិស័យ។

*** តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាសរុបចំនួន ៤៧៩ ១៣០លានរៀល ក្នុងនោះ៖ (១)-ឥណទានថវិកាចំនួន ៤៧១ ២៣០លានរៀល ដោយយោងប្រកាសបន្ថែមឥណទានថវិកាសម្រាប់ជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលរាជធានី ខេត្ត និង(២)-ឥណទានថវិកាចំនួន ៧ ៩០០លានរៀល យោងការធ្វើនិយ័តកម្មឥណទានថវិកាជូនសាលាខេត្តសៀមរាប (មូលនិធិអភិរក្ស និងអភិវឌ្ឍន៍តំបន់អង្គរ)។ ឥណទានថវិកានេះរួមមាន ចំណាយចរន្តចំនួន ៤៤៧ ១៣០លានរៀល និងចំណាយមូលធនចំនួន ៣២ ០០០លានរៀល។

## ខ៧/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលក្រុង ស្រុក

*ឯកតា : លានរៀល*

| បរិយាយ | ឆ្នាំ២០២០ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| **I. សរុបចំណូលថវិកា** | **២៧៤ ៣៩០,៨** | **២៧២ ៩៦៣,៤** | **៩៩,៥%** |
| -ចំណូលចរន្ត (មិនមែនសារពើពន្ធ) | ៣១ ៦៤៦,០* | ៣០ ៤០៣,៧ | ៩៦,១% |
| -ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | ២៤២ ៧៤៤,៨** | ២៤២ ៥៥៩,៧ | ៩៩,៩% |
| **II. សរុបចំណាយថវិកា** | **២៧៤ ៣៩០,៨** | **២៦៣ ៥០៤,៩** | **៩៦,០%** |
| -ចំណាយចរន្ត | ២៧៤ ៣៩០,៨*** | ២៦៣ ៥០៤,៩ | ៩៦,០% |

**កំណត់សម្គាល់:** កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលក្រុង ស្រុកឆ្នាំ២០២០ ដកស្រង់ចេញពីច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០

(*) តួលេខនេះបូកបញ្ចូលចំនួន ១១ ៥៣៥,០លានរៀល ពីប្រភពការបែងចែកចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្ត៤% និងតួលេខថវិកាចំនួន ៨ ០០០,០លានរៀល សម្រាប់អនុវត្តមុខងារសេវាអនាម័យបរិស្ថាន។

(**) តួលេខនេះបូកបញ្ចូលថវិកាប្រកាសបន្ថែមឥណទានថវិកាការិយាល័យជំនាញ១៩វិស័យ ដែលសមាហរណកម្មចូលរចនាសម្ព័ន្ធក្រុង ស្រុក ចំនួន ១ ១៦៨,៧លានរៀល និងបូកបន្ថែមថវិកាពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន១៦ស្រុក ចំនួន ៦ ៤៥៩,០ លានរៀល សម្រាប់ចំណាយអភិវឌ្ឍន៍។

(***) តួលេខនេះ បានបូកបញ្ចូលនូវ៖ (១)-ឥណទានចំនួន ១១ ៥៣៥,០លានរៀល ដោយយោងប្រកាសបន្ថែមឥណទានថវិកាពីការបែងចែកចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្ត ៤% សម្រាប់ចំណាយអភិវឌ្ឍន៍ (២)-ប្រកាសបន្ថែមឥណទានថវិកាចំនួន ៨ ០០០,០ លានរៀល សម្រាប់អនុវត្តមុខងារសេវាអនាម័យបរិស្ថាន (៣)-ប្រកាសបន្ថែមឥណទានថវិកាពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន ១៦ស្រុក ចំនួន ៦ ៤៥៩,០លានរៀល សម្រាប់ចំណាយអភិវឌ្ឍន៍ និង(៤)-ប្រកាសបន្ថែមឥណទានថវិកាការិយាល័យជំនាញ១៩វិស័យ ដែលសមាហរណកម្មចូលរចនាសម្ព័ន្ធក្រុង ស្រុកចំនួន ១ ១៦៨,៧លានរៀល។

## ខ៣/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលឃុំ សង្កាត់

*ឯកតា : លានរៀល*

| បរិយាយ | ឆ្នាំ២០២០ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| **I. សរុបចំណូលថវិកា** | **៩៤៣ ៧៨១,២** | **៨៤៦ ២៣០,៣** | **៨៩,៧%** |
| -ចំណូលមិនមែនសារពើពន្ធ | 0 | ៤៩ ៧៩៣,១ | |
| -ចំណូលឧបត្ថម្ភពីថវិកាជាតិ | ៨០៣ ៧១២,0* | ៦៥៦ ៣៦៨,0 | ៨១,៧% |
| -អតិរេកឆ្នាំ២០១៩ | ១៤០ ០៦៩,២ ** | ១៤០ ០៦៩,២ | ១00,0% |
| **II. សរុបចំណាយថវិកា** | **៩៤៣ ៧៨១,២** | **៦៥១ ៧៣០,៦** | **៦៩,១%** |
| -ចំណាយសង្កាត់ចំណុះរាជធានី | ៥៨ ៥៣៩,៩ | ៤៨ ៨៧៤,១ | ៨៣,៥% |
| - ចំណាយសង្កាត់ចំណុះក្រុង | ៧៩ ៨៤៩,៧ | ៥២ ៧៣០,១ | ៦៦,0% |
| -ចំណាយឃុំ | ៨០៥ ៣៩១,៦ | ៥៥០ ១២៦,៤ | ៦៨,៣% |

***កំណត់សម្គាល់:*** កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០២០ ដកស្រង់ចេញពីច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០

---

(*) តួលេខនេះបូកបញ្ចូលនូវឥណទានចំនួន ៣៩០លានរៀលដោយយោងការធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០១៩ ស្តីពីការផ្ទេរឥណទានថវិកា

(**) តួលេខនេះបូកបញ្ចូលនូវឥណទានចំនួន ១៤០ ០៦៩,២លានរៀល ដោយយោងការធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ដែលមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០។

## ៣. លទ្ធផលសវនកម្ម

### ៣.១. ការគ្រប់គ្រងថវិកាថ្នាក់ជាតិ

#### ៣.១.១.ការធ្វើសវនកម្មសម្រាប់កម្មវិធីសវនកម្មឆ្នាំ២០២០

ដើម្បីប្រមូលពន្ធពីការខកខាន ឬការធ្វេសប្រហែលណាមួយពីអ្នកជាប់ពន្ធ ការិយាល័យសវនកម្មពន្ធនៃសាខាពន្ធដារខេត្ត និងខណ្ឌមានភារកិច្ចរៀបចំកម្មវិធីសវនកម្ម និងធ្វើសវនកម្មលើឯកសារ និងសវនកម្មមានកម្រិតលើអ្នកជាប់ពន្ធឱ្យបានទាន់ពេល ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព...។

តាមការពិនិត្យលើកម្មវិធីសវនកម្មរបស់ការិយាល័យសវនកម្មពន្ធនៃសាខាពន្ធដារខណ្ឌ និងខេត្ត អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០២០ ការិយាល័យសវនកម្មពន្ធនៃសាខាពន្ធដារខណ្ឌ និងខេត្តបានលើកកម្មវិធីសវនកម្មសរុបចំនួន២ ៩០៣ សហគ្រាស ក្នុងនោះការិយាល័យសវនកម្មពន្ធនៃសាខាពន្ធដារខណ្ឌបានអនុវត្តការងារសវនកម្មសម្រេចបានលទ្ធផលចំនួន១ ៦៦៨ សហគ្រាស ស្មើនឹង៨៤%នៃកម្មវិធីសវនកម្ម និងការិយាល័យសវនកម្មពន្ធនៃសាខាពន្ធដារខេត្ត បានអនុវត្តការងារសវនកម្មសម្រេចបានលទ្ធផលចំនួន៧០២ សហគ្រាស ស្មើនឹង៧៦%នៃកម្មវិធីសវនកម្ម ប៉ុន្តែការិយាល័យសវនកម្មពន្ធនៃសាខាពន្ធដារខណ្ឌ និងខេត្តមិនបានធ្វើសវនកម្មលើសហគ្រាសមួយចំនួនទៀត។

ភាពយឺតយ៉ាវក្នុងការបញ្ចប់កម្មវិធីសវនកម្មឆ្នាំ២០២០បណ្តាលមកពីការរៀបចំកម្មវិធីសវនកម្ម និងការធ្វើសវនកម្មមិនទាន់បានល្អប្រសើរ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំដល់អគ្គនាយកដ្ឋានពន្ធដារឱ្យរៀបចំកម្មវិធីសវនកម្ម និងធ្វើសវនកម្មដោយផ្អែកលើធនធានសវនករ។

ឆ្លើយតបនឹងបញ្ហាខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមឯកភាព និងសូមបំភ្លឺបន្ថែមថា សម្រាប់កម្មវិធីសវនកម្មឆ្នាំ២០២០ ពិតជាមានភាពយឺតយ៉ាវប្រាកដមែន ដោយការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ និងការដាក់កម្មវិធីច្រើនលើសលុប។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងបន្តខិតខំកែលម្អលើចំណុចខ្វះខាតនេះ ឱ្យបានល្អប្រសើរនៅឆ្នាំបន្តបន្ទាប់។

#### ៣.១.២.ការកត់ត្រាប្រាក់ពន្ធតែមប្រ៊ិសារពើពន្ធ

ដើម្បីផ្តល់លទ្ធភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួនឱ្យកាន់តែប្រសើរឡើង រាជរដ្ឋាភិបាលបានផ្តល់ប្រភពចំណូលបន្ថែមជូនរដ្ឋបាលរាជធានី ខេត្ត ដោយផ្ទេរគណនី៧០០៨១ "ពន្ធតែមប្រ៊ិសារពើពន្ធ" ពីថវិកាជាតិមកថវិកាថ្នាក់ក្រោមជាតិ តាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១២១៩/០២៥ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ ត្រង់មាត្រា១០ ចំណុច១ ចែងថា ពន្ធតែមប្រ៊ិសារពើពន្ធដែលជាគុណប្រយោជន៍ថវិកាថ្នាក់ជាតិ ត្រូវបានផ្ទេរជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលរាជធានី ខេត្ត។

តាមការពិនិត្យស្ថិតិលើប្រាក់ពន្ធតែមប្រើសារពើពន្ធប្រចាំខែ និងសំណុំឯកសារផ្សេងៗ របស់សាខាពន្ធដារខេត្តមួយចំនួន និងតាមការធ្វើតេស្តលើស្លាកយីហោរបស់សាខាក្រុមហ៊ុន ដែលប្រកបអាជីវកម្មនៅតាមខេត្តមួយចំនួន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រុមហ៊ុនមេ ឬទីស្នាក់ការកណ្តាលបានប្រកាស និងបង់ប្រាក់ពន្ធតែមប្រើសារពើពន្ធជូនដល់អង្គភាពពន្ធ ដែលក្រុមហ៊ុននោះបានចុះបញ្ជី។ ប៉ុន្តែអង្គភាពពន្ធ ដែលទទួលបានចំណូលពីពន្ធតែមប្រើសារពើពន្ធនោះ មិនទាន់បានបង្វែរប្រាក់ពន្ធតែមប្រើសារពើពន្ធខាងលើទៅអង្គភាពពន្ធ ដែលស្លាកយីហោរបស់សាខាក្រុមហ៊ុនទាំងនោះ ស្ថិតនៅតាមទីតាំងជាក់ស្តែងនៅឡើយទេ។

ការកត់ត្រាចំណូលពីពន្ធតែមប្រើសារពើពន្ធមិនបានត្រឹមត្រូវទៅតាមទីតាំងជាក់ស្តែង ដែលស្លាកយីហោស្ថិតនៅចូលជាចំណូលថវិការាជធានី ខេត្តនាំឱ្យការកត់ត្រាចំណូលនេះ មិនត្រឹមត្រូវតាមចំណាត់ថ្នាក់អនុគណនី និងធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមិនមានថវិកាគ្រប់គ្រាន់ ដើម្បីអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំដល់អគ្គនាយកដ្ឋានពន្ធដារឱ្យពិនិត្យការកត់ត្រាពន្ធតែមប្រើសារពើពន្ធឱ្យបានសមស្របតាមចំណាត់ថ្នាក់អនុគណនី និងទីតាំងស្លាកយីហោស្ថិតនៅជាក់ស្តែង។

ឆ្លើយតបនឹងបញ្ហាខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមឯកភាព និងសូមបំភ្លឺបន្ថែមថា កន្លងមក មានសហគ្រាសជាច្រើនបានបំពេញកាតព្វកិច្ចបង់ពន្ធតែមប្រើសារពើពន្ធនៅរាជធានីភ្នំពេញ ជាងនៅតាមបណ្តាសាខាពន្ធដារខេត្ត។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងបន្តខិតខំកែលម្អលើចំណុចខ្វះខាតនេះ ឱ្យបានល្អប្រសើរនៅឆ្នាំបន្តបន្ទាប់។ ដើម្បីដោះស្រាយបញ្ហានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាពិសេសអគ្គនាយកដ្ឋានពន្ធដារគួរពិនិត្យបញ្ជាក់ការបង់ប្រាក់ពន្ធតែមប្រើសារពើពន្ធ និងបង្វែរប្រាក់ពន្ធតែមប្រើសារពើពន្ធទៅអង្គភាពពន្ធដែលស្លាកយីហោស្ថិតនៅជាក់ស្តែង ដើម្បីកត់ត្រាចូលជាថវិការដ្ឋបាលរាជធានី ខេត្ត។

**៣.១.៣.ចំណូលផ្សេងៗ និងបង្វែររង់ចាំដំណោះស្រាយ**

ដើម្បីធានាថា តួលេខចំណូលថវិកាត្រូវបានកត់ត្រាត្រឹមត្រូវតាមឆ្នាំថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសលេខ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ ត្រង់ឧបសម្ព័ន្ធទី២ ចំណុច១៣៤ "គណនីចំណូលផ្សេងៗ និងបង្វែររង់ចាំដោះស្រាយ" ចែងថា គណនីលេខ ៤៧០៦ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលផ្សេងៗ ឬចំនួនទឹកប្រាក់ដែលត្រូវបង្វែរទៅគណនីអកម្មផ្សេងទៀត។

តាមការពិនិត្យតារាងតុល្យភាពបណ្តោះអាសន្នគណនីថវិកាថ្នាក់កណ្តាលនៅអគ្គនាយកដ្ឋានរតនាគារជាតិ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ចំណូលផ្សេងៗនិងបង្វែររង់ចាំដោះស្រាយមានចំនួន ២៤ ៦៧០ ២៩៦ ០៦៧ រៀល ពុំទាន់ជម្រះ ឬបង្វែរសមតុល្យទៅគណនីអកម្មផ្សេងទៀតនៅបិទបញ្ជីគណនេយ្យប្រចាំការិយបរិច្ឆេទ២០២០ នៅឡើយទេ។

ភាពយឺតយ៉ាវនៃការជម្រះ ឬបង្វែរសមតុល្យនៃគណនីចំណូលផ្សេងៗ និងបង្វែររង់ចាំដោះស្រាយទៅគណនីអកម្មផ្សេងទៀត អាចនាំឱ្យតួលេខចំណូលក្នុងការិយបរិច្ឆេទ២០២០

មិនត្រូវបានបង្ហាញត្រឹមត្រូវ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរជំរុញឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា ខិតខំដោះស្រាយ និងជម្រះនូវទឹកប្រាក់ទាំងនេះឱ្យបានទាន់ការិយបរិច្ឆេទ។

ឆ្លើយតបនឹងបញ្ហានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមឯកភាព និងសូមបំភ្លឺបន្ថែមថា ក្នុងតួលេខ ២៧ ៦៧០ ២៩៦ ០៦៧ រៀល គឺមានចំណូល ៥លានដុល្លារអាម៉េរិក សមមូលជាប្រាក់រៀល ២០ ៤៩៥ ០០០ ០០០ រៀល ជាចំណូលរបស់ក្រសួងមួយ ដែលពុំទាន់បានបង្វែរចូលជាចំណូលថវិកាជាតិនៅឡើយ ដោយទាមទារនូវនីតិវិធីច្បាស់លាស់ និងការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបង្វែរទៅចំណូលបាន។ បច្ចុប្បន្ន ក្រុមការងារកំពុងដោះស្រាយចំពោះចំណូលនេះ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងបន្តជំរុញដោះស្រាយចំណូលផ្សេងៗរង់ចាំដោះស្រាយ ដើម្បីកត់ត្រាចំណូលទាន់ពេលវេលា។

**៣.១.៤.ការកំណត់តម្លៃគិតពន្ធទំនិញល្មើសនៅទាបជាងតម្លៃចម្លងការ**

នាយកដ្ឋានផែនការ និងបច្ចេកទេសបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាលើការងារកំណត់តម្លៃគិតពន្ធគយនាំចូល ដោយមានតួនាទី និងភារកិច្ច ដូចជា៖ ស្រាវជ្រាវ និងចងក្រងនូវទិន្នន័យតម្លៃគិតពន្ធគយលើទំនិញនាំចេញ-នាំចូល តម្លៃរូបិយប័ណ្ណ អត្រាប្តូរប្រាក់ឱ្យបានសមស្របតាមភាពជាក់ស្តែងសម្រាប់ជាមូលដ្ឋាននៃកិច្ចប្រតិបត្តិការប្រចាំថ្ងៃរបស់អង្គភាពគយ និងរដ្ឋាករពាក់ព័ន្ធ យោងតាមលិខិតលេខ ៣៦៣៩/១៩ អ.គ.រ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការកែសម្រួលតារាងតម្លៃចម្លងការសម្រាប់ជាមូលដ្ឋានពិចារណាលើមុខទំនិញនាំចូលមួយចំនួន បានបញ្ជាក់ថា តារាងតម្លៃចម្លងការសម្រាប់ជាមូលដ្ឋានពិចារណានេះ នឹងត្រូវដាក់ឱ្យអនុវត្តចំពោះទំនិញដែលចូលមកបំពេញបែបបទផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ នេះតទៅ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការកំណត់តម្លៃគិតពន្ធលើទំនិញល្មើសច្បាប់គយនៃកូនជ្រូកពូជមួយចំនួន មានតម្លៃទាបជាងតម្លៃចម្លងការដែលបានចេញសម្រាប់ឱ្យអនុវត្តក្នុងឆ្នាំ២០២០។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមឯកភាព និងសូមបំភ្លឺបន្ថែមថា ករណីការកំណត់តម្លៃលើមុខទំនិញកូនជ្រូកពូជ គឺជាកំហុសបច្ចេកទេសដោយអចេតនារបស់មន្ត្រីគយមានសមត្ថកិច្ចក្នុងការបញ្ចូលទិន្នន័យទៅក្នុងពាក្យស្នើសុំកំណត់តម្លៃគិតពន្ធគយរបស់ម្ចាស់ទំនិញខុសពីទិន្នន័យត្រឹមត្រូវដែលមាននៅក្នុងកំណត់បង្ហាញ។ ករណីនេះ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ បានកោះហៅម្ចាស់ទំនិញឱ្យមកបង់ពន្ធអាករបន្ថែមឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិជាធរមានរួចរាល់ តាមរយៈបង្កាន់ដៃបង់ប្រាក់ផ្សេងៗលេខ 2021O-1 ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងពង្រឹងការងារ និងណែនាំមន្ត្រីទទួលបន្ទុកឱ្យបង្កើនការយកចិត្តទុកដាក់លើការងារនេះបន្ថែមទៀត។

### ៣.១.៥.កង្វះខាតការតាមដាន និងផ្ទៀងផ្ទាត់ចំណូល

តាមកិច្ចព្រមព្រៀងវិនិយោគ BCT រវាងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងក្រុមហ៊ុន CATS ពុំមានចំណុចណាមួយបានចែងអំពីយន្តការ ឬនីតិវិធីនៃការត្រួតពិនិត្យ ឬការផ្ទៀងផ្ទាត់ចំណូលពីការហោះហើរឆ្លងកាត់ និងនាំផ្លូវចុះចតហោះហើរ ដែលគ្រប់គ្រងប្រមូលដោយក្រុមហ៊ុន CATS នោះទេ។ ជាមួយគ្នានេះ ត្រង់មាត្រា៤ ចំណុច៤.១ នៃកិច្ចព្រមព្រៀងនេះ បានចែងថា "រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលត្រូវទទួលខុសត្រូវទាំងអស់លើប្រព័ន្ធប្រតិបត្តិការបច្ចេកទេស ដែលអនុវត្តដោយមន្ត្រីបច្ចេកទេសរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល"។

តាមការពិនិត្យរបាយការណ៍របស់ក្រុមហ៊ុន CATS (Cambodia Air Traffic Services) ដែលបានផ្ញើមករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក្នុងរយៈពេលមួយត្រីមាសម្តងអំពីការបែងចែកប្រាក់ចំណូលរវាងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងក្រុមហ៊ុន CATS អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ទទួលបានតែរបាយការណ៍បែងចែកចំណូលដែលក្រុមហ៊ុន CATS បានផ្ញើជូនតែប៉ុណ្ណោះ ដោយពុំមានឯកសារណាមួយផ្សេងទៀតសម្រាប់ធ្វើការផ្ទៀងផ្ទាត់នូវភាពត្រឹមត្រូវនៃការបែងចែកចំណូលនេះទេ។ របាយការណ៍ហោះហើរឆ្លងកាត់ និងនាំផ្លូវចុះចតហោះហើររបស់ក្រុមហ៊ុនអាកាសចរណ៍ទាំងអស់ ត្រូវបានរាយការណ៍ដោយមន្ត្រីបច្ចេកទេសជូនទៅក្រុមហ៊ុន CATS ជាប្រចាំ ប៉ុន្តែមិនបានផ្ញើមករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលនោះទេ។

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល គួរបង្កើតយន្តការ ឬនីតិវិធីក្នុងការត្រួតពិនិត្យ ដើម្បីធ្វើការផ្ទៀងផ្ទាត់ចំណូលពីការហោះហើរឆ្លងកាត់ និងនាំផ្លូវចុះចតហោះហើរ ដែលគ្រប់គ្រងដោយក្រុមហ៊ុនCATS ដើម្បីបញ្ជាក់ភាពត្រឹមត្រូវ និងពេញលេញនៃការបែងចែកចំណូល។

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលសូមអនុញ្ញាតជម្រាបថា ក្រុមហ៊ុនCATS បានផ្តល់របាយការណ៍ចំនួនជើងហោះហើរជារៀងរាល់ខែមករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដើម្បីធ្វើការផ្ទៀងផ្ទាត់ចំណូល ហើយបច្ចុប្បន្នរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានរៀបចំក្រុមការងារ ដើម្បីចូលរួមសហការជាមួយក្រុមហ៊ុនCATS ក្នុងការផ្ទៀងផ្ទាត់ចំណូលពីកម្រៃសេវាកម្មនាំផ្លូវអាកាសរួចរាល់ហើយ។

### ៣.១.៦.ការបង់ចំណូលចូលថវិកាជាតិឆ្លងឆ្នាំ

សារាចរណែនាំលេខ ០០៨ សហវ អថ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបិទបញ្ជីចំណូល-ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការងារអនុវត្តចំណូល-ចំណាយថ្នាក់ជាតិឆ្នាំ២០២០ ត្រង់ចំណុច I -ក បានចែងថា "ប្រាក់ចំណូលទាំងអស់ ទោះបីស្ថិតក្នុងប្រភេទចំណូលណាក៏ដោយ អាណាប័កគ្មានសិទ្ធិដកចំណូលយកទៅចំណាយ ឬមួយពន្យារពេលបង់ចូលថវិកាថ្នាក់ជាតិ ដើម្បីទុកប្រើប្រាស់ជាផលប្រយោជន៍ណាមួយបានឡើយ។ ដូចនេះ ប្រាក់ចំណូលទាំងអស់ត្រូវតែប្រមូលបង់ចូលថវិកាថ្នាក់ជាតិយ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ជាកំហិត"។

តាមការពិនិត្យលើរបាយការណ៍ចំណូលប្រចាំឆ្នាំ២០២០ បញ្ជីបេឡា ប័ណ្ណចំណូល និងសលាកបត្របង់ចរិកាចូលក្នុងធនាគារជាតិ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈបានបង់ចំណូលចំនួន **៣៨ ០៥២ ៩០០** រៀល ដែលប្រមូលបានពីកម្រៃនៃការថែទាំ ចាប់ពីថ្ងៃ២២ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ចូលចរិកាជាតិនៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១។

កត្តានេះ នាំឱ្យការប្រមូលចំណូលខាងលើមិនឆ្លុះបញ្ចាំងទៅនឹងឆ្នាំសារពើពន្ធ។

ឆ្លើយតបនឹងចំណុចខាងលើ ក្រសួងសូមទទួលយកនូវអនុសាសន៍ខាងលើ ខិតខំពង្រឹង និងណែនាំដល់អង្គភាពក្រោមឱវាទអនុវត្តឱ្យបានត្រឹមត្រូវស្របតាមខ្លឹមសារសារាចរណែនាំខាងលើ។

**៣.១.៧. ក្រុមហ៊ុនចូលរួមដេញថ្លៃមានសកម្មភាពអាជីវកម្មមិនស្របទៅនឹងកម្មវត្ថុនៃការដេញថ្លៃ**

ប្រកាសលេខ១៩៨ សហវ.ប្រក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្ដីពីការកែសម្រួលវិធាន និងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់ ត្រង់ប្រការ៨ វាក្យខណ្ឌ២បានចែងថា "ក្នុងការចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់តម្លៃក្នុងការផ្គត់ផ្គង់ទំនិញ ឬសេវា អ្នកជាប់ពន្ធត្រូវមានប័ណ្ណប៉ាតង់ដែលបញ្ជាក់ពីសកម្មភាពអាជីវកម្មរបស់ខ្លួនស្របតាមកម្មវត្ថុនៃការដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់តម្លៃក្នុងការផ្គត់ផ្គង់សេវាទាំងនោះ"។

តាមការធ្វើតេស្តសំណុំឯកសារគម្រោងលទ្ធកម្មមួយចំនួនរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងក្រសួងអប់រំ យុវជន និងកីឡាក្នុងឆ្នាំ២០២០ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រុមហ៊ុនចូលរួមដេញថ្លៃ និងក្រុមហ៊ុនទទួលការបានប្រើប្រាស់ប័ណ្ណប៉ាតង់ពុំស្របតាមកម្មវត្ថុនៃការដេញថ្លៃ។

អាស្រ័យហេតុនេះ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងក្រសួងអប់រំ យុវជន និងកីឡាគួរអនុវត្តកិច្ចលទ្ធកម្មសាធារណៈឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃប្រកាសខាងលើ។

ចំពោះចំណុចខាងលើ ក្រសួងក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈទទួលយកនូវអនុសាសន៍ខាងលើ ខិតខំពង្រឹង និងណែនាំដល់អង្គភាពក្រោមឱវាទ អនុវត្តឱ្យបានត្រឹមត្រូវស្របតាមខ្លឹមសារសារាចរណែនាំខាងលើ។ ក្រសួងអប់រំ យុវជន និងកីឡាសូមឯកភាពតាមការលើកឡើងរបស់ប្រតិភូអាជ្ញាធរសវនកម្មជាតិ ប៉ុន្តែដោយសារៈ ១.គម្រោងផ្គត់ផ្គង់ទោចក្រយានយន្ត គណៈកម្មាធិការលទ្ធកម្មបានដំណើរការបើកឯកសារដេញថ្លៃនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០។ ក្នុងដំណាក់កាលនៃការវាយតម្លៃសំណើដេញថ្លៃ ក្រុមហ៊ុន SCSD (Cambodia) (ជាក្រុមហ៊ុនដែលទទួលបានកិច្ចសន្យា) បានភ្ជាប់នូវកិច្ចព្រមព្រៀងដៃគូ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ ជាមួយក្រុមហ៊ុន OMC Co,Ltd ជាក្រុមហ៊ុនដែលមានប៉ាតង់សកម្មភាពអាជីវកម្មចម្បង (បរិក្ខារអេឡិចត្រូនិកទោចក្រយានយន្ត និងរថយន្ត) ដោយមានការបញ្ជាក់ច្បាស់លាស់ក្នុងកំណត់ហេតុវាយតម្លៃប្រគល់កិច្ចសន្យាផងដែរ។ ២ .គម្រោងផ្គត់ផ្គង់សម្ភារបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា ក្នុងដំណាក់កាលវាយតម្លៃលើសំណើ

ដេញថ្លៃរបស់ក្រុមហ៊ុនជីអ ស្ទេរសិនរី (ខេមបូឌា) (ជាក្រុមហ៊ុនដែលទទួលបានកិច្ចសន្យា) មានភ្ជាប់ប៉ាតង់ឆ្នាំ២០២០ ដែលមានសកម្មភាពអាជីវកម្មចម្បង (សម្ភារការិយាល័យ) ដែលមិនស្របនឹងកម្មវត្ថុនៃការដេញថ្លៃ។ ករណីនេះ គណៈកម្មាធិការលទ្ធកម្មបានចេញលិខិតលេខ១៦/០១ អយក.គលទ.ទន ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២០ ដើម្បីឱ្យក្រុមហ៊ុនផ្តល់ប៉ាតង់ដែលមានសកម្មភាពអាជីវកម្មចម្បងស្របនឹងការដេញថ្លៃគម្រោងនេះ។ បន្ទាប់មក ក្រុមហ៊ុនបានផ្តល់ប៉ាតង់ឆ្នាំ២០២០ ដែលមានសកម្មភាពអាជីវកម្មសមស្របមកក្រសួងអប់រំ យុវជន និងកីឡា តាមរយៈលិខិតចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០។ ៣.គម្រោងផ្គត់ផ្គង់ឯកសណ្ឋានកាយរឹទ្ធិ តាមការពិនិត្យអំពីលក្ខណៈបច្ចេកទេសនៃមុខទំនិញ ដែលជាតម្រូវការប្រើប្រាស់ស្នើឡើងដោយនាយកដ្ឋានកាយរឹទ្ធិ គឺមានលក្ខណៈជាសម្ភារប្រើប្រាស់ទូទៅ មិនមែនជាសម្លៀកបំពាក់ ស្បែកជើង ខ្សែក្រវ៉ាត់ ដូចជាឯកសណ្ឋានរបស់កងកម្លាំងប្រដាប់អាវុធឡើយ។ ម្យ៉ាងវិញទៀត ក្រុមហ៊ុនក៏ធ្លាប់មានបទពិសោធន៍ផ្គត់ផ្គង់នៅឆ្នាំ២០១៩ ដែរ។

### ៣.១.៨. ការអនុវត្តចំណាយរជ្ជទេយ្យបុរេប្រទានកម្មវិធីមិនទាន់បានត្រឹមត្រូវតាមគោលការណ៍ចំណាយ

ប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ ត្រង់ផ្នែកទី២ ប្រការ១៥បានចែងថា "ជាគោលការណ៍មុននឹងធ្វើការចំណាយជាសាច់ប្រាក់ រជ្ជទេយ្យករបុរេប្រទានត្រូវស្នើសុំគោលការណ៍ចំណាយទៅអាណាប័ក ឬអ្នកដែលទទួលបានការផ្ទេរសិទ្ធិពីអាណាប័ក..." និងប្រការ១៦ បានចែងថា "រាល់ប័ណ្ណចំណាយត្រូវភ្ជាប់មកជាមួយនៅគោលការណ៍ចំណាយ វិក្កយបត្រ ឬសក្ខីបត្រចំណាយដែលរជ្ជទេយ្យកបុរេប្រទានបានធ្វើការទូទាត់ ដោយមានការបញ្ជាក់ទទួលស្គាល់ពីអាណាប័ក ឬអ្នកដែលទទួលបានការផ្ទេរសិទ្ធិពីអាណាប័ក" និងសារាចរណែនាំលេខ០០១ សហវ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៤ ស្តីពីការកែលម្អនីតិវិធីអនុវត្តថវិកា ត្រង់ចំណុច៦បានចែងថា "កិច្ចជម្រះបញ្ជីនេះត្រូវធ្វើឡើងក្រោយចំណាយទាំងឡាយរបស់រដ្ឋ ត្រូវបានបញ្ចប់ព្រមជាមួយនឹងការបញ្ជាក់ពីភាពត្រឹមត្រូវលើគ្រប់សក្ខីបត្រ..."។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពថវិការដ្ឋបាលកណ្តាលមួយចំនួនរបស់ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តការចំណាយថវិការជ្ជទេយ្យបុរេប្រទានថវិកាកម្មវិធីពុំស្របតាមគោលការណ៍ក្នុងការចំណាយថវិការជ្ជទេយ្យបុរេប្រទាននៅឡើយ ដោយបានអនុវត្តការចំណាយមុនគោលការណ៍ឯកភាពពីប្រធានអង្គភាពថវិកា និងសក្ខីបត្រសម្រាប់ការទូទាត់ចំណាយពុំមានចុះកាលបរិច្ឆេទឱ្យបានត្រឹមត្រូវ។

អាស្រ័យហេតុនេះ ក្រសួងអប់រំ យុវជន និងកីឡាគួរធ្វើការណែនាំដល់អង្គភាពថវិកាក្រោមឱវាទឱ្យធ្វើការចំណាយថវិការជ្ជទេយ្យបុរេប្រទានឱ្យបានត្រឹមត្រូវទៅតាមគោលការណ៍ នីតិវិធីចំណាយថវិការជ្ជទេយ្យបុរេប្រទាន និងសក្ខីបត្រសម្រាប់ទូទាត់ការចំណាយ។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងអប់រំ យុវជន និងកីឡាសូមធ្វើការបញ្ជាក់ថា នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបុគ្គលិក អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ និងសាកលវិទ្យាល័យមានជ័យ កន្លងមក នាយកដ្ឋានហិរញ្ញវត្ថុបានណែនាំដល់គ្រប់អង្គភាពថវិកា គឺរាល់ការចំណាយត្រូវមានគោលការណ៍អនុញ្ញាតជាមុន។ ក្នុងន័យនេះ នាយកដ្ឋានហិរញ្ញវត្ថុសូមទទួលយកចំណុចរកឃើញខាងលើ ហើយនឹងពង្រឹងបន្ថែមដល់អង្គភាពសាមី ក៏ដូចជាអង្គភាពផ្សេងៗទៀត។

**៣.១.៩.ការកត់ត្រាគណនីចំណាយថវិកាបុរេប្រទានមិនទាន់មានលក្ខណៈសមស្រប**

ឧបសម្ព័ន្ធទី២នៃមាតិកាចំណាយថវិកាភ្ជាប់ជាមួយប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ បានកំណត់ពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចខាងក្រោម៖

- គណនី អនុគណនី៦១០៤១ ចំណាយដែលទាក់ទងនឹងការបណ្តុះបណ្តាល ការរៀបចំឯកសារ និងសម្ភារតូចតាច ការជួលទីតាំង និងការរៀបចំទីកន្លែង ការឧបត្ថម្ភគ្រូឧទ្ទេស និងអ្នកសម្របសម្រួល និងចំណាយផ្សេងៗបម្រើឱ្យសកម្មភាពការបណ្តុះបណ្តាល ព្រមទាំងការទូទាត់ជូនអ្នកជំនាញការដែលមិនមែនជាមន្ត្រីរាជការ និងការបង់ថ្លៃសាលាក្នុង និងក្រៅប្រទេស។

- កចំណាយដែលទាក់ទងដល់ការឧបត្ថម្ភទាំងផ្ទៃ ៦២០៣៨គណនី អនុគណនី ហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុដល់អង្គភាពដែលមានលក្ខណៈសង្គម និងវប្បធម៌ផ្សេងទៀត។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពថវិកាវិទ្យាស្ថានជាតិអប់រំនៃក្រសួងអប់រំ យុវជន និងកីឡាបានចំណាយ និងកត់ត្រាចំណាយថវិកាបុរេប្រទានឧបត្ថម្ភដល់អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (អង្គការខេម) ដើម្បីរៀបចំកិច្ចដំណើរការមជ្ឈមណ្ឌលសាលាជំនាន់ថ្មីពុំទាន់ស្របទៅនឹងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិថវិកាដូចមានបង្ហាញក្នុងតារាងខាងក្រោម៖

ឯកតាគិតជា:រៀល

| ល.រ | កម្មវត្ថុចំណាយ | ទឹកប្រាក់ | អនុគណនីចំណាយ និងកត់ត្រាជាក់ស្តែង ដោយអង្គភាព | អនុគណនីចំណាយ គួរកត់ត្រាតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋ |
|---|---|---|---|---|
| ១ | ចំណាយបុរេប្រទានកិច្ចដំណើរការមជ្ឈមណ្ឌលសាលាជំនាន់ថ្មីរបស់អង្គការខេប | ៦៦៣ ០០០ ០០០ | ៦១០៤១ | ៦២០៣៨ |

អាស្រ័យហេតុនេះ ក្រសួងអប់រំ យុវជន និងកីឡាគួរធ្វើការណែនាំដល់អង្គភាពថវិកាវិទ្យាស្ថានជាតិអប់រំឱ្យធ្វើការចំណាយ និងកត់ត្រាចំណាយថវិកាបុរេប្រទានក្នុងការឧបត្ថម្ភខាងលើឱ្យបានត្រឹមត្រូវស្របតាមប្រកាសស្តីពីចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាខាងលើ។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងអប់រំ យុវជន និងកីឡាសូមឯកភាពតាមការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ។ ប៉ុន្តែវិទ្យាស្ថានជាតិអប់រំសូមបញ្ជាក់ថា កញ្ចប់ថវិកានេះត្រូវបាននាយកដ្ឋានហិរញ្ញវត្ថុអនុញ្ញាតឱ្យបញ្ចូលទៅក្នុងអនុគណនី៦១០៤១។ វិទ្យាស្ថាននឹងពង្រឹងការអនុវត្តតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ ដោយធ្វើការសម្របសម្រួលជាមួយនាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចាប់ពីឆ្នាំ២០២២ តទៅ។

**៣.១.១០.ការអនុវត្តគម្រោងកិច្ចលទ្ធកម្មលើសផែនការលទ្ធកម្មប្រចាំឆ្នាំ**

សារាចរណែនាំលេខ០០២ សហវ.អលសា ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ បានបញ្ជាក់ថា "ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវប្រមូលផ្តុំគម្រោងចំណាយដែលត្រូវអនុវត្តកិច្ចលទ្ធកម្មទាំងអស់កត់ត្រាបញ្ចូលក្នុងផែនការលទ្ធកម្ម។ រាល់គម្រោងចំណាយដែលត្រូវអនុវត្តកិច្ចលទ្ធកម្មទាំងឡាយណាដែលមិនបានកត់ត្រានៅក្នុងផែនការលទ្ធកម្ម មិនអនុញ្ញាតឱ្យសុំ ឬផ្តល់ការធានាចំណាយឡើយ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សម្រាប់ការិយបរិច្ឆេទ២០២០ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានអនុវត្តគម្រោងកិច្ចលទ្ធកម្ម (ទំនិញ និងសំណង់) លើសផែនការលទ្ធកម្មប្រចាំឆ្នាំចំនួន០២គម្រោង។

កត្តានេះនាំឱ្យការអនុវត្តផែនការលទ្ធកម្មប្រចាំឆ្នាំពុំទាន់មានប្រសិទ្ធភាព។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គួរណែនាំដល់អង្គភាពលទ្ធកម្មអនុវត្តកិច្ចលទ្ធកម្មឱ្យស្របតាមផែនការប្រចាំឆ្នាំដែលបានអនុម័ត។

ក្រសួងសូមធ្វើការបំភ្លឺថា យោងលិខិតរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការយល់ព្រមធានាចំណាយថវិកាសម្រាប់ចំណាយទិញបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា និងចំណាយរៀបចំជួសជុលអគារធ្វើការ និងបន្ទប់ដាក់Server ដោយប្រើប្រាស់កញ្ចប់ថវិកាសល់ពីការអនុវត្តឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ដោយអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈជាធរមាន។ ប្រការនេះ ត្រូវអនុវត្តក្នុងឆ្នាំ២០២០ ហើយនីតិវិធីនៃការកែតម្រូវផែនការលទ្ធកម្មត្រូវបានបិទ ទើបក្រសួងមិនបានធ្វើការកែតម្រូវ ហើយអនុវត្តកិច្ចលទ្ធកម្មលើសគម្រោងទាំងពីរតាមគោលការណ៍ផ្តល់ធានាចំណាយរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**៣.១.១១.ការបំបែកបណ្ណចំណាយដើម្បីគេចវេសនីតិវិធីលទ្ធកម្ម**

ប្រកាសលេខ៨២៩ សហវ ប្រក.ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិបានបញ្ជាក់ថា " រដ្ឋទេយ្យករបុរេប្រទាន ឬរដ្ឋទេយ្យករបុរេប្រទានរង ត្រូវជៀសវាងដាច់ខាតនូវការបំបែកប័ណ្ណចំណាយទៅ

តាមទីកន្លែង ឬគោលដៅចំណាយ ពេលវេលា ទឹកប្រាក់ចំណាយ និងសមាសធាតុនៃមុខសញ្ញាចំណាយក្នុងគោលបំណងគេចវេសការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ ”។

តាមការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០២០ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពថវិកាអគ្គនាយកដ្ឋានបច្ចេកទេស និងអង្គភាពថវិកាអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានប្រើប្រាស់ថវិការជួទេយ្យបុរេប្រទានកម្មវិធីសម្រាប់ចំណាយលើការថែទាំ ជួសជុល និងឧបត្ថម្ភដល់អង្គភាពដែលមានលក្ខណៈសង្គម និងវប្បធម៌(ទិញសម្ភារកីឡា) ជូនអង្គភាពរបស់ខ្លួន ដោយធ្វើការបំបែកប័ណ្ណចំណាយ ដើម្បីធ្វើការគេចវេសពីការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ។

ដើម្បីធានាឱ្យការចំណាយថវិការជួទេយ្យបុរេប្រទានអនុវត្តដោយតម្លាភាព ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គួរធ្វើការណែនាំដល់អង្គភាពថវិកាទាំងពីរខាងលើអនុវត្តការចំណាយថវិការជួទេយ្យបុរេប្រទានឱ្យបានត្រឹមត្រូវតាមនីតិវិធីចំណាយឱ្យមានប្រសិទ្ធភាពខ្ពស់។

ក្រសួងសូមធ្វើការបំភ្លឺថា មូលហេតុអង្គភាពទាំងពីរខាងលើបំបែកបណ្ណចំណាយដោយសារការចំណាយទាំងនេះមានលក្ខណៈបន្ទាន់ ត្រូវចំណាយភ្លាមៗតាមការស្នើសុំរបស់អង្គភាពចំណុះ។ ម៉្យាងវិញទៀត ឥណទានដែលត្រូវអនុវត្តនេះមានចំនួនតិចតួចជាហេតុពិបាកក្នុងការអនុវត្តតាមនីតិវិធីលទ្ធកម្ម។ ក្រសួងបានណែនាំអង្គភាពខាងលើត្រូវអនុវត្តតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។

**៣.១.១២.ពេលវេលានៃការអនុវត្តកិច្ចលទ្ធកម្មពុំស្របតាមផែនការលទ្ធកម្មប្រចាំឆ្នាំ**

សារាចរណែនាំលេខ ០០២ សហវ.អលសា ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ បានបញ្ជាក់ថា ស្ថាប័នអនុវត្តលទ្ធកម្មត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់ និងទៀងទាត់តាមវិធីសាស្ត្រ និងពេលវេលានៃដំណាក់កាលនីមួយៗនៃកិច្ចលទ្ធកម្ម ដូចមានចែងក្នុងផែនការលទ្ធកម្មដែលបានអនុម័ត។

តាមការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០២០ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពថវិកាបេឡាជាតិអតីតយុទ្ធជននៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានអនុវត្តកិច្ចលទ្ធកម្មពុំស្របតាមពេលវេលានៃផែនការលទ្ធកម្មប្រចាំឆ្នាំដែលបានអនុម័តនៅឡើយ។

អាស្រ័យហេតុនេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គួរណែនាំអង្គភាពថវិកាបេឡាជាតិអតីតយុទ្ធជន អនុវត្តកិច្ចលទ្ធកម្មឱ្យស្របតាមផែនការប្រចាំឆ្នាំរបស់ខ្លួន។

ក្រសួងសូមធ្វើការបំភ្លឺថា យោងសារាចររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការធ្វើវិចារណកម្ម តម្រូវឱ្យអង្គភាពលទ្ធកម្មរបស់បេឡាជាតិអតីតយុទ្ធជន រៀបចំការស្នើសុំធានាចំណាយថ្មីទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធ្វើនីតិវិធីលទ្ធកម្ម។ ម៉្យាងវិញទៀត មានការយឺតយ៉ាវក្នុងការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យានៅអគ្គនាយកដ្ឋានរតនាគារជាតិរបស់

ក្រុមហ៊ុន ទើបធ្វើឱ្យការចុះកិច្ចសន្យាខុសពីកាលបរិច្ឆេទ និងការបញ្ចូលទំនិញរបស់ក្រុមហ៊ុនមកបេឡាជាតិអតីតយុទ្ធជនមិនទាន់ពេលវេលា ជាហេតុធ្វើឱ្យការប្រគល់-ទទួលមានការយឺតយ៉ាវ។ ក្រសួងបានណែនាំអង្គភាពខាងលើ ត្រូវអនុវត្តតាមអនុសាសន៍របស់អាជ្ញាធរ សវនកម្មជាតិ។

### ៣.១.១៣.ការអនុវត្តប្រកាសអន្តរក្រសួងលេខ២៦១ ស.អ.យ មិនទាន់បានពេញលេញ

អនុក្រឹត្យលេខ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការរៀបចំ និងដាក់ឱ្យអនុវត្តអង្គភាពថវិកា បានកំណត់ថា "អង្គភាពថវិកា គឺជាអង្គភាពដែលត្រូវបានទទួលស្គាល់អាណត្តិកិច្ចច្បាស់លាស់ ក្នុងការអនុវត្តសកម្មភាពការងារដើម្បីបង្កើតបានជាលទ្ធផលជាក់លាក់ និងអាចវាស់វែងបាន និងរួមចំណែកក្នុងការសម្រេចគោលបំណងគោលនយោបាយអាទិភាពរបស់ក្រសួង ស្ថាប័ន " និងប្រកាសអន្តរក្រសួងលេខ២៦១ ស.អ.យ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមួយនឹងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកាបានបញ្ជាក់ថា ទទួលស្គាល់ និងដាក់ឱ្យអនុវត្តអង្គភាពថវិកាចំនួន៣០ រួមមាន៖ អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេស បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល បេឡាជាតិអតីតយុទ្ធជន មូលនិធិជនពិការ និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី-ខេត្តទាំង២៥ ។

តាមការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០២០ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អគ្គនាយកដ្ឋានបច្ចេកទេសមិនទាន់មានអាណត្តិកិច្ចច្បាស់លាស់ ក្នុងការអនុវត្តសកម្មភាពការងាររបស់ខ្លួន ដូចជា ការទូទាត់ថវិកាចំណាយរជ្ជទេយ្យបុរេប្រទាន នៅឡើយ។

ដើម្បីឱ្យការងារថវិការបស់អង្គភាពជំនាញអនុវត្តបានពេញលេញ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គួរធ្វើការរៀបចំចាត់ចែងការងារអនុវត្តថវិការបស់អង្គភាពថវិកាខាងលើឱ្យមានប្រសិទ្ធភាព។

ក្រសួងសូមធ្វើការបំភ្លឺថា បច្ចុប្បន្នក្រសួងបាននឹងកំពុងខិតខំបណ្តុះបណ្តាលមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់អង្គភាពទាំងពីរ ពាក់ព័ន្ធនឹងនីតិវិធីអនុវត្តថវិកាកម្មវិធីតាមរយៈការចូលរៀនវគ្គខ្លីៗនៅវិទ្យាស្ថានជាតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីឱ្យមានសមត្ថភាពគ្រប់គ្រាន់ឈានទៅអនុវត្តសកម្មភាពពេញលេញនាពេលខាងមុខស្របតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។

### ៣.១.១៤.កង្វះខាតយន្តការក្នុងការតាមដានគណនីអតីតយុទ្ធជន

កិច្ចព្រមព្រៀងរវាងធនាគារអេស៊ីលីដា ភីអិលស៊ី (ភាគីក) និងបេឡាជាតិអតីតយុទ្ធជន (ភាគីខ) ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការប្រើប្រាស់សេវាកម្មធនាគារ បានបញ្ជាក់ថា "ភាគី ក ត្រូវធ្វើរបាយការណ៍សមតុល្យគណនីប្រចាំខែរបស់បេឡាជាតិអតីតយុទ្ធជនជូនភាគី ខ តាមសារអេឡិចត្រូនិច នៅរៀងរាល់សប្តាហ៍ទី១ នៃខែបន្ទាប់" និង " ភាគី ក ត្រូវធ្វើរបាយការណ៍គណនីអតីតយុទ្ធជនដែលមិនបានមកបើកប្រាក់ពីធនាគារជូនភាគី ខ តាមសារអេឡិចត្រូនិចនៅរៀងរាល់បីខែម្តង។ របាយការណ៍គណនីអតីតយុទ្ធជន ត្រូវបែងចែកលម្អិត

តាមខេត្តទាំង២៤។ ក្នុងករណីចាំបាច់ ភាគីក ត្រូវបោះពុម្ពរបាយការណ៍គណនីអតីតយុទ្ធជនជូនភាគី ខ តាមការស្នើសុំរបស់ភាគី ខ"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សម្រាប់ការិយបរិច្ឆេទ២០២០ បេឡាជាតិអតីតយុទ្ធជនពុំទាន់បានអនុវត្តយន្តការក្នុងការតាមដានគណនីអតីតយុទ្ធជននៅឡើយ។

ដើម្បីធានាឱ្យការគ្រប់គ្រងគណនីអតីតយុទ្ធជនមានភាពច្បាស់លាស់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គួរធ្វើការណែនាំបេឡាជាតិអតីតយុទ្ធជន ឱ្យតាមដានគណនីអតីតយុទ្ធជនឱ្យមានប្រសិទ្ធភាពខ្ពស់។

ក្រសួងបានណែនាំអង្គភាពខាងលើ ត្រូវខិតខំបង្កើតក្រុមការងារដើម្បីមានយន្តការក្នុងការតាមដានគណនីរបស់អតីតយុទ្ធជនក្នុងឆ្នាំ២០២១ ឱ្យបានរួចរាល់ស្របតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។

**៣.១.១៥.ការពុំបានទុករយៈពេលគ្រប់១០ថ្ងៃសម្រាប់ជំទាស់តវ៉ាក្រោយចេញលិខិតសម្រេចប្រគល់កិច្ចសន្យា**

ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០១២/០០៤ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១២ ត្រង់មាត្រា៤៨ចែងថា ប្រសិនបើមិនមានការជំទាស់តវ៉ាណាមួយក្នុងរយៈពេល១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីការចេញសេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យា អង្គភាពលទ្ធកម្មត្រូវស្នើសុំអ្នកដេញថ្លៃឈ្នះផ្តល់នូវឯកសារប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា និងរៀបចំកិច្ចសន្យាលទ្ធកម្ម ដូចមានចែងក្នុងជំពូកទី៩នៃច្បាប់នេះ។

តាមការពិនិត្យលើសំណុំឯកសារលទ្ធកម្មរបស់អង្គភាពលទ្ធកម្មនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់សម្រាប់ការិយបរិច្ឆេទ២០២០ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពលទ្ធកម្មរបស់ក្រសួងពុំបានទុករយៈពេលគ្រប់១០ថ្ងៃនៃថ្ងៃធ្វើការក្នុងករណីមានជំទាស់តវ៉ាណាមួយពីក្រុមហ៊ុនដែលដេញថ្លៃចាញ់លើគម្រោងដេញថ្លៃ ក្រោយពីការចេញលិខិតសម្រេចជ្រើសរើស និងប្រគល់កិច្ចសន្យាជូនក្រុមហ៊ុនដែលឈ្នះនោះទេ។ ជាមួយគ្នានេះ អង្គភាពលទ្ធកម្មរបស់ក្រសួង បានធ្វើការចេញលិខិតជ្រើសរើសនិងប្រគល់កិច្ចសន្យា និងលិខិតអញ្ជើញឱ្យក្រុមហ៊ុនដែលឈ្នះមកចុះកិច្ចសន្យាដោយភ្ជាប់នូវឯកសារប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាក្នុងថ្ងៃតែមួយ ដូចមានបង្ហាញជូនក្នុងតារាងខាងក្រោម៖

| ល.រ | បរិយាយ | ថ្ងៃចេញលិខិតជ្រើសរើស | ថ្ងៃអញ្ជើញចុះកិច្ចសន្យា |
|---|---|---|---|
| ១ | ទិញប្រេងឥន្ធនៈ | ២៩ កក្កដា ២០២០ | ២៩ កក្កដា ២០២០ |
| ២ | ទិញសម្ភារការិយាល័យ | ០៧ សីហា ២០២០ | ០៧ សីហា ២០២០ |
| ៣ | បោះពុម្ព | ០៧ សីហា ២០២០ | ០៧ សីហា ២០២០ |
| ៤ | គ្រឿងសង្ហារិម | ១០ សីហា ២០២០ | ១០ សីហា ២០២០ |
| ៥ | ជួសជុលអគារទីស្តីការ | ១៣ តុលា ២០២០ | ១៣ តុលា ២០២០ |
| ៦ | សេវាបោសជូតនិងអនាម័យ | ១៣ តុលា ២០២០ | ១៣ តុលា ២០២០ |
| ៧ | សម្ភារបរិក្ខារបច្ចេកទេស | ០៨ ធ្នូ ២០២០ | ០៨ ធ្នូ ២០២០ |

ដើម្បីឱ្យការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈឱ្យបានត្រឹមត្រូវ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់គួរតែណែនាំដល់អង្គភាពលទ្ធកម្មឱ្យធ្វើការកែលម្អឱ្យស្របតាមច្បាប់។

ឆ្លើយតបនៅការលើកឡើងខាងលើ មូលហេតុដែលអង្គភាពលទ្ធកម្មពុំបានទុករយៈពេល១០ថ្ងៃសម្រាប់ការជំទាស់តវ៉ាព្រោះកិច្ចសន្យាលទ្ធកម្មទាំង៧ នោះជាគម្រោងដែលអនុវត្តនៅចុងកាលបរិច្ឆេទ ឆ្លើយតបមិនទាន់ទៅនឹងការទូទាត់ថវិកាចរន្តក្នុងឆ្នាំ និងគម្រោងដែលមានការប្រើប្រាស់ទំនិញ និងសេវាចាំបាច់ និងបន្ទាន់។

## ៣.១.១៦.កង្វះវិធានការចំពោះសំណង់ដែលបានសាងសង់ដោយពុំបានស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសាងសង់

ប្រកាសលេខ៣២ ប្រ/សណ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់ ត្រង់ប្រការ៣ ចែងថា ការដ្ឋាននីមួយៗ អាចដំណើរបានលុះត្រាតែមានលិខិតអនុញ្ញាតបើកការដ្ឋាន។ លិខិតបើកការដ្ឋាន ត្រូវស្នើសុំនៅក្រសួងរៀបចំដែនដី នគរូបនីកម្ម និងសំណង់ ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុងក្នុងរយៈពេលមួយខែយ៉ាងយូរ បន្ទាប់ពីទទួលបានលិខិតអនុញ្ញាតសាងសង់ និងប្រកាសអន្តរក្រសួងលេខ៣៥៦ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រង់មាត្រាទី១ ចែងថាអនុញ្ញាតឱ្យក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈដើម្បីជាគុណប្រយោជន៍ដល់ថវិកាជាតិ។

តាមការពិនិត្យរបាយការណ៍ស្តីពីលទ្ធផលការងារផ្តល់សេវាសាធារណៈ ក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ប្រចាំឆ្នាំ២០២០ របស់ការិយាល័យច្រកចេញចូលតែមួយរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០២០ ក្រសួងបានចេញលិខិតអនុញ្ញាតសាងសង់បានចំនួន៥៨១គម្រោង ក្នុងនោះក្រសួងបានចេញលិខិតអនុញ្ញាតបើកការដ្ឋានបានចំនួន១២៨ គម្រោង ប៉ុន្តែនៅសល់៤៥៣គម្រោងទៀតដែលក្រសួងមិនបានចេញ។ ជាមួយគ្នានេះ ក្រសួងក៏ពុំទាន់មានវិធានការចំពោះការដ្ឋានសំណង់ដែលមិនទាន់បានស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសាងសង់ពីក្រសួងនៅឡើយ ។

ដើម្បីឱ្យការគ្រប់គ្រងការសាងសង់ស្របតាមបទដ្ឋានបច្ចេកទេសសំណង់ និងប្លង់ស្ថាបត្យកម្ម ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ គួរចាត់វិធានការឱ្យបានតឹងរឹងចំពោះការដ្ឋានទាំងឡាយដែលពុំបានសុំលិខិតអនុញ្ញាតបើកការដ្ឋានសាងសង់។

ឆ្លើយតបនៅការលើកឡើងខាងលើ បច្ចុប្បន្ន អគ្គនាយកដ្ឋានសំណង់មានវិធានការមួយចំនួនចំពោះសំណង់ដែលពុំបានស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានដូចខាងក្រោម៖

- បានផ្ញើលិខិតអញ្ជើញម្ចាស់សំណង់ដែលទទួលបានលិខិតអនុញ្ញាតសាងសង់ពីក្រសួង មកបំពេញបែបបទស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់។

• ចេញលិខិតជូនម្ចាស់សំណង់ឱ្យអញ្ជើញមន្ត្រីជំនាញចុះបោះបង្គោលព្រំ មុនចាប់ផ្តើមដំណើរការសាងសង់។

• ចេញលិខិតផ្អាកការដ្ឋានសំណង់ដែលគ្មានលិខិតអនុញ្ញាតបើកការដ្ឋានសំណង់។

**៣.១.១៧.កង្វះខាតក្នុងការប្រកាសក្រមសីលធម៌សម្រាប់ការអនុវត្តវិធីសាស្ត្រលទ្ធកម្មដោយឡែក**

ប្រកាសលេខ៩៨៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីក្រមសីលធម៌លទ្ធកម្ម ត្រង់ប្រការ៨ និងប្រការ១១ បានបញ្ជាក់ថា គណៈកម្មាធិការលទ្ធកម្ម មន្ត្រីអង្គភាពលទ្ធកម្ម និងអ្នកដេញថ្លៃត្រូវចុះហត្ថលេខាលើសេចក្តីប្រកាសស្តីពីក្រមសីលធម៌លទ្ធកម្មនៅគ្រប់ពេលចូលរួមវាយតម្លៃសំណើដេញថ្លៃ។

តាមការពិនិត្យឯកសារគម្រោងលទ្ធកម្មប្រចាំឆ្នាំ២០២០ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានអនុវត្តវិធីសាស្ត្រលទ្ធកម្មដោយឡែកចំនួន០២គម្រោង ដែលមានទឹកប្រាក់សរុបចំនួន ៧ ៨០៤ ០០០ ០០០រៀល ប៉ុន្តែគណៈកម្មាធិការលទ្ធកម្ម មន្ត្រីអង្គភាពលទ្ធកម្ម និងអ្នកទទួលការពុំបានប្រកាសក្រមសីលធម៌នៅក្នុងដំណើរការនៃការអនុវត្តវិធីសាស្ត្រលទ្ធកម្មដោយឡែកទេ។

អាស្រ័យហេតុនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គួរណែនាំគណៈកម្មាធិការលទ្ធកម្ម មន្ត្រីអង្គភាពលទ្ធកម្ម និងអ្នកទទួលការ ឱ្យប្រកាសក្រមសីលធម៌វិជ្ជាជីវៈ ដើម្បីជំរុញឱ្យការអនុវត្តដំណើរការនៃកិច្ចលទ្ធកម្មសាធារណៈប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព។

ឆ្លើយតបនឹងចំណុចដែលបានលើកឡើងនេះ ក្រសួងទទួលយកនូវអនុសាសន៍ខាងលើ ខិតខំពង្រឹង និងណែនាំដល់អង្គភាពក្រោមឱវាទអនុវត្តឱ្យបានត្រឹមត្រូវស្របតាមខ្លឹមសារនៃប្រកាសខាងលើ។

**៣.១.១៨.កង្វះខាតក្នុងការរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តការងារការអនុវត្តគម្រោងលទ្ធកម្មតបណ្តាញអគ្គិសនី និងប្រព័ន្ធទឹក**

ប្រកាសលេខ១៦១៣ សហវ.ប្រក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងការអនុវត្តកិច្ចសន្យាលទ្ធកម្មសាធារណៈ ត្រង់ជំពូកទី២ ផ្នែកទី៣ បានចែងថា "អ្នកផ្គត់ផ្គង់ និងអ្នកទទួលការមានភារកិច្ចអនុវត្តកិច្ចសន្យាលទ្ធកម្មសំខាន់ៗជាអាទិ៍៖ រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តការងាររហូតដល់ការប្រគល់ទទួលចប់ជាស្ថាពរជូនស្ថាប័នអនុវត្តលទ្ធកម្ម និងអង្គភាពថវិកា"។

តាមការពិនិត្យផែនការលទ្ធកម្មប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈឆ្នាំ២០២០ អាជ្ញាធរសវនកម្មជាតិបានសង្កេតឃើញថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអនុវត្តកិច្ចលទ្ធកម្មសាធារណៈចំនួន៣៤គម្រោង ក្នុងនោះអ្នកទទួលការពុំបានរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តការងារជូនស្ថាប័នអនុវត្តលទ្ធកម្ម រួមមាន ការងារតបណ្តាញអគ្គិសនីចំនួន០២គម្រោង ការងារជួសជុលហេដ្ឋារចនាសម្ព័ន្ធ

និងបន្ទប់ធ្វើការនៅទីស្តីការក្រសួងចំនួន០១គម្រោង និងការរៀបចំប្រព័ន្ធទឹកចំនួន០២គម្រោង មានទឹកប្រាក់សរុបចំនួន ១ ៩៣៥ ៣៨១ ០០០ រៀល។

អាស្រ័យហេតុនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈគួរណែនាំអ្នកទទួលការឱ្យអនុវត្តការងារស្របតាមប្រកាសខាងលើ។

ចំពោះចំណុចខាងលើ ក្រសួងទទួលយកនូវអនុសាសន៍ខាងលើ ខិតខំពង្រឹង និងណែនាំដល់អង្គភាពក្រោមឱវាទអនុវត្តឱ្យបានត្រឹមត្រូវស្របតាមខ្លឹមសារប្រកាសខាងលើ ដោយរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តការងាររហូតដល់ការប្រគល់ទទួលចប់ជាស្ថាពរជូនស្ថាប័នអនុវត្តលទ្ធកម្ម និងអង្គភាពថវិកា។

**៣.១.១៩.ការចំណាយរជ្ជទេយ្យបុរេប្រទានពុំទាន់សមស្រប**

ប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ ត្រង់ជំពូកទី៣ ផ្នែកទី២ ប្រការ១៧ កថាខណ្ឌទី២ បានចែងថា "រជ្ជទេយ្យបុរេប្រទានត្រូវជៀសវាងដាច់ខាតនូវការបំបែកប័ណ្ណចំណាយទៅតាមទីកន្លែង ឬគោលដៅចំណាយពេលវេលា ទឹកប្រាក់ចំណាយ និងសមាសធាតុនៃមុខសញ្ញាចំណាយក្នុងគោលបំណងគេចវេសពីការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ"។

ប្រកាសលេខ១៨៦៦ សហវ.ប្រក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកំណត់កម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម ត្រង់ប្រការ១ បានចែងថា "ត្រូវបានកំណត់ទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្មទំនិញ សំណង់ និងសេវានៅក្រសួងស្ថាប័នរាជធានី-ខេត្ត សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី១ ថា សម្រាប់ទំនិញ និងសេវាកម្មត្រូវអនុវត្តវិធីសាស្ត្រពិគ្រោះថ្លៃ(ព.ថ) ចំពោះទឹកប្រាក់ចាប់ពី២០លានរៀល ដល់១០០លានរៀល"។

តាមការពិនិត្យរបាយការណ៍ចំណាយរជ្ជទេយ្យបុរេប្រទានឆ្នាំ២០២០ និងប្រតិបត្តិការនីមួយៗនៃការចំណាយរជ្ជទេយ្យបុរេប្រទាន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នៅក្នុងខែមករា និងខែកុម្ភៈ ឆ្នាំ២០២០ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអនុវត្តការចំណាយរជ្ជទេយ្យបុរេប្រទាន ដោយទិញគ្រឿងបន្លាស់ និងសំបកកង់រថយន្តចំនួន២៦ប័ណ្ណចំណាយ មានទឹកប្រាក់សរុបចំនួន ៥៨ ៣០៥ ០០០រៀល និងជួសជុលរថយន្តចំនួន១៥ប័ណ្ណចំណាយមានទឹកប្រាក់សរុបចំនួន ៦៤ ៧៤៩ ២០០រៀល ដោយពុំបានអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ។

អាស្រ័យហេតុនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈគួរអនុវត្តការចំណាយរជ្ជទេយ្យបុរេប្រទានឱ្យស្របតាមប្រកាសខាងលើ។

ចំពោះចំណុចខាងលើ ក្រសួងទទួលយកនូវអនុសាសន៍ខាងលើ ខិតខំពង្រឹង និងណែនាំដល់អង្គភាពក្រោមឱវាទអនុវត្តឱ្យបានត្រឹមត្រូវស្របតាមខ្លឹមសារប្រកាសខាងលើ។

## ៣.២.ការគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

### ៣.២.១.ការកត់ត្រាប្រាក់ពន្ធតែមប្រិ៍សារពើពន្ធពុំទាន់សមស្រប

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១២១៩/០២៥ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ ត្រង់មាត្រា១០ ចំណុច១ ចែងថា ពន្ធតែមប្រិ៍សារពើពន្ធដែលជាគុណប្រយោជន៍ថវិកាថ្នាក់ជាតិ ត្រូវបានផ្ទេរជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលរាជធានី ខេត្ត។

តាមការពិនិត្យស្ថិតិលើប្រាក់ពន្ធតែមប្រិ៍សារពើពន្ធប្រចាំខែ និងសំណុំឯកសារផ្សេងៗរបស់សាខាពន្ធដារខេត្តមួយចំនួន និងតាមការធ្វើតេស្តលើស្លាកយីហោរបស់សាខាក្រុមហ៊ុនដែលប្រកបអាជីវកម្មនៅតាមខេត្តមួយចំនួន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រុមហ៊ុនមេឬទីស្នាក់ការកណ្តាលបានប្រកាស និងបង់ប្រាក់ពន្ធតែមប្រិ៍សារពើពន្ធជូនដល់អង្គភាពពន្ធដែលក្រុមហ៊ុននោះបានចុះបញ្ជី។ ប៉ុន្តែអង្គភាពពន្ធដែលទទួលបានចំណូលពីពន្ធតែមប្រិ៍សារពើពន្ធនោះ មិនទាន់បានបង្វែរប្រាក់ពន្ធតែមប្រិ៍សារពើពន្ធខាងលើទៅអង្គភាពពន្ធដែលស្លាកយីហោរបស់សាខាក្រុមហ៊ុនទាំងនោះស្ថិតនៅតាមទីតាំងជាក់ស្តែងនៅឡើយទេ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំអគ្គនាយកដ្ឋានពន្ធដារឱ្យបង្វែរប្រាក់ពន្ធតែមប្រិ៍សារពើពន្ធទៅអង្គភាពពន្ធដែលស្លាកយីហោស្ថិតនៅ និងកត់ត្រាប្រាក់ពន្ធតែមប្រិ៍សារពើពន្ធឱ្យបានត្រឹមត្រូវតាមចំណាត់ថ្នាក់អនុគណនី ដើម្បីឱ្យបានជាប្រយោជន៍ដល់រដ្ឋបាលរាជធានី ខេត្ត។

កន្លងមក មានសហគ្រាសជាច្រើនបានបំពេញកាតព្វកិច្ចបង់ពន្ធតែមប្រិ៍សារពើពន្ធនៅរាជធានីភ្នំពេញ ជាងនៅតាមបណ្តាសាខាពន្ធដារខេត្ត។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងបន្តខិតខំកែលម្អលើចំណុចខ្វះខាតនេះឱ្យបានល្អប្រសើរនៅឆ្នាំបន្តបន្ទាប់។

### ៣.២.២.ការផ្តល់សេវាចំពោះឯកសារស្នើសុំបង់ពន្ធប្រថាប់ត្រារបស់អ្នកជាប់ពន្ធមួយចំនួន

ដើម្បីសម្រួលដល់សាធារណៈជនក្នុងការបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិអចលនទ្រព្យឱ្យបានឆាប់រហ័ស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកំណត់ឱ្យអគ្គនាយកដ្ឋានពន្ធដារផ្តល់សេវាចំពោះការបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិក្នុងរយៈពេលចំនួន ៤-៨ ថ្ងៃ (ថ្ងៃធ្វើការ)។ តាមការពិនិត្យសំណុំឯកសារស្នើសុំបង់ពន្ធប្រថាប់ត្រាចំនួន៧១៨ ក្នុងខែមករា មិថុនា និងធ្នូ ឆ្នាំ២០២០ របស់សាខាពន្ធដារខេត្តចំនួន១២ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សាខាពន្ធដារខេត្តមួយចំនួន មានភាពយឺតយ៉ាវក្នុងការផ្តល់សេវាប្រថាប់ត្រាលើអចលនទ្រព្យមួយចំនួនតូច **ដែលពុំ**ឱ្យស្របតាមការកំណត់ក្នុងប្រកាសខាងលើ (**យឺត**ចាប់ពី២៨ថ្ងៃ រហូតដល់៤៦ថ្ងៃ)។

ភាពយឺតយ៉ាវក្នុងការផ្តល់សេវាប្រថាប់ត្រាចំពោះផ្ទេរកម្មសិទ្ធិអចលនទ្រព្យ អាចនាំឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពការងារ និងនាំឱ្យមានការថ្នាំងថ្នាក់ពីអ្នកជាប់ពន្ធមួយចំនួនផងដែរ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំដល់អគ្គនាយកដ្ឋានពន្ធដារផ្តល់សេវាប្រថាប់ត្រាលើអចលនទ្រព្យឱ្យកាន់តែប្រសើរថែមទៀត។

ជាវិធានការ ដើម្បីពន្លឿនការផ្តល់សេវាស្នើសុំបង់ពន្ធប្រថាប់លើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យជូនអ្នកជាប់ពន្ធ អគ្គនាយកដ្ឋានពន្ធដារបានផ្តល់ជម្រើសអាចឱ្យអ្នកជាប់ពន្ធ ដែលមានអចលនទ្រព្យនៅតាមបណ្តាខេត្តស្នើសុំបង់ពន្ធប្រថាប់ត្រានៅនាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យបានយ៉ាងទូលំទូលាយ។ ទន្ទឹមនឹងការទទួលយកអនុសាសន៍នេះ អគ្គនាយកដ្ឋានពន្ធដារនឹងបន្តជំរុញដល់គ្រប់សាខាពន្ធដារខេត្តពាក់ព័ន្ធ ត្រូវបន្តយកចិត្តទុកដាក់ផ្តោតលើបញ្ហាដូចបានលើកឡើងខាងលើដោយការទទួលខុសត្រូវ។

### ៣.២.៣.ការប្រមូលពន្ធដីធ្លីមិនបានប្រើប្រាស់

ដើម្បីប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ឱ្យអស់លទ្ធភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកែសម្រួលសមាសភាពគណៈកម្មការវាយតម្លៃដីសម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ហើយក៏មានសេចក្តីសម្រេចស្តីពីការបង្កើតអនុគណៈកម្មការវាយតម្លៃដីសម្រាប់ពន្ធលើដីធ្លីមិបានប្រើប្រាស់រាជធានី ខេត្ត បានចែងថា "អនុគណៈកម្មការវាយតម្លៃដីសម្រាប់ពន្ធដីធ្លីមិនបានប្រើប្រាស់មានភារកិច្ចបង្កើតបញ្ជីដីត្រូវជាប់ពន្ធតាមតំបន់រាជធានី ខេត្ត..."។

តាមការធ្វើសវនកម្មនៅសាខាពន្ធដារខេត្តចំនួន១៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សាខាពន្ធដារខេត្តទាំងនេះបានខិតខំប្រមូលពន្ធដីធ្លីមិនបានប្រើប្រាស់បានលើសផែនការឆ្នាំ២០២០ ដោយការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ភាគច្រើនធ្វើឡើងនៅពេលម្ចាស់ដីស្នើសុំបង់ពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិដី ទោះបីជាសាខាពន្ធដារខេត្តទាំងនេះពុំទាន់ទទួលបានបញ្ជីដីដែលត្រូវជាប់ពន្ធពីអនុគណៈកម្មការវាយតម្លៃដីសម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ក៏ដោយ។ ការខកខានក្នុងការបំពេញតួនាទីរបស់គណៈកម្មការវាយតម្លៃដីសម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ធ្វើឱ្យការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ពុំទាន់បានពេញលេញ។ គណៈកម្មការវាយតម្លៃដីសម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ គួរជំរុញឱ្យអនុគណៈកម្មការវាយតម្លៃដីសម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់នៅតាមបណ្តារាជធានីខេត្តរៀបចំបញ្ជីដីដែលត្រូវជាប់ពន្ធ។

ជាវិធានការ អគ្គនាយកដ្ឋានពន្ធដារនឹងបន្តជំរុញ និងណែនាំសាខាពន្ធដារពាក់ព័ន្ធត្រូវខិតខំអនុវត្តការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់នៅសាខាពន្ធដារខេត្តទាំងអស់ឱ្យអស់លទ្ធភាព។

### ៣.២.៤.ការប្រមូលចំណូលពីសោហ៊ុយសេវាសំណង់ពុំទាន់អស់លទ្ធភាព

អនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីលិខិតអនុញ្ញាតសាងសង់ បានតម្រូវឱ្យម្ចាស់សំណង់មុនចាប់ដំណើរការការដ្ឋានម្ចាស់សំណង់ត្រូវមានលិខិតអនុញ្ញាតសាងសង់ បើកការដ្ឋាន និងបិទការដ្ឋានពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ឬការិយាល័យខេត្ត ក្រុង និងប្រកាសអន្តរក្រសួងលេខ៣៥៦ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩ រវាងក្រសួងសេដ្ឋកិច្ច និង

ហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីផ្តល់សេវាសាធារណៈ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានកំណត់នូវដែនសមត្ថកិច្ចជូនមន្ទីរ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីលើការគ្រប់គ្រង ការផ្តល់លិខិតអនុញ្ញាត សាងសង់ លិខិតអនុញ្ញាតបើកការដ្ឋាន និងលិខិតអនុញ្ញាតបិទការដ្ឋានសំណង់លំនៅឋាន ដូចជា ភូមិគ្រឹះ ផ្ទះល្វែង ផ្ទះថ្មក្រោមឈើលើ ទាំងនៅក្រៅក្រុង ក្នុងក្រុង និងរាជធានី ព្រម ទាំងបានកំណត់នូវថ្លៃសេវាលើវិស័យសំណង់ត្រូវប្រមូលផងដែរ ។

តាមការធ្វើសវនកម្មនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្តចំនួន៧ ឃើញថា មន្ទីរបានផ្តល់លិខិតអនុញ្ញាតសាងសង់ជូនម្ចាស់សំណង់ និង បានប្រមូលចំណូលពីសេវានេះរួចហើយ ប៉ុន្តែមន្ទីរទាំងនេះខកខានមិនបានប្រមូលចំណូលពី សេវាបើក និងបិទការដ្ឋានឱ្យបានគ្រប់តាមចំនួនលិខិតអនុញ្ញាតសាងសង់នៅឡើយ ដូចមាន បង្ហាញក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះខេត្ត | ចំនួនលិខិតអនុញ្ញាត សាងសង់ | ចំនួនលិខិតបើក ការដ្ឋាន | ចំនួនលិខិតបិទ ការដ្ឋាន |
|---|---|---|---|---|
| ១ | ខេត្តតាកែវ | ៥៤ | ០៤ | 0 |
| ២ | ខេត្តកំពង់ស្ពឺ | ៣២ | ០៩ | 0 |
| ៣ | ខេត្តបាត់ដំបង | ៣៦ | ១២ | 0 |
| ៤ | ខេត្តក្រចេះ | ១២៣ | ២១ | 0 |
| ៥ | ខេត្តសៀមរាប | ៦៦ | ០១ | 0 |
| ៦ | ខេត្តបន្ទាយមានជ័យ | ៧៧ | ០៥ | 0 |
| ៧ | ខេត្តព្រៃវែង | ១៩ | ០៤ | 0 |

ដោយសារកង្វះខាតក្នុងការបំពេញកាតព្វកិច្ចរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី នាំឱ្យបាត់ចំណូលសម្រាប់ជាគុណប្រយោជន៍ថវិការាជធានី ខេត្ត ហើយសំណង់អាចមិនរៀបរយត្រឹមត្រូវតាមប្លង់ និងបទដ្ឋានបច្ចេកទេសនៃសំណង់។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្តគួរណែនាំដល់មន្ទីរជំនាញខាងលើឱ្យខិតខំអនុវត្ត តាមគោលការណ៍ណែនាំខាងលើឱ្យមានប្រសិទ្ធភាព។

ឆ្លើយតបនឹងការលើកឡើងនេះ រដ្ឋបាលខេត្តខ្លះបានឱ្យមន្ទីររៀបចំដែនដី នគរូបនីយ កម្ម សំណង់ និងសុរិយដីជាអ្នកបំភ្លឺ ហើយមន្ទីរបានបំភ្លឺថា មន្ទីរនឹងខិតខំអនុវត្តកែលម្អនូវ ចំណុចខ្វះខាតនេះ នៅឆ្នាំបន្តបន្ទាប់នាពេលខាងមុខ ដោយពង្រឹងយន្តការការងារតាមរយៈ មន្ត្រីជួរក្រោយរបស់មន្ទីរដែលប្រចាំការនៅច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្ត។ ជាមួយនេះ រដ្ឋបាលខេត្តក៏បានទទួលយកអនុសាសន៍សវនកម្ម ដោយសន្យាថានឹងជំរុញឱ្យមន្ទីររៀបចំ ដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខិតខំអនុវត្តតាមខ្លឹមសារនៃប្រកាសអន្តរក្រសួង ខាងលើ។

### ៣.២.៥.ការគ្រប់គ្រងស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈនៅមានកម្រិត

ប្រកាសលេខ១០៥ រថ.បវប.ប្រក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងរ៉ែ និងថាមពល ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ ត្រង់ជំពូកទី២ ប្រការ៣ បានបញ្ជាក់ថា គ្មានបុគ្គលណាម្នាក់ដែលអាចបង្កើត និងដំណើរការស្ថានីយឧស្ម័នឥន្ធនៈដោយគ្មានលិខិតបញ្ជាក់បច្ចេកទេសសុវត្ថិភាពនៃការបង្កើតស្ថានីយឧស្ម័នឥន្ធនៈ ឬស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈពីក្រសួងរ៉ែ និងថាមពល និងវិញ្ញាបនបត្រអនុញ្ញាតដំណើរការឧស្ម័នឥន្ធនៈ ឬស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈពីក្រសួងរ៉ែ និងថាមពល។

តាមការធ្វើសវនកម្មនៅមន្ទីររ៉ែ និងថាមពលនៃខេត្តចំនួន០៧ ឃើញថា ការគ្រប់គ្រងស្ថានីយលក់ប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈរបស់មន្ទីរនៅមិនទាន់បានល្អនៅឡើយ ដោយស្ថានីយមួយចំនួន ដែលកំពុងធ្វើអាជីវកម្មលក់ប្រេងឥន្ធនៈ និងហ្គាស ពុំបានស្នើសុំលិខិតអនុញ្ញាតឱ្យដំណើរការ និងវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព ដូចមានបង្ហាញខាងក្រោម៖

១. ខេត្តតាកែវ មានស្ថានីយប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈសរុបចំនួន២៩២ ក្នុងនោះមានវិញ្ញាបនបត្រអនុញ្ញាតដំណើរការតែចំនួន៥៤។
២. ខេត្តកំពង់ចាម មានស្ថានីយប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈសរុបចំនួន២៥០ ក្នុងនោះមានវិញ្ញាបនបត្រអនុញ្ញាតដំណើរការតែចំនួន៣៣ និងមានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពតែចំនួន១១។
៣. ខេត្តក្រចេះ មានស្ថានីយប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈសរុបចំនួន៨៨ ក្នុងនោះពុំមានលិខិតអនុញ្ញាតដំណើរការស្ថានីយចំនួន១៣ទីតាំង។
៤. ខេត្តកំពត មានស្ថានីប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈសរុបចំនួន៣០៨ ក្នុងនោះពុំទាន់មានវិញ្ញាបនបត្រអនុញ្ញាតដំណើរការ និងវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពចំនួន១០២។
៥. ខេត្តសៀមរាប មានស្ថានីយប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈសរុបចំនួន២៧០ ក្នុងនោះមានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព និងលិខិតអនុញ្ញាតដំណើរការស្ថានីយចំនួន១៩៤។
៦. ខេត្តឧត្តរមានជ័យ មានស្ថានីយប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈសរុបចំនួន១២៥ ក្នុងនោះមានវិញ្ញាបនបត្រអនុញ្ញាតដំណើរការតែចំនួន៤៤ និងមានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពតែចំនួន០១។
៧. ខេត្តរតនគិរី មានស្ថានីយប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈសរុបចំនួន៨៩ ក្នុងនោះពុំទាន់មានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពចំនួន៥២។

កត្តានេះនាំឱ្យបាត់ចំណូលថវិការដ្ឋ និងអាចនាំឱ្យមានហានិភ័យជាយថាហេតុ។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្តគួរណែនាំ មន្ទីររ៉ែ និងថាមពលឱ្យចាត់វិធានការម៉ឺងម៉ាត់ក្នុងការជំរុញអាជីវករម្ចាស់ស្ថានីយប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈរួសរាន់មកស្នើសុំចុះបញ្ជីឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលា។

ឆ្លើយតបនឹងការលើកឡើងនេះ រដ្ឋបាលខេត្តលើកឡើងថា ក្រោយពីអង្គភាពជំនាញបានចុះផ្សព្វផ្សាយអំពីច្បាប់ និងបទដ្ឋានបច្ចេកទេសរួចមក មានអាជីវករមកដាក់ពាក្យសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការកើនបានចំនួនច្រើន។ ជាមួយនេះ រដ្ឋបាលខេត្តក៏បានទទួលយកនូវអនុសាសន៍សវនកម្ម ដោយសន្យាថានឹងណែនាំដល់មន្ទីរជំនាញអនុវត្តឱ្យបានត្រឹមត្រូវ។

**៣.២.៦.ការបំបែកគម្រោងចំណាយដើម្បីតម្រូវតាមសិទ្ធិសម្រេច**

ប្រកាសលេខ០១០ សហវ.ប្រក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់កម្រិតទឹកប្រាក់សិទ្ធិសម្រេចក្នុងកិច្ចលទ្ធកម្មសាធារណៈ ត្រង់ប្រការ១បានប្រគល់សិទ្ធិសម្រេចទទួលខុសត្រូវលើកិច្ចលទ្ធកម្មសាធារណៈជូនក្រសួង ស្ថាប័ន រាជធានី ខេត្ត សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពថវិកាក្នុងកម្រិតទឹកប្រាក់ធានាចំណាយ ក្រោមទឹកប្រាក់៣០០លាន រៀលសម្រាប់ថវិកាមន្ទីរជំនាញរាជធានី ខេត្ត និងក្រោមទឹកប្រាក់ ៥០០លានរៀល សម្រាប់ថវិការដ្ឋបាលខេត្ត និងសារាចរណែនាំលេខ០០២ សហវ.អលសា ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រង់ចំណុច៤ បានចែងថា "ការរៀបចំផែនការលទ្ធកម្ម ត្រូវធ្វើឡើងដោយចងជាឡូត៍ ឬជាកញ្ចប់លទ្ធកម្មចំពោះមុខសញ្ញាលទ្ធកម្មដែលមានលក្ខណៈបច្ចេកទេសដូចគ្នា ឬប្រហាក់ប្រហែលគ្នាស្របតាមតម្រូវការជាក់ស្តែងរបស់សាមីស្ថាប័នអនុវត្តលទ្ធកម្មនីមួយៗ។ រាល់ការបំបែកគម្រោងលទ្ធកម្មទៅជាគម្រោងតូចៗ ក្នុងគោលបំណងបំពានវិធីសាស្រ្តលទ្ធកម្ម ឬដើម្បីតម្រូវសិទ្ធិសម្រេចរបស់ខ្លួនត្រូវជៀសវាងឱ្យបានដាច់ខាត"។

តាមរយៈការធ្វើសវនកម្មលើឯកសារលទ្ធកម្មសាធារណៈនៅបណ្តាមន្ទីរជំនាញមួយចំនួនជុំវិញខេត្ត និងនៅរដ្ឋបាលខេត្តចំនួន០៤ឃើញថា មានការបំបែកគម្រោងចំណាយតូចៗដើម្បីតម្រូវតាមសិទ្ធិសម្រេច ដូចខាងក្រោម៖

១. រដ្ឋបាលខេត្តតាកែវ មាន០១ករណី សរុបទឹកប្រាក់ ៨៣៦ ៣២៥ ០០០រៀល ការងារសាងសង់អគារការិយាល័យច្រកចេញចូលតែមួយស្រុកគិរីវង់ និងស្រុកព្រៃកប្បាស បានបំបែកចេញជា០២កិច្ចសន្យា។

២. រដ្ឋបាលខេត្តកំពង់ស្ពឺ មាន០១ករណី សរុបទឹកប្រាក់ ១ ៤៧៣ ៩៦០ ០០០ រៀល ការងារបំពាក់បង្គោលភ្លើង បានបំបែកចេញជា០៣កិច្ចសន្យា។

៣. រដ្ឋបាលខេត្តសៀមរាប មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាមាន ០១ករណី សរុបទឹកប្រាក់ ៤៩៨ ៣៥០ ០០០រៀល ការងារជួសជុលអគារស្នាក់នៅ និងចាក់ដីលុបបឹងបំពេញទីធ្លាមណ្ឌលសង្គមកិច្ច បានបំបែកចេញជា០២កិច្ចសន្យា។

៤.រដ្ឋបាលខេត្តរតនគិរី មន្ទីរធនធានទឹក និងឧតុនិយម មាន០១ករណី សរុបទឹកប្រាក់ ៤៩៧ ៨២០ ០០០រៀល ការងារជួសជុលសំណង់បង្ហៀរទឹក បានបំបែកចេញជា០២កិច្ចសន្យា។

កត្តានេះនាំឱ្យចំណាយពេលវេលាច្រើនដងក្នុងការធ្វើលទ្ធកម្ម ព្រមទាំងប៉ះពាល់ដល់ប្រសិទ្ធភាពនៃការអនុវត្តគោលការណ៍លទ្ធកម្មសាធារណៈ។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្ត និងមន្ទីរគួរអនុវត្តតាមគោលការណ៍ណែនាំស្ដីពីលទ្ធកម្មសាធារណៈឱ្យបានត្រឹមត្រូវ។

ឆ្លើយតបនឹងការលើកឡើងនេះ រដ្ឋបាលខេត្តលើកឡើងថា ទទួលយកអនុសាសន៍សវនកម្ម និងជំរុញណែនាំអង្គភាពលទ្ធកម្មអនុវត្តឱ្យបានត្រឹមត្រូវ។

### ៣.២.៧.ការពុំបានប្រមូលផ្ដុំប្រភេទទំនិញបញ្ចូលក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំ

ប្រកាសលេខ៨៥១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្ដីពីការរៀបចំផែនការលទ្ធកម្ម ត្រង់ប្រការ១៩ បានតម្រូវឲ្យអង្គភាពលទ្ធកម្ម/ក្រុមលទ្ធកម្ម ត្រូវប្រមូលផ្ដុំបញ្ចូលក្នុងក្រុមតែមួយហៅថា "ឡូត៍លទ្ធកម្ម" នូវតម្រូវការទំនិញ សំណង់ សេវាកម្ម ដែលស្ថិតក្នុងប្រភេទដូចគ្នា ហើយមានលក្ខណៈដូចគ្នា ឬស្រដៀងគ្នា ឬបម្រើឲ្យការងារតែមួយដូចជា គ្រឿងសង្ហារឹម សម្ភារការិយាល័យ ឬប្រេងឥន្ធនៈសម្រាប់ទំនិញ ឬការងារសាងសង់តូចតាចមួយចំនួនដែលស្ថិតនៅជិតគ្នាៗជាដើមសម្រាប់សំណង់ ។

អាជ្ញាធរសវនកម្មជាតិ សង្កេតឃើញថា អាជ្ញាធរអគ្គិសនីកម្ពុជាបានចំណាយទិញទព្វសម្ភារ និងគ្រឿងសង្ហារឹមមួយចំនួន ដែលពុំមានក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំដូចខាងក្រោម៖

- ចំណាយទិញទព្វសម្ភារៈ សរុបទឹកប្រាក់ចំនួន ១៤ ៩៦៤ ១០០ រៀល
- ចំណាយទិញគ្រឿងសង្ហារឹម សរុបទឹកប្រាក់ចំនួន ៧ ២១៩ ៣៦៥ រៀល។

អាជ្ញាធរអគ្គិសនីកម្ពុជាគួរកត់ត្រាបញ្ចូលតម្រូវការទាំងអស់ក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំដែលត្រូវអនុវត្តកិច្ចលទ្ធកម្មឲ្យស្របតាមប្រកាសខាងលើ។

ឆ្លើយតបចំពោះការលើកឡើងនេះ អាជ្ញាធរអគ្គិសនីកម្ពុជា ទទួលយកអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ នឹងខិតខំកែលម្អអនុសាសន៍ចំពោះការមិនកត់ត្រាបញ្ចូលក្នុងផែនការលទ្ធកម្មលើចំណាយទិញទព្វសម្ភារ ប៉ុន្តែ ចំពោះការចំណាយទិញគ្រឿងសង្ហារឹមចំនួន២មុខខាងលើ ជាការចំណាយដោយចៃដន្យយកមកប្រើជំនួសទព្វសម្ភារៈ ដែលខូចតែប៉ុណ្ណោះ។

### ៣.២.៨.ការផ្ដល់ទម្រង់ពាក្យស្នើសុំសេវារដ្ឋបាលជូនប្រជាពលរដ្ឋ

ក្រសួងមហាផ្ទៃបានចេញប្រកាសលេខ៣៨៧១ ប្រក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត ត្រង់ប្រការ៧ បានចែងថា "អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត មានតួនាទីផ្ដល់សេវា

រដ្ឋបាលជូនប្រជាពលរដ្ឋក្នុងក្របខណ្ឌសមត្ថកិច្ចរបស់រដ្ឋបាលរាជធានី ខេត្ត តាមនីតិវិធីសាមញ្ញប្រកបដោយមនសិការវិជ្ជាជីវៈ តម្លាភាព គណនេយ្យភាព និងភាពអាចជឿទុកចិត្តបាន។ អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត មានភារកិច្ចទទួល ពិនិត្យ និងផ្តល់យោបល់លើសំណុំឯកសារស្នើសុំសេវារដ្ឋបាលរបស់ប្រជាពលរដ្ឋ ព្រមទាំងផ្តល់លទ្ធផលសម្រេចជាផ្លូវការ លើកយោបល់លើការរៀបចំទម្រង់បែបបទ នីតិវិធីលម្អិត និងក្របខណ្ឌពេលវេលាសម្រាប់ផ្តល់សេវារដ្ឋបាលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន...។

តាមការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០២០ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្តកំពង់ធំ នៅពុំទាន់មានទម្រង់ពាក្យស្នើសុំសេវាលើវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ជូនប្រជាពលរដ្ឋសម្រាប់បំពេញពេលមកស្នើសុំសេវារដ្ឋបាលនៅឡើយ ដែលជាហេតុធ្វើឲ្យប្រជាពលរដ្ឋត្រូវទៅស្នើសុំទម្រង់បែបបទនោះនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ធំជាមុនសិន មុននឹងដាក់ពាក្យស្នើសុំសេវារដ្ឋបាលនៅអង្គភាពច្រកចេញចូលតែមួយ។

ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី គួរផ្តល់ទម្រង់ពាក្យស្នើសុំសេវាមកអង្គភាពច្រកចេញចូលតែមួយ។

ឆ្លើយតបនឹងការលើកឡើង រដ្ឋបាលខេត្តកំពង់ធំ សូមឯកភាពតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ និងធ្វើការណែនាំដល់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ដើម្បីផ្តល់ទម្រង់ពាក្យស្នើសុំសេវាមកអង្គភាពច្រកចេញចូលតែមួយ ដើម្បីអនុវត្តឲ្យស្របប្រកាសរបស់ក្រសួងមហាផ្ទៃ។

**៣.២.៩.កិច្ចលទ្ធកម្មសាធារណៈមួយចំនួនពុំមានអនុលោមភាពពីក្រសួងមហាផ្ទៃ**

ក្រសួងមហាផ្ទៃបានចេញសេចក្តីណែនាំលេខ០២៣ សណន ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៧ ស្តីពីការពង្រឹងការអនុវត្តនីតិវិធីនៃការរៀបចំ និងការអនុវត្តគម្រោងរាជធានី ខេត្ត ត្រង់ផ្នែកទី៣ ការដាក់គម្រោងបញ្ចូលក្នុងផែនការថវិកា និងផែនការលទ្ធកម្មប្រចាំ ចំណុច៣.១ បានចែងថា "បន្ទាប់ពីទទួលបានការផ្តល់អនុលោមភាពពីក្រសួងមហាផ្ទៃ រដ្ឋបាលរាជធានី ខេត្ត ត្រូវដាក់បញ្ចូលគម្រោងទាំងអស់ទៅក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ខ្លួន។ បន្ទាប់ពីបានការពារថវិកាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋបាលរាជធានី ខេត្ត ត្រូវដាក់បញ្ចូលគម្រោងទាំងនោះទៅក្នុងសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំរបស់ខ្លួនមុនដំណាច់ខែវិច្ឆិកា រួចបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងអនុម័ត ឲ្យបានមុនថ្ងៃទី៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកា" និងចំណុច៣.២ នៃសេចក្តីណែនាំខាងលើបានចែងថា "រដ្ឋបាលរាជធានី ខេត្ត ត្រូវយកសំណុំឯកសារគម្រោងដែលទទួលបានការផ្តល់អនុលោមភាពពីក្រសួងមហាផ្ទៃ និងផែនការលទ្ធកម្មប្រចាំឆ្នាំដែលអនុម័តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅប្រើប្រាស់ជាមូលដ្ឋានក្នុងការរៀបចំកិច្ចលទ្ធកម្មសាធារណៈ ស្របតាមនីតិវិធីលទ្ធកម្មសាធារណៈជាធរមាន។ រដ្ឋបាលរាជធានី ខេត្ត ត្រូវរួសរាន់អនុវត្តកិច្ចលទ្ធកម្មឲ្យបានទាន់ពេលវេលាស្របតាមកាលបរិច្ឆេទ

ដូចមានចែងក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំរបស់ខ្លួន ដែលបានការអនុម័តពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ចំពោះគម្រោងរាជធានី ខេត្ត ទាំងឡាយណាដែលមិនបានទទួលការផ្តល់អនុលោមភាពពីក្រសួងមហាផ្ទៃ និងមិនមាននៅក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំដែលបានអនុម័តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គម្រោងទាំងនោះមិនអាចអនុវត្តកិច្ចលទ្ធកម្មបានឡើយ"។

តាមការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០២០ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រដ្ឋបាលខេត្តកំពង់ធំ បានអនុវត្តកិច្ចលទ្ធកម្មសាធារណៈសរុបចំនួន២៥គម្រោង សរុបទឹកចំនួន ២២ ០៩០ ៦០០ ០០០រៀល ដែលក្នុងនោះគម្រោងចំនួន ០៦ មានអនុលោមភាព ប៉ុន្តែមានគម្រោងចំនួន១៩ទៀត ពុំមានអនុលោមភាពពីក្រសួងមហាផ្ទៃឡើយ។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្តកំពង់ធំ គួរធ្វើការស្នើសុំអនុលោមភាពគ្រប់គម្រោងទាំងអស់ពីក្រសួងមហាផ្ទៃ។

ឆ្លើយតបនឹងការលើកឡើង រដ្ឋបាលខេត្តកំពង់ធំ សូមឯកភាពតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ និងធ្វើការស្នើសុំអនុលោមភាពគ្រប់គម្រោងទាំងអស់ពីក្រសួងមហាផ្ទៃឲ្យស្របតាមសេចក្តីណែនាំ។

### ៣.២.១០.ភាពយឺតយ៉ាវក្នុងធ្វើប្លង់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញលិខិតលេខ ៣៨៤៤ សហវ.ទរ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការរំលឹកការធ្វើប្លង់កម្មសិទ្ធិដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់បណ្តាក្រសួង ស្ថាប័ន និងខេត្ត ក្រុង ដោយធ្វើការក្រើនរំលឹកដល់គ្រប់ក្រសួង ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន ព្រមទាំងបណ្តាមន្ទីរ និងសាលាខេត្ត ក្រុងទាំងអស់ត្រូវរៀបចំធ្វើប្លង់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ ដែលខ្លួនកំពុងកាន់កាប់ឱ្យបានឆាប់រហ័ស ដោយរួមសហការជាមួយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី គ្រប់ខេត្ត ក្រុងទាំងអស់។

តាមរយៈការធ្វើសវនកម្មនៅរដ្ឋបាលខេត្តចំនួន១៥ និងមន្ទីរជំនាញមួយចំនួន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រដ្ឋបាលខេត្ត និងមន្ទីរ ពុំទាន់មានប្លង់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ ដូចមានខាងក្រោមៈ

| ល.រ | ឈ្មោះខេត្ត | ចំនួនទីតាំងមិនទាន់មានប្លង់កម្មសិទ្ធិ | ផ្សេងៗ |
|---|---|---|---|
| ១ | ខេត្តតាកែវ | ២៥៤ | |
| ២ | ខេត្តបាត់ដំបង | ២១ | |
| ៣ | ខេត្តកំពង់ស្ពឺ | ៤៣៣ | |
| ៤ | ខេត្តកំបង់ចាម | ១១ | |
| ៥ | ខេត្តស្វាយរៀង | ១៤៦ | |
| ៦ | ខេត្តព្រះសីហនុ | ៩០ | |

| ល.រ | ឈ្មោះខេត្ត | ចំនួនទីតាំងមិនទាន់មានប្លង់កម្មសិទ្ធិ | ផ្សេងៗ |
| --- | --- | --- | --- |
| ៧ | ខេត្តកោះកុង | ៣៥ | |
| ៨ | ខេត្តក្រចេះ | ៣៥៤ | |
| ៩ | ខេត្តកំពត | ២១០ | |
| ១០ | ខេត្តសៀមរាប | ១៤ | |
| ១១ | ខេត្តបន្ទាយមានជ័យ | ៣៥ | |
| ១២ | ខេត្តពោធិ៍សាត់ | ២៦៩ | |
| ១៣ | ខេត្តព្រៃវែង | ៦០៨ | |
| ១៤ | ខេត្តឧត្តរមានជ័យ | ២៤០ | |
| ១៥ | ខេត្តរតនគិរី | ២៦ | |

ដោយសារភាពយឺតយ៉ាវក្នុងការធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់កម្មសិទ្ធិដីធ្លីរបស់រដ្ឋ និងការគ្រប់គ្រងដីរដ្ឋពុំបានល្អ អាចបណ្ដាលឱ្យកើតមាននូវការរំលោភបំពានណាមួយពីមជ្ឈដ្ឋានខាងក្រៅ និងអាចឈានដល់ការបាត់បង់ដីរដ្ឋជាយថាហេតុ។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្ត មន្ទីរ និងអង្គភាពជុំវិញខេត្ត គួររួសរាន់ធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនទ្រព្យរបស់រដ្ឋឱ្យបានឆាប់រហ័ស។

ឆ្លើយតបនឹងការលើកឡើងនេះ រដ្ឋបាលខេត្តបានឯកភាពដោយសន្យាថា នឹងជំរុញបន្ថែមដល់អង្គភាពក្រោមឱវាទ មន្ទីរ អង្គភាពកាន់កាប់ និងប្រើប្រាស់ដីរដ្ឋឱ្យអនុវត្តតាមអនុសាសន៍សវនកម្ម។ រដ្ឋបាលខេត្តខ្លះទៀតថា បានណែនាំដល់បណ្ដាអង្គភាពរួចហើយ ដីខ្លះកំពុងដំណើរការធ្វើប្លង់ ដីខ្លះមិនអាចធ្វើប្លង់បានដោយសារពាក់ព័ន្ធទំនាស់ ទីតាំងដីខ្លះទៀតរង់ចាំការចុះបញ្ជីដីជាប្រព័ន្ធ។

## ៤. ការពិនិត្យទៅលើវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍សវនកម្ម

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០២០ នាពេលកន្លងមក អាជ្ញាធរសវនកម្មជាតិកត់សម្គាល់ឃើញថា ចំណុចខ្វះខាត និងអនុសាសន៍សវនកម្មមួយចំនួន ដែលអាជ្ញាធរសវនកម្មជាតិបានលើកឡើង ត្រូវបានក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានាខិតខំអនុវត្តកែលម្អគួរឱ្យកត់សម្គាល់ និងកោតសរសើរ រីឯចំណុចមួយចំនួនទៀតនៅតែបន្តកើតមាននៅឡើយ ជាអាទិ៍ ៖

### ៤.១.ភាពយឺតយ៉ាវក្នុងការព្យួរទុកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម

ដើម្បីទប់ស្កាត់ការគេចវេះពន្ធ ឬការប្រកាសពន្ធមិនត្រឹមត្រូវ ជាពិសេសចំពោះអាជីវកម្មនាំចេញ និងនាំចូលទំនិញ អគ្គនាយកដ្ឋានពន្ធដារមានសិទ្ធិព្យួរទុក ឬដកហូតមកវិញនូវវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែមគំរូថ្មី ប្រសិនបើសហគ្រាស ក្រុមហ៊ុនណាមួយមិនបានប្រកាសនូវការផ្គត់ផ្គង់ជាប់អាករក្នុងរយៈពេល៣ខែជាប់គ្នា។

តាមការពិនិត្យស្ថិតិក្រុមហ៊ុនសហគ្រាសអ្នកជាប់ពន្ធមធ្យមក្នុងឆ្នាំ២០២០ របស់សាខាពន្ធដារខណ្ឌចំនួន០៩ និងខេត្តចំនួន១៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានក្រុមហ៊ុនសហគ្រាសចំនួន ៧ ៦១៧ ដែលបានដាក់លិខិតប្រកាសពន្ធប្រចាំខែសូន្យ (គ្មានសកម្មភាព) ក្នុងនោះសាខាពន្ធដារខេត្តខណ្ឌបានព្យួរទុកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែមរបស់ក្រុមហ៊ុនសហគ្រាសចំនួន ៨៧៤ ប៉ុន្តែនៅសល់ក្រុមហ៊ុនសហគ្រាសចំនួន ៥ ៤៧១ មិនទាន់ត្រូវបានព្យួរទុកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម។

ដោយសារការព្យួរទុកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែមមិនទាន់បានគត់មត់ អគ្គនាយកដ្ឋានពន្ធដារអាចនឹងជួបការលំបាកក្នុងការទប់ស្កាត់ការគេចវេះពន្ធ ឬការប្រកាសពន្ធមិនត្រឹមត្រូវ និងទាន់ពេលវេលា។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំអគ្គនាយកដ្ឋានពន្ធដារឱ្យព្យួរទុកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែមឱ្យបានទាន់ពេលវេលា។

ជាវិធានការ អគ្គនាយកដ្ឋានពន្ធដារនឹងបន្តណែនាំសាខាពន្ធដារខេត្ត-ខណ្ឌពាក់ព័ន្ធធ្វើការព្យួរទុក ឬដកហូតមកវិញនូវវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែមរបស់ក្រុមហ៊ុនសហគ្រាសណាមិនបានប្រកាសនូវការផ្គត់ផ្គង់ជាប់អាករ ក្នុងរយៈពេល ៣ខែជាប់គ្នា។ ប៉ុន្តែ អគ្គនាយកដ្ឋានពន្ធដារស្នើសុំឱ្យមានការចូលរួមសហការពីក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធនឹងការចេញអាជ្ញាប័ណ្ណដើម្បីព្យួរទុក ឬមិនបន្តសុពលភាពអាជ្ញាប័ណ្ណប្រកបអាជីវកម្មដល់សហគ្រាសទាំងឡាយណាដែលអគ្គនាយកដ្ឋានពន្ធដារបានព្យួរវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម។ ដោយឡែក អគ្គនាយកដ្ឋានពន្ធដារ បានស្នើសុំការសហការជាមួយ CamDX ដើម្បីទប់ស្កាត់បញ្ហាខាងលើនេះរួចរាល់ហើយ។

### ៤.២.ក្រុមហ៊ុនសហគ្រាសមួយចំនួនមិនបានមកធ្វើបច្ចុប្បន្នភាព

ដើម្បីគ្រប់គ្រងទិន្នន័យអ្នកជាប់ពន្ធ ផ្តល់សេវាជូនអ្នកជាប់ពន្ធ និងប្រមូលពន្ធឱ្យកាន់តែមានប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានតម្រូវឱ្យអ្នកជាប់ពន្ធ ដែលមានការផ្លាស់ប្តូរព័ត៌មានដូចជា អាសយដ្ឋាន ទ្រង់ទ្រាយ នាមករណ៍ កម្មវត្ថុអាជីវកម្ម ឬសកម្មភាពអាជីវកម្ម ការផ្ទេរ ឬផ្លាស់

ប្តូរម្ចាស់ភាគហ៊ុន សមាសភាពអ្នកគ្រប់គ្រងសហគ្រាស ឬសាខា ការបញ្ឈប់អាជីវកម្ម អ្នកទទួលបន្ទុកកិច្ចការពន្ធដារ ព័ត៌មានគណនីធនាគារ ព័ត៌មានទំនាក់ទំនង លេខទូរស័ព្ទ សារអេឡិចត្រូនិក និងអ្នកជាប់ពន្ធដែលចុះបញ្ជីពន្ធដារមុនថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៤ មានកាតព្វកិច្ចជូនដំណឹងមករដ្ឋបាលសារពើពន្ធក្នុងកំឡុងពេល១៥ថ្ងៃនៃថ្ងៃធ្វើការ។ តាមការពិនិត្យស្ថិតិសហគ្រាសមិនទាន់ធ្វើបច្ចុប្បន្នភាពគិតត្រឹមខែធ្នូ ឆ្នាំ២០២០ របស់សាខាពន្ធដារខណ្ឌចំនួន០៩ និងខេត្តចំនួន១៤ ដោយមិនរាប់បញ្ចូលអង្គការ និងស្ថាប័នរដ្ឋ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នៅមានក្រុមហ៊ុនសហគ្រាសចំនួន៥៤៦ មិនទាន់បានធ្វើបច្ចុប្បន្នភាពនៅឡើយ។

កត្តានេះ អាចនាំឱ្យព័ត៌មានរបស់ក្រុមហ៊ុនសហគ្រាសមិនទាន់ប្រាកដប្រជានៅឡើយ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំអគ្គនាយកដ្ឋានពន្ធដារឱ្យមានវិធានការពង្រឹងបន្ថែមទៀតឱ្យស្របតាមប្រកាសលេខ៧០១ សហវ.ប្រក ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ ស្តីពីការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ។

ជាវិធានការ អគ្គនាយកដ្ឋានពន្ធដារនឹងបន្តខិតខំធ្វើការផ្សព្វផ្សាយប្រកាសលេខ៧០១ សហវ.ប្រក ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ ត្រង់ចំណុចកាតព្វកិច្ចធ្វើបច្ចុប្បន្នភាពជូនសហគ្រាសឱ្យបានកាន់តែទូលំទូលាយ។ អគ្គនាយកដ្ឋានពន្ធដារនឹងបន្តខិតខំកែលម្អលើចំណុចខ្វះខាតនេះឱ្យបានល្អប្រសើរនៅឆ្នាំបន្តបន្ទាប់។

**៤.៣.ការផ្ទេរក្រុមហ៊ុនសហគ្រាសពីអ្នកជាប់ពន្ធតូចទៅអ្នកជាប់ពន្ធមធ្យម**

ប្រកាសលេខ០២៥ សហវ.ប្រក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រង់ប្រការ៤ បានចែងថា "ការធ្វើចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវបែងចែកជាបីប្រភេទ៖ អ្នកជាប់ពន្ធតូច គឺជាសហគ្រាសឯកបុគ្គល ឬសហគ្រាសសហកម្មសិទ្ធិដែលមានផលរបរប្រចាំឆ្នាំចាប់ពី២៥០លានរៀល ដល់ ៧០០លានរៀល ឬមានផលរបរក្នុងរយៈពេលបីខែជាប់គ្នាណាមួយ ដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្ត... អ្នកជាប់ពន្ធមធ្យមគឺជាសហគ្រាសដែលមានផលរបរប្រចាំឆ្នាំលើសពី ៧០០លានរៀល ដល់ ៤ ០០០លានរៀល..."។

តាមការពិនិត្យលិខិតប្រកាសពន្ធប្រចាំខែរបស់អ្នកជាប់ពន្ធតូចចំនួន១៦៣ នៅសាខាពន្ធដារខណ្ឌ០៩ និងខេត្ត១៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានក្រុមហ៊ុនសហគ្រាសមួយចំនួនតូចបានប្រកាសផលរបរលើសពី៧០០លានរៀល ក្នុងឆ្នាំ២០២០ ប៉ុន្តែសាខាពន្ធដារខណ្ឌ ខេត្តទាំងនោះមិនទាន់បានចាត់វិធានការផ្ទេរសហគ្រាសទាំងនោះទៅអ្នកជាប់ពន្ធមធ្យមនៅឡើយ។

ការយឺតយ៉ាវនេះក៏ដោយសារអ្នកជាប់ពន្ធតូចមួយចំនួនមិនបានបង្កលក្ខណៈងាយស្រួលដល់អង្គភាពពន្ធដារ ដើម្បីធ្វើការចុះបញ្ជីពន្ធដារនោះទេ ដោយហេតុថា អ្នកជាប់ពន្ធមួយចំនួនមានបំណងចង់គេចវេះពីការធ្វើសវនកម្ម និងការកាន់កាប់បញ្ជីគណនេយ្យ។ ជាវិធានការ អគ្គនាយកដ្ឋានពន្ធដារនឹងណែនាំសាខាពន្ធដារខេត្ត-ខណ្ឌពាក់ព័ន្ធ ត្រូវបន្តពង្រឹងការផ្ទេរសហគ្រាសអ្នកជាប់

ពន្ធតូច ទៅអ្នកជាប់ពន្ធមធ្យម ដើម្បីឱ្យស្របតាមប្រកាសណែនាំស្តីពីការកែសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស។

**៤.៤.ការប្រមូលពន្ធប៉ាតង់ពុំទាន់បានពេញលេញ**

ប្រកាសលេខ ១៩៨ សហវ.ប្រក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការកែសម្រួលវិធាន និងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់ ត្រង់ប្រការ៥ ចំណុច៤ បានតម្រូវឱ្យអ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្មនៅក្នុងរាជធានី ខេត្តផ្សេងគ្នាត្រូវបង់ពន្ធប៉ាតង់ទៅតាមរាជធានី ខេត្តដែលអាជីវកម្មនោះស្ថិតនៅ និងត្រង់ប្រការ៧ បានចែងថា ពន្ធប៉ាតង់ត្រូវបង់ក្នុងអំឡុងពេលចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំ។

តាមការធ្វើតេស្តអ្នកជាប់ពន្ធចំនួន៣ ៧៦៣ នៅតាមបណ្តាសាខាពន្ធដារខណ្ឌចំនួន៩ និងខេត្តចំនួន១៤ ដែលបានធ្វើការប្រកាសបង់ពន្ធក្នុងឆ្នាំ២០២០ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថាមានអ្នកជាប់ពន្ធចំនួន១ ១០០ មិនទាន់បានបង់ពន្ធប៉ាតង់ឆ្នាំ២០២០នៅឡើយ។

ជាវិធានការ អគ្គនាយកដ្ឋានពន្ធដារនឹងបន្តខិតខំជំរុញ និងណែនាំដល់សាខាក្រុមហ៊ុនដែលនៅពុំទាន់បានបង់ពន្ធប៉ាតង់ឱ្យមកបង់ពន្ធប៉ាតង់ឱ្យបានគ្រប់ចំនួន និងពង្រឹងការផាកពិន័យទៅតាមច្បាប់ជាធរមាន។

**៤.៥.ការប្រមូលព័ត៌មានសហគ្រាសមួយចំនួនដែលបានចុះបញ្ជីតាមក្រសួង ស្ថាប័ន**

ដើម្បីគ្រប់គ្រងការប្រមូលពន្ធឱ្យកាន់តែមានប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញលិខិតបទដ្ឋាន និងនីតិវិធីទាក់ទងទៅនឹងការប្រមូលព័ត៌មានអ្នកជាប់ពន្ធ។ អគ្គនាយកដ្ឋានពន្ធដារបានបង្កើតក្រុមការងារមួយចំនួន និងបានសហការធ្វើការងារជាមួយក្រសួងពាណិជ្ជកម្ម អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងមួយចំនួនក៏បានផ្តល់ព័ត៌មានដល់អគ្គនាយកដ្ឋានពន្ធដារផងដែរ។ ប៉ុន្តែអគ្គនាយកដ្ឋានពន្ធដារក៏ពុំទាន់បានប្រមូលព័ត៌មានសហគ្រាសនៅតាមបណ្តាក្រសួង ស្ថាប័នមួយចំនួនផ្សេងទៀតឱ្យបានពេញលេញ និងទាន់ពេលវេលានៅឡើយ។

ជាវិធានការ អគ្គនាយកដ្ឋានពន្ធដារនឹងបន្តស្នើសុំកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យផ្តល់ព័ត៌មានអ្នកជាប់ពន្ធឱ្យបានពេញលេញ និងទាន់ពេលវេលា ក្នុងន័យនេះ អគ្គនាយកដ្ឋានពន្ធដារ ស្នើសុំអាជ្ញាធរសវនកម្មជាតិជួយជំរុញក្រសួងស្ថាប័នពាក់ព័ន្ធសហការផ្តល់ព័ត៌មានពេញលេញទាន់ពេលវេលា មកអគ្គនាយកដ្ឋានពន្ធដារផងដែរ។

**៤.៦.ការកាន់កាប់កិច្ចបញ្ជិកាគណនេយ្យរបស់អ្នកជាប់ពន្ធ**

ច្បាប់ស្តីពីសារពើពន្ធដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ត្រង់ផ្នែកទី៣ រដ្ឋបាលសារពើពន្ធ មាត្រា៩៨ បានចែងថា "អ្នកជាប់ពន្ធត្រូវកាន់កាប់ កត់ត្រា និងថែរក្សាបញ្ជី លិខិតយុត្តិការ និងឯកសារហិរញ្ញវត្ថុផ្សេងៗ ដូចដែលបទ

ប្បញ្ញត្តិស្តីពីពន្ធដារបានកំណត់...˝ និងត្រង់មាត្រា១១៦ ចំណុច៣ បានចែងថា "ក្នុងករណីដែលអ្នកជាប់ពន្ធមិនបានរក្សាទុកឱ្យបានត្រឹមត្រូវនូវបញ្ជីគណនេយ្យ ឬមិនបានផ្តល់ព័ត៌មានចាំបាច់ជូនរដ្ឋបាលសារពើពន្ធនោះ អ្នកជាប់ពន្ធត្រូវរងនូវការកំណត់ពន្ធជាឯកតោភាគីពីរដ្ឋបាលសារពើពន្ធ...˝។

តាមការពិនិត្យសំណុំឯកសារសវនកម្មនៃការកំណត់ពន្ធឡើងវិញរបស់នាយកដ្ឋានសវនកម្មសហគ្រាសនៃអគ្គនាយកដ្ឋានពន្ធដារលើអ្នកជាប់ពន្ធចំនួន៦០ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អ្នកជាប់ពន្ធចំនួន២៩ (ក្រុមហ៊ុនសហគ្រាសស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំចំនួន១០ និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់សាខាពន្ធដារខេត្តខណ្ឌចំនួន១៩) ពុំទាន់បានកាន់កាប់ កត់ត្រា និងថែរក្សាទុកកិច្ចបញ្ជិកាគណនេយ្យ និងលិខិតយុត្តិការឱ្យបានត្រឹមត្រូវស្របតាមច្បាប់ស្តីពីសារពើពន្ធនៅឡើយ។

ជាវិធានការ អគ្គនាយកដ្ឋានពន្ធដារនឹងបន្តធ្វើការអប់រំ ផ្សព្វផ្សាយ និងណែនាំដល់អ្នកជាប់ពន្ធទាំងអស់តាមរយៈការធ្វើសិក្ខាសាលា ដើម្បីជំរុញការអប់រំអ្នកជាប់ពន្ធ ឱ្យមានការយល់ដឹងឱ្យបានច្បាស់លាស់អំពីកាតព្វកិច្ចសារពើពន្ធ ការអនុវត្តច្បាប់ពន្ធដារ ការកាន់កាប់បញ្ជិកាគណនេយ្យឱ្យបានត្រឹមត្រូវ និងចាត់វិធានការពិន័យតាមច្បាប់ស្តីពីសារពើពន្ធជាធរមាន។

**៤.៧.ក្រុមហ៊ុនសហគ្រាសមួយចំនួនពុំទាន់បានបំពេញកាតព្វកិច្ចសារពើពន្ធ**

ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់សារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ត្រង់មាត្រា១០៤ថ្មី ចំណុច១ បានចែងថា "អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវដាក់លិខិតប្រកាសសារពើពន្ធទៅតាមទម្រង់ ពេលវេលា និងទីកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់˝។ ច្បាប់ស្តីពីសារពើពន្ធដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ត្រង់មាត្រា១២៨ អំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ចំណុច១ ចែងថា "ករណីដែលបុគ្គលមិនបានដាក់លិខិតប្រកាសសារពើពន្ធដែលគ្មានប្រាក់ពន្ធត្រូវបង់ក្នុងរយៈពេល៣០ថ្ងៃ ក្រោយកាលបរិច្ឆេទដែលច្បាប់កំណត់˝ និងមាត្រា១២៩ បទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារបានចែងថា "ក្រៅពីទោសទណ្ឌផ្នែករដ្ឋបាលផ្សេងទៀត បុគ្គលណាមួយបានធ្វើសកម្មភាពគេចវេះពន្ធ ឬធ្វើការរាំងស្ទះដល់ការគ្រប់គ្រងប្រព័ន្ធសារពើពន្ធដូចមានចែងក្នុងមាត្រា១២៨នៃច្បាប់ខាងលើ ត្រូវបានចាត់ទុកថាបានប្រព្រឹត្តបទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ˝។

តាមការពិនិត្យរបាយការណ៍ស្តីពីការគ្រប់គ្រង និងប្រមូលចំណូលពន្ធសម្រាប់ខែធ្នូ ឆ្នាំ២០២០ នៅសាខាពន្ធដារខណ្ឌចំនួន០៩ និងខេត្តចំនួន១៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រុមហ៊ុនសហគ្រាសចំនួន៣៤ ០៤៦ (អ្នកជាប់ពន្ធមធ្យមចំនួន២៣ ០៦៥ អ្នកជាប់ពន្ធតូចចំនួន១០ ៩៨១) ក្នុងចំណោមសហគ្រាសត្រូវដាក់លិខិតប្រកាសសរុបចំនួន៧២ ៣៧២ មិនបានមកដាក់លិខិតប្រកាសពន្ធប្រចាំខែក្នុងឆ្នាំ២០២០។

ជាវិធានការ អគ្គនាយកដ្ឋានពន្ធដារនឹងបន្តខិតខំបន្ថែមទៀតនូវការផ្សព្វផ្សាយកាតព្វកិច្ចសារពើពន្ធ តាមរយៈការធ្វើសិក្ខាសាលាដល់អ្នកជាប់ពន្ធ ឱ្យមានការយល់ដឹងកាន់តែច្បាស់លាស់ និងចាត់វិធានការពិន័យតាមច្បាប់ជាធរមាន។

**៤.៨.របាយការណ៍សវនកម្មរបស់សវនករឯករាជ្យ**

សហគ្រាសវិនិយោគទាំងឡាយ ដែលបានធ្វើសកម្មភាពអាជីវកម្ម មានកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំការិយបរិច្ឆេទនីមួយៗរបស់ខ្លួនជូនសវនករឯករាជ្យសម្រាប់ធ្វើសវនកម្មស្របទៅតាមច្បាប់ដែលបានកំណត់ចំពោះសហគ្រាសដែលមានលក្ខណៈវិនិច្ឆ័យពីរក្នុងចំណោមលក្ខណៈវិនិច្ឆ័យបីគឺ (១) ផលរបរប្រចាំឆ្នាំរបស់សហគ្រាសមានចំនួនចាប់ពីបួនពាន់លានរៀលឡើងទៅ (២) ទ្រព្យសកម្មសរុបមានតម្លៃចាប់ពីបីពាន់លានរៀលឡើងទៅ (៣) និយោជិកបម្រើការងារមានចំនួនចាប់ពីមួយរយនាក់ឡើងទៅ និងរាល់គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយបានចុះឈ្មោះនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ពោលគឺសហគ្រាសដែលមានលក្ខណៈវិនិច្ឆ័យដូចនេះត្រូវមានរបាយការណ៍សវនកម្មរបស់សវនករឯករាជ្យ។

តាមការពិនិត្យសំណុំឯកសារសវនកម្មពេញលេញនៅនាយកដ្ឋានសវនកម្មសហគ្រាសអាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រុមហ៊ុនចំនួន៣៤ មានកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំការិយបរិច្ឆេទនីមួយៗរបស់ខ្លួនឱ្យសវនករឯករាជ្យធ្វើសវនកម្ម ក្នុងនោះមានក្រុមហ៊ុនចំនួន០៣ បានដាក់របាយការណ៍សវនកម្មពីសវនករឯករាជ្យ ប៉ុន្តែក្រុមហ៊ុនចំនួន៣១មិនបានដាក់របាយការណ៍សវនកម្មពីសវនករឯករាជ្យនៅឡើយ។

ជាវិធានការ អគ្គនាយកដ្ឋានពន្ធដារនឹងបន្តពង្រឹងបន្ថែមទៀតចំពោះក្រុមហ៊ុន សហគ្រាសដែលពុំទាន់មានរបាយការណ៍សវនកម្មពីសវនករឯករាជ្យដោយសហការជាមួយនិយ័តករគណនេយ្យ និងសវនកម្ម។

**៤.៩.ការប្រើប្រាស់វិក្កយបត្រ**

តាមច្បាប់ស្តីពីសារពើពន្ធគឺតម្រូវឱ្យមានការប្រើប្រាស់ ឬចេញវិក្កយបត្រចំពោះរាល់កិច្ចការជំនួញរវាងអ្នកជាប់ពន្ធ និងបុគ្គលដទៃទៀត។ ចំពោះវិក្កយបត្រអាករលើតម្លៃបន្ថែម គឺត្រូវមានចុះលេខរៀងត្រឹមត្រូវឱ្យទៅអ្នកទិញ និងត្រូវមានចុះនិទ្ទេស ដូចជា ឈ្មោះ និងលេខចុះបញ្ជីរបស់អ្នកលក់ កាលបរិច្ឆេទចេញវិក្កយបត្រ ឈ្មោះអ្នកទិញ ឬនិយោជិក ឬភ្នាក់ងារអ្នកទិញ បរិមាណ សេចក្តីបរិយាយ និងថ្លៃលក់ទំនិញ ឬសេវា។ ជាងនេះទៅទៀត វិក្កយបត្រសម្រាប់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវមានអាសយដ្ឋាន លេខអត្តសញ្ញាណកម្ម "អតប" លេខវិក្កយបត្រ ថ្ងៃខែឆ្នាំចេញវិក្កយបត្រ រាយមុខទំនិញ ឬសេវា បរិមាណ ថ្លៃឯកតា ថ្លៃសរុប គោត្តនាម និងនាមអ្នកចេញវិក្កយបត្រ...។

តាមការធ្វើតេស្តលើលិខិតប្រកាសពន្ធ និងឯកសារភ្ជាប់ផ្សេងៗរបស់ក្រុមហ៊ុនសហគ្រាសមួយចំនួន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០២០ ក្រុមហ៊ុនសហគ្រាសមួយចំនួនបាន

ប្រើប្រាស់ និងចេញវិក្កយបត្រពុំទាន់បានត្រឹមត្រូវតាមការណែនាំទៅឱ្យអតិថិជនរបស់ខ្លួន ដូចជា វិក្កយបត្រគ្មានលេខអត្តសញ្ញាណកម្ម "អតប" គ្មានលេខវិក្កយបត្រ គ្មានគោត្តនាម និងនាមអ្នកចេញវិក្កយបត្រ...។

ជាវិធានការ អគ្គនាយកដ្ឋានពន្ធដារ និងបន្តធ្វើការអប់រំ ផ្សព្វផ្សាយ និងណែនាំដល់អ្នកជាប់ពន្ធពីការប្រើប្រាស់វិក្កយបត្រឱ្យបានសមស្រប និងចាត់វិធានការតាមច្បាប់ជាធរមានចំពោះអ្នកជាប់ពន្ធដែលមិនបានប្រើប្រាស់វិក្កយបត្រ ឬប្រើប្រាស់វិក្កយបត្រពុំស្របទៅតាមវិធានវិក្កយបត្រឱ្យបានត្រឹមត្រូវ។

**៤.១០.ការត្រួតពិនិត្យលើលិខិតប្រកាសពន្ធ**

ការដាក់លិខិតប្រកាសពន្ធអាករប្រចាំខែ ប្រចាំឆ្នាំនៅរដ្ឋបាលសារពើពន្ធត្រូវធ្វើឡើងដោយភាពត្រឹមត្រូវ និងច្បាស់លាស់ ហើយបណ្ណាធិការសហគ្រាសជាអ្នកទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ ប្រសិនបើព័ត៌មានណាមួយមានការក្លែងបន្លំ រីឯការត្រួតពិនិត្យលិខិតប្រកាសពន្ធជាភារកិច្ចរបស់មន្ត្រីពន្ធ។

តាមការធ្វើតេស្តលើលិខិតប្រកាសពន្ធប្រចាំខែ និងលិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំរបស់ក្រុមហ៊ុនចំនួន៦១១ (លិខិតប្រកាសពន្ធធំចំនួន៦៧ ពន្ធមធ្យមចំនួន៣២២ និងពន្ធតូច២២២) នៅនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និងសាខាពន្ធដារខេត្ត ខណ្ឌចំនួន២២ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ដោយសារកត្តាមួយចំនួនដូចជា៖ កង្វះមន្ត្រី មន្ត្រីចាត់ចែងលិខិតប្រកាសត្រូវរៀបចំឯកសារទុតិយតាផ្ញើជូនអគ្គនាយកដ្ឋានពន្ធដារ អ្នកជាប់ពន្ធមកដាក់លិខិតប្រកាសពន្ធនៅចុងកាលបរិច្ឆេទកំណត់។ ដូចនេះធ្វើឱ្យមន្ត្រីចាត់ចែងលិខិតប្រកាសពុំមានពេលវេលាគ្រប់គ្រាន់ក្នុងការត្រួតពិនិត្យលើភាពត្រឹមត្រូវនៃលិខិតប្រកាសសារពើពន្ធដើម្បីធានាថា លិខិតប្រកាសត្រូវបានបំពេញគ្រប់ខ្ទង់ គ្រប់និទ្ទេស និងភាពមិនប្រក្រតីនៃលិខិតប្រកាសនោះទេ។ ជាលទ្ធផលនៃកត្តាខាងលើ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា លិខិតប្រកាសពន្ធប្រចាំខែរបស់ក្រុមហ៊ុនចំនួន១៦៧ (អ្នកជាប់ពន្ធធំចំនួន០៥ អ្នកជាប់ពន្ធមធ្យមចំនួន៩០ និងអ្នកជាប់ពន្ធតូចចំនួន៧២) ក្នុងចំណោមក្រុមហ៊ុន៦១១ខាងលើ មានបញ្ហាគួរឱ្យកត់សម្គាល់ដូចជា៖ការមិនប្រកាសចំណូល និងប្រកាសគ្មានបុគ្គលិក ខណៈដែលសហគ្រាសកំពុងមានសកម្មភាពអាជីវកម្ម ការលក់ទំនិញដែលបាននាំចូលដោយមិនប្រកាស និងបង់ពន្ធ ការបន្ទាបបៀវត្សបុគ្គលិកជំនាញ ការមិនប្រកាសពន្ធកាត់ទុកលើការជួលការិយាល័យ ខណៈដែលសហគ្រាសមិនមានអគារការិយាល័យដែលជាទ្រព្យសកម្មរបស់ខ្លួន ការមិនបង្ហាញមូលដ្ឋានគិតអាករពិសេស និងអាករបំភ្លឺសាធារណៈ។

ជាវិធានការ អគ្គនាយកដ្ឋានពន្ធដារនឹងបន្តអប់រំ ផ្សព្វផ្សាយ និងណែនាំដល់អ្នកជាប់ពន្ធពីកាតព្វកិច្ចដាក់លិខិតប្រកាសពន្ធ និងបន្តជំរុញបន្ថែមទៀតដល់មន្ត្រីទទួលបន្ទុកពិនិត្យការដាក់លិខិតប្រកាសរបស់អ្នកជាប់ពន្ធឱ្យបានត្រឹមត្រូវ។

**៤.១១.ការប្រមូលពន្ធអចលនទ្រព្យ**

គោលការណ៍នៃការប្រមូលពន្ធលើអចលនទ្រព្យបានតម្រូវឱ្យម្ចាស់អចលនទ្រព្យបំពេញព័ត៌មានអចលនទ្រព្យ ចុះបញ្ជី ដាក់លិខិតប្រកាស និងបង់ពន្ធ។ តាមការធ្វើតេស្តនៅសាខាពន្ធដារ

ខណ្ឌនៃរាជធានីភ្នំពេញ និងសាខាពន្ធដារខេត្តចំនួន១៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អចលនទ្រព្យមួយចំនួននៅមិនទាន់បានបង់ពន្ធអចលនទ្រព្យសម្រាប់ឆ្នាំ២០២០។ លទ្ធផលនៃការប្រមូលពន្ធអចលនទ្រព្យបានដោយសារអគ្គនាយកដ្ឋានពន្ធដារខិតខំប្រឹងប្រែងប្រមូលទិន្នន័យដោយខ្លួនឯងតាមរយៈការចុះធ្វើបច្ចុប្បន្នភាពអចលនទ្រព្យ ដែលកិច្ចការងារនេះប្រឈមនូវបញ្ហាជាច្រើន។ ដូចនេះ អគ្គនាយកដ្ឋានពន្ធដារស្នើសុំឱ្យអាជ្ញាធរសវនកម្មជាតិ ជួយជំរុញមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី សហការផ្តល់ព័ត៌មានឱ្យបានពេញលេញ ទាន់ពេលវេលា មកអគ្គនាយកដ្ឋានពន្ធដារ។ អគ្គនាយកដ្ឋានពន្ធដារ នឹងបន្តជំរុញនាយកដ្ឋាន និងសាខាពន្ធដារខេត្ត-ខណ្ឌពាក់ព័ន្ធត្រូវបន្តយកចិត្តទុកដាក់ប្រមូលពន្ធលើអចលនទ្រព្យឱ្យបានអស់លទ្ធភាព។

**៤.១២.ការទូទាត់ប្រាក់កក់ដែលបាននាំចូលដោយជំពាក់បែបបទយឺតយ៉ាវ**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសស្តីពីនិមុត្តិធានា ដោយបានបញ្ជាក់ថា រដ្ឋបាលគយអាចតម្រូវឱ្យតម្កល់នូវនិមុត្តិធានា ដើម្បីធានានូវការបង់ពន្ធនិងអាករ ឬដើម្បីធានាថា ប្រតិវេទន៍ករ និងភាគីទទួលខុសត្រូវផ្សេងៗទៀតបំពេញនូវកាតព្វកិច្ចតាមនីតិវិធីគយ ឬការអនុវត្តច្បាប់ផ្សេងៗទៀត និងត្រង់ប្រការ៩ រដ្ឋបាលគយត្រូវដោះបន្ទុកនិមុត្តិធានាឱ្យបានឆាប់តាមដែលអាចធ្វើទៅបានក្រោយពេលដែលមន្ត្រីគយមានសមត្ថកិច្ចពិនិត្យឃើញថា កាតព្វកិច្ចនានានៃនិមុត្តិធានាត្រូវបានបំពេញរួចរាល់ រាប់បញ្ចូលទាំងការបង់ពន្ធ និងអាករ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ សាខាគយ និងរដ្ឋាករខេត្តរតនគិរី មានសមតុល្យគណនីប្រាក់កក់សល់ចុងឆ្នាំ ចំនួន៣១៤ ៨២៥ ០៣៥ រៀល និងប្រាក់កក់ជាដុល្លារអាមេរិកចំនួន១២០ ០០០ដុល្លារ ដែលជាប្រាក់កក់ជំពាក់បែបបទនាំចូលចាប់តាំងពីឆ្នាំ២០១២ រហូតមកដល់បច្ចុប្បន្ន នៅតែមិនទាន់បានសងបែបបទ និងមិនទាន់មានដំណោះស្រាយ និងវិធានការនៅឡើយទេ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមឯកភាព និងសូមបំភ្លឺបន្ថែមថា អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានធ្វើលិខិតអញ្ជើញក្រុមហ៊ុនតាមរយៈលិខិតលេខ ០៣៤១/២០ អគរ/ស.រត/ក.អដ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ ហើយក្រុមហ៊ុនបានចូលខ្លួនមកអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដើម្បីដោះស្រាយ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ ហើយក្រុមហ៊ុនបានសន្យាមកបញ្ចប់ការងារនេះក្នុងឆ្នាំ២០២១។ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបាន និងកំពុងចាត់វិធានការបន្តចំពោះករណីនេះ។

**៤.១៣.ការយឺតយ៉ាវក្នុងការដោះស្រាយកំណត់ហេតុល្មើសច្បាប់គយ**

នាយកដ្ឋានកិច្ចការច្បាប់ និងទំនាក់ទំនងសាធារណៈបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាលើការងារដូចជា៖ ពិនិត្យកំណត់ហេតុល្មើសគយ លើកសំណើសម្រុះសម្រួល និងសម្រេចវិនិច្ឆ័យ លើបទល្មើសគយ និងវិវាទផ្សេងទៀតជូនអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាពិនិត្យ និងសម្រេច។ ប្រកាសលេខ ៦១៨ សហវ.ប្រក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ ២០០៩ ស្តីពីការសម្រុះសម្រួលបទល្មើសគយ ត្រង់ប្រការ៤ បានបញ្ជាក់ថា ប្រសិនបើក្នុងរយៈ

ពេលកៅសិប(៩០)ថ្ងៃ គិតពីកាលបរិច្ឆេទក្នុងកំណត់ហេតុបទល្មើសគយ ឬកំណត់ហេតុគយផ្សេងទៀត សេចក្តីសម្រេចជាផ្លូវការស្តីពីការសម្រុះសម្រួលនូវបទល្មើសគយមិនអាចទៅបាន រដ្ឋបាលគយត្រូវបញ្ជូនសំណុំរឿងទៅតុលាការមានសមត្ថកិច្ច។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ នាយកដ្ឋានកិច្ចការច្បាប់ និងទំនាក់ទំនងសាធារណៈ មានកំណត់ហេតុល្មើសច្បាប់គយចំនួន៧១៦ករណី ក្នុងនោះកំណត់ហេតុល្មើសច្បាប់ចំនួន៤៧៣ករណី ត្រូវបានធ្វើសេចក្តីសម្រេចវិនិច្ឆ័យរួច (បូកកំណត់ហេតុល្មើសសល់ឆ្នាំ២០១៩) ប៉ុន្តែនៅសល់កំណត់ហេតុល្មើសចំនួន៣៨២ករណីទៀត នៅពុំទាន់បានធ្វើការដោះស្រាយ និងមានវិធានការសមស្របនៅឡើយ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមឯកភាព និងសូមបំភ្លឺបន្ថែមថា ជាការពិត រៀងរាល់ដំណាច់ឆ្នាំនីមួយៗ កំណត់ហេតុល្មើសច្បាប់គយរមែងមាននៅសល់ជាកត្តាសត្យានុម័ត ដែលអគ្គនាយកដ្ឋានគយ និងរដ្ឋាករ ពុំទាន់អាចដោះស្រាយសម្រេចវិនិច្ឆ័យបានចប់សព្វគ្រប់តាមការចង់បាននិងការផ្តល់អនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ ដូចជាករណីពាក់ព័ន្ធនឹងស្ថាប័នផ្សេងជាក់ស្តែងបទល្មើសគ្រឿងញៀន។ល។ ដែលត្រូវការពេលវេលាបន្ថែមដើម្បីតាមដានស្រាវជ្រាវ និងចាត់ការបន្តតាមនីតិវិធីទៅតុលាការជាដើម។ ក្រៅពីយន្តការនិងវិធានការដោះស្រាយដែលមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិគយ អគ្គនាយកដ្ឋានគយ និងរដ្ឋាករបានចាត់វិធានការណ៍ចំពោះមុខដូចខាងក្រោម៖

- ផ្តល់សិទ្ធិសម្រុះសម្រួលបទល្មើសគយបន្ថែមទៀតជូនអង្គភាពគយនិងរដ្ឋាករសម្រាប់ទំនិញគ្រប់ប្រភេទដែលមានតម្លៃមិនលើសពី ៣ ០០០ ដុល្លាអាម៉េរិក
- បានបង្កើតគណៈកម្មការចំពោះកិច្ច ដើម្បីដោះស្រាយទំនិញល្មើសនឹងច្បាប់ស្តីពីគយដែលមានយន្តការនិងនីតិវិធីដោះស្រាយដូចមានចែងក្នុងប្រការ២ នៃសេចក្តីសម្រេចលេខ ១៤៩១/២០ អគរ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០
- ជំរុញអង្គភាពក្រោមឱវាទ ឱ្យបន្តរៀបចំសំណុំរឿងទៅតុលាការចំពោះកំណត់ហេតុបទល្មើសគយណាដែលហួសរយៈពេលសម្រុះសម្រួល។

ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ បាននឹងកំពុងពិនិត្យលទ្ធភាពនៃការធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិគយមួយចំនួន ដើម្បីឱ្យទាន់ការវិវឌ្ឍនៃតម្រូវការនៃការអនុវត្តច្បាប់ក្នុងអង្គភាពគយ។

### ៤.១៤.ការទូទាត់ និងការកត់ត្រាចំណាយ

ជាគោលការណ៍ ការបញ្ជូនអាណត្តិបើកប្រាក់ទៅរតនាគារថ្នាក់កណ្តាល និងរតនាគាររាជធានីខេត្តត្រូវបញ្ឈប់ការទទួលអាណត្តិបើកប្រាក់ឆ្នាំ២០២០ ត្រឹមវេលាម៉ោង១៧ និង៣០នាទីនាថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អាណត្តិបើកប្រាក់មួយចំនួន (សម្រាប់រដ្ឋបាលកណ្តាល) ត្រូវបានបញ្ជូនមកអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីធ្វើការទូទាត់នៅ

ក្រោយថ្ងៃកំណត់បិទបញ្ជី (អំឡុងពេលពីខែកុម្ភៈ ដល់ខែមីនា ឆ្នាំ២០២១) ហើយបានកត់ត្រាជាចំណាយថវិកាប្រចាំឆ្នាំ២០២០។

នៅរៀងរាល់ដំណាច់ឆ្នាំនីមួយៗ គឺមានការបញ្ជូនអាណត្តិបើកប្រាក់ក្នុងចំនួនច្រើន មកអគ្គនាយកដ្ឋានរតនាគារជាតិ ដោយមានភាពយឺតយ៉ាវ និងមិនទាន់ពេលវេលានៃកាលបរិច្ឆេទកំណត់តាមសារាចរណែនាំបិទបញ្ជីប្រចាំឆ្នាំ ជាពិសេសក្នុងឆ្នាំថវិកា២០២០។ ដោយឡែក បើពិនិត្យប្រភេទអាណត្តិទាំងនោះ គឺមានអាណត្តិនិយ័តកម្មមួយចំនួន (អាណត្តិទូទាត់ប្រាក់បុរេប្រទាននិងរជ្ជទេយ្យបុរេប្រទាន) ដែលចាំបាច់ត្រូវទូទាត់ជម្រះបញ្ជីក្នុងឆ្នាំថវិកា២០២០ ដើម្បីបិទបញ្ជីចំណាយថវិកា។ ការទូទាត់ចំណាយខាងលើ គឺបានសម្រួលដល់ការទូទាត់ចំណាយចាំបាច់ និងបញ្ចៀសការបង្ករបន្ទុកចំណាយទៅឆ្នាំថវិកា២០២១ និងឆ្នាំបន្តបន្ទាប់។ ម្យ៉ាងទៀត រយៈពេលនេះ គឺស្ថិតក្នុងរយៈពេលបំពេញបន្ថែមសម្រាប់ប្រតិបត្តិការនិយ័តកម្មនៃរតនាគារ។ បន្ថែមពីលើនេះ អាស្រ័យដោយឆ្នាំ២០២០មានការឆ្លងរាតត្បាតនៃជំងឺកូវីដ-១៩ ដែលតម្រូវឱ្យអនុវត្តនូវរាល់វិធានការ បង្ការការពារ និងទប់ស្កាត់ការឆ្លងរីករាលជំងឺកូវីដ-១៩ ទើបបណ្តាល ឱ្យការអនុវត្តចំណាយថវិការបស់ក្រសួង ស្ថាប័នមួយចំនួនមានការយឺតយ៉ាវ។

អនុវត្តតាមសារាចរណែនាំលេខ០០៨ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ ស្តីពីការបិទបញ្ជីចំណូល-ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល-ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២០ អគ្គនាយកដ្ឋានថវិកាបានជំរុញក្រសួង-ស្ថាប័នឱ្យរៀបចំទូទាត់ប្រតិបត្តិការចំណាយឱ្យបានទាន់ពេលវេលា។ ជាមួយគ្នានេះ ភាពយឺតយ៉ាវនៃការទូទាត់នៅតែកើតឡើង ជាពិសេសស្ថិតក្នុងបរិការណ៍ នៃការរីករាលដាលជំងឺកូវីដ-១៩ យ៉ាងគំហុកបានបង្កផលប៉ះពាល់ដល់ការយឺតយ៉ាវក្នុងទូទាត់កាន់តែខ្លាំង ដោយតម្រូវឱ្យមន្ត្រីមកបំពេញការងារផ្លាស់វេនគ្នា ទាំងអគ្គនាយកដ្ឋានថវិកា និងក្រសួងស្ថាប័ន។

ដើម្បីសម្រួលការទូទាត់បន្ថែមជូនក្រសួង-ស្ថាប័ន អគ្គនាយកដ្ឋានរតនាគារជាតិបានស្នើសុំគោលការណ៍ពីឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី ដើម្បីពន្យារកាលបរិច្ឆេទទទួលអាណត្តិបើកប្រាក់រហូតដល់ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១ (លិខិតលេខ ២៥៣ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១)។ តាមរយៈការពន្យារពេលនេះ អាណត្តិទូទាត់ត្រូវ បានអនុញ្ញាតជាបន្តបន្ទាប់ក្នុងខែកុម្ភៈ ក្នុងនោះក៏មានអាណត្តិមួយចំនួនតូចត្រូវបានអនុញ្ញាតឱ្យបើកផ្តល់សាច់ប្រាក់ក្នុងខែមីនា ដោយសារការប្រគល់-ទទួលមានការយឺតយ៉ាវ (បោះអាណត្តិតម្កល់)។ ទោះបីទទួលបានការពន្យារពេលបន្ថែមក្តី ក៏ការទូទាត់ចំណាយនៅតែមានភាពយឺតយ៉ាវដដែល។

អគ្គនាយកដ្ឋានថវិកា នឹងបន្តវិធានការជំរុញដល់ក្រសួងស្ថាប័ន ឱ្យពន្លឿនការអនុវត្តសកម្មភាពរបស់ខ្លួន ជាពិសេស ការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ ឱ្យបានទាន់ពេលវលា ដូចមានចែងនៅក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំ និងរូតរះក្នុងការប្រមូលសក្ខីបត្រចំណាយផ្សេងៗដើម្បីធ្វើការទូទាត់ឱ្យបានទាន់ពេល។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងបន្តជំរុញក្រសួង ស្ថាប័នឱ្យរួសរាន់រៀបចំលិខិតយុត្តិការ ចំណាយ និងបោះផ្សាយអាណត្តិបើកប្រាក់ រួចបញ្ជូនទៅអភិបាលហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីអាចធ្វើការទូទាត់បានទាន់ពេលវេលា ជាពិសេសការទូទាត់ជម្រះបញ្ជីបុរេប្រទាន និងរជ្ជទេយ្យបុរេប្រទានឱ្យទាន់ក្នុងឆ្នាំថវិកា ជៀសវាងការបង្គរបំណុលទៅឆ្នាំថវិកាបន្ទាប់។ ទន្ទឹមនឹងនេះ ក្រសួងក៏បន្តជំរុញ និងពង្រឹងការអនុវត្តការងារតាមប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដែលនឹងចូលរួមជំរុញការអនុវត្តចំណាយថវិកា តាមគោលការណ៍នៃកាលបរិច្ឆេទកំណត់។

### ៤.១៥.ការត្រួតពិនិត្យភាពត្រឹមត្រូវនៃអាណត្តិបើកប្រាក់

ដើម្បីធានាបាននូវការទទួលខុសត្រូវក្នុងការអនុវត្តចំណាយថវិការដ្ឋ អគ្គនាយកដ្ឋានរតនាគារជាតិដែលជាគណនេយ្យករសាធារណៈមានតួនាទីយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យភាពត្រឹមត្រូវនៃការអនុវត្តចំណាយថវិការដ្ឋ។ ការអនុវត្តតួនាទីនេះបានគត់មុត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញសារាចរណែនាំលេខ០០៦ សហវ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ស្តីពីលិខិតយុត្តិការភ្ជាប់អាណត្តិបើកប្រាក់សម្រាប់ការទូទាត់ចំណាយថវិកាដែលអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈ តម្រូវឱ្យក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវភ្ជាប់លិខិតយុត្តិការជាមួយនឹងអាណត្តិបើកប្រាក់សម្រាប់ទូទាត់ចំណាយ ដែលអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈ ដូចជា៖ កិច្ចសន្យាលទ្ធកម្ម ដែលមានពន្ធប្រថាប់ត្រា និងបណ្ណប៉ាតង់ដែលប្រភេទអាជីវកម្មត្រូវស្របតាមការផ្គត់ផ្គង់ជាដើម។ល។

តាមការធ្វើតេស្តលើអាណត្តិបើកប្រាក់ឆ្នាំ២០២០ ចំនួន៤៩៨ របស់ក្រសួង ស្ថាប័នមួយចំនួន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អាណត្តិបើកប្រាក់ចំនួន២៤ មិនបានភ្ជាប់នូវឯកសារគាំទ្រត្រឹមត្រូវដូចជា៖ ប្រភេទអាជីវកម្មរបស់អ្នកផ្គត់ផ្គង់មិនសមស្របតាមកម្មវត្ថុនៃការចំណាយ (ប្រភេទអាជីវកម្មមិនត្រូវតាមការផ្គត់ផ្គង់) និងប្រថាប់ត្រាក្រោយកាលបរិច្ឆេទ។

អាស្រ័យដោយ នៅកៀកដំណាច់ឆ្នាំថវិកា២០២០ មានការបញ្ជូនអាណត្តិបើកប្រាក់គំហុកច្រើនមកអគ្គនាយកដ្ឋានរតនាគារជាតិ ហើយក្នុងនោះអាណត្តិបើកប្រាក់ទូទាត់ចំណាយលទ្ធកម្មមួយចំនួន មានបញ្ហាខ្វះចន្លោះមិនត្រឹមត្រូវតាមនីតិវិធីនៃការទូទាត់។ ផ្អែកតាមសារាចរណែនាំលេខ ០០៦ សហវ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ស្តីពីលិខិតយុត្តិការភ្ជាប់អាណត្តិបើកប្រាក់សម្រាប់ការទូទាត់ថវិកាដែលអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈ អគ្គនាយកដ្ឋានរតនាគារជាតិបានបន្តការយកចិត្តទុកដាក់ពង្រឹងការត្រួតពិនិត្យអាណត្តិបើកប្រាក់ទូទាត់ចំណាយលទ្ធកម្ម ដើម្បីមានមូលដ្ឋានក្នុងការទូទាត់ចំណាយថវិកា ដោយផ្អែកលើកំណត់ហេតុប្រគល់ ទទួល ឬកំណត់ហេតុវាយតម្លៃលទ្ធផលការងាររបស់គណៈកម្មការលទ្ធកម្ម ដែលបញ្ជាក់អំពីភាពត្រឹមត្រូវ និងច្បាស់លាស់លើទំនិញ ឬសេវាដែលបានបំពេញរួច។ ប៉ុន្តែអាស្រ័យដោយសារកត្តាពេលវេលា និងការមិនបានត្រៀមលក្ខណៈគ្រប់គ្រាន់ពីដើមទី បញ្ហាខ្វះចន្លោះមួយចំនួន ដែលតម្រូវឱ្យមានកិច្ចសហការចូលរួមពង្រឹងបន្ថែមពីសាមីក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធចាប់ពីដើមទីនៅដំណាក់កាលអនុ

វត្តកិច្ចលទ្ធកម្ម និងដំណាក់កាលរៀបចំលិខិតយុត្តិការចំណាយបោះផ្សាយអាណត្តិបើកប្រាក់។ ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋានរតនាគារជាតិបានបន្តណែនាំដល់ក្រសួង ស្ថាប័ន ក៏ដូចជាអ្នកផ្គត់ផ្គង់ ឱ្យបំពេញបន្ថែមនូវសក្ខីប័ត្រចំណាយឱ្យបានត្រឹមត្រូវ និងគ្រប់គ្រាន់ ដូចជា ការបង់ពន្ធប៉ាតង់បន្ថែម ឱ្យស្របតាមប្រភេទអាជីវកម្ម និងការបង់ពន្ធប្រថាប់ត្រាលើកិច្ចសន្យាជាដើម។ ករណីនេះ ក៏បានរួមចំណែកក្នុងការប្រមូលពន្ធបង់ចូលថវិការដ្ឋផងដែរ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងបន្តពង្រឹងការត្រួតពិនិត្យលិខិតយុត្តិការចំណាយ និងទូទាត់ចំណាយថវិកា ឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា ជាពិសេសបន្តកិច្ចសហការពីអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ អគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងសាមីក្រសួង ស្ថាប័ន ដែលជាអង្គភាពពាក់ព័ន្ធពីដើមទី ឱ្យចូលរួមក្នុងការពង្រឹង និងដោះស្រាយបញ្ហាប្រឈមទាំងនេះនៅដំណាក់កាលអនុវត្ត កិច្ចលទ្ធកម្មសាធារណៈ និងដំណាក់កាលរៀបចំលិខិតយុត្តិការចំណាយបោះផ្សាយអាណត្តិបើកប្រាក់។

ស្ថិតក្នុងបរិការណ៍នៃការរីករាលដាលនៃជំងឺកូវីដ-១៩ ការផ្គត់ផ្គង់សម្ភារមួយចំនួនធ្វើឡើងជាការប្រញាប់ ក្រសួង ស្ថាប័នសាធារណៈនីមួយៗមានចំនួនមន្ត្រីតិចតួចមកបំពេញការងារតាមសារាចរណែនាំរបស់រាជរដ្ឋាភិបាលស្តីពីការកំណត់ចំនួនមន្ត្រីដែលចាំបាច់មកបំពេញការងារប្រចាំថ្ងៃប្រមាណ ២%។ ហេតុនេះ ធ្វើឱ្យការប្រថាប់ត្រាកិច្ចសន្យា និងភ្ជាប់ឯកសារផ្សេងៗមិនបានទាន់ពេល។

អគ្គនាយកដ្ឋានថវិកា នឹងកំណត់វិធានការជំរុញបន្ថែមសម្រាប់ឯកសារភ្ជាប់រួមមាន៖ កម្មវត្ថុអាជីវកម្មក្នុងប័ណ្ណប៉ាតង់ និងការផ្គត់ផ្គង់ជាក់ស្តែងឱ្យមានសង្គតិភាពនឹងគ្នា ក៏ដូចជាការប្រថាប់ត្រាលើកិច្ចសន្យាឱ្យបានត្រឹមត្រូវតាមពេលវេលា។

**៤.១៦.ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ**

រដ្ឋាភិបាលបានចេញសារាចរណែនាំស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋដោយបានបញ្ជាក់ថា អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវទទួលខុសត្រូវចំពោះមុខរាជរដ្ឋាភិបាល ក្នុងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋជារៀងរាល់ឆ្នាំឱ្យបានត្រឹមត្រូវគ្រប់ចំនួន និងចប់សព្វគ្រប់នៅក្នុងត្រីមាសទី១នៃឆ្នាំបន្ទាប់។ ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋត្រូវអនុវត្តតាមទម្រង់ដូចជាតារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋដែលត្រូវធ្វើឡើងក្នុងឆ្នាំនីមួយៗ ក្នុងចន្លោះរយៈពេល០៥(ប្រាំ)ឆ្នាំនៃឆ្នាំគោល។ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវធ្វើតារាងប្រៀបធៀបនៃការកើនឡើង ឬថយចុះទ្រព្យសម្បត្តិរដ្ឋក្នុងឆ្នាំនីមួយៗដោយអនុលោមតាមបែបបទ នីតិវិធី និងទម្រង់គំរូរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំដែលរៀបចំរួច ត្រូវផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន០២ (ពីរ) ច្បាប់ យ៉ាងយូរនៅដំណាច់ត្រីមាសទី១នៃឆ្នាំបន្ទាប់ ដើម្បីតម្កល់ទុក និងធ្វើការពិនិត្យតាមដាន ព្រមទាំងរាយការណ៍ជារៀងរាល់ឆ្នាំនូវលទ្ធផលស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ជូនប្រមុខរាជរដ្ឋាភិបាលតាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួង ស្ថាប័នថ្នាក់កណ្ដាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ បានផ្ញើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងមិនបានផ្ញើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋសម្រាប់ឆ្នាំ២០២០ រួមមាន៖

| ល.រ | អង្គភាព | បញ្ជីសារពើភណ្ឌឆ្នាំ២០២០ | | |
|---|---|---|---|---|
| | | បានផ្ញើ | មិនបានផ្ញើ | សរុប |
| ១ | ក្រសួង-ស្ថាប័ន (ថ្នាក់កណ្ដាល) | ៥៧ | ៣១៧ | ៣៧៤ |
| ២ | រាជធានី ខេត្ត ក្រុង ស្រុក | ៩៣ | ១៣៥ | ២២៨ |
| ៣ | មន្ទីរជំនាញ(ថ្នាក់មូលដ្ឋាន) | ៥៤៦ | ២៣៦ | ៧៨២ |
| ៤ | រដ្ឋបាលឃុំ សង្កាត់ | ៧៧៥ | ៨៧១ | ១ ៦៤៦ |

## ៤.១៧.ការធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ

រាជរដ្ឋាភិបាល បានចេញសារាចរណែនាំស្ដីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដោយបញ្ជាក់ថា អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវរៀបចំធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលើទ្រព្យសម្បត្តិរដ្ឋជាអចលនវត្ថុទាំងអស់ស្ថិតនៅក្រោមការកាន់កាប់ និងប្រើប្រាស់របស់ខ្លួនឱ្យបានឆាប់រហ័ស និងតាមពេលវេលាកំណត់ដោយសហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គ្រប់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋទាំងអស់ ត្រូវបញ្ចូលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលរៀបចំរួចទៅក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដើម្បីធានាបាននូវភាពគង់វង្ស និងភាពស្របច្បាប់នៃទ្រព្យសម្បត្តិទាំងឡាយនោះ។

អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា ក្រសួង ស្ថាប័នថ្នាក់កណ្ដាល ដែលមានអង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋចំនួន៣៣៨ អង្គភាព មានទីតាំងអចលនទ្រព្យចំនួន១ ២១២កន្លែង ក្នុងនោះអចលនទ្រព្យដែលមានបណ្ណកម្មសិទ្ធិត្រឹមត្រូវមានចំនួន៦២០កន្លែង ប៉ុន្តែទីតាំងអចលនទ្រព្យចំនួន៥៩២ កន្លែងទៀត នៅមិនទាន់បានធ្វើបណ្ណកម្មសិទ្ធនៅឡើយទេ។ មន្ទីរ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងអង្គភាពជុំវិញខេត្ត ដែលមានអង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋចំនួន២ ៦៤២អង្គភាព មានទីតាំងអចលនទ្រព្យចំនួន២៧ ៣៤៨កន្លែង ក្នុងនោះទីតាំងអចលនទ្រព្យដែលមានបណ្ណកម្មសិទ្ធិត្រឹមត្រូវមានចំនួន១៧ ១៤៤កន្លែង ចំណែកឯទីតាំងអចលនទ្រព្យចំនួន១០ ២០៤កន្លែងផ្សេងទៀត នៅមិនទាន់បានធ្វើបណ្ណកម្មសិទ្ធិនៅឡើយទេ។

## ៥. សេចក្តីសន្និដ្ឋាន

លទ្ធផលនៃការអនុវត្តច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ បានបង្ហាញឱ្យឃើញនូវការខិតខំប្រឹងប្រែងពុះពាររបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រត្រឹមត្រូវស្របតាមសភាពការណ៍ជាក់ស្តែង ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពរីកចម្រើន និងគត់មត់ពីមួយឆ្នាំទៅមួយឆ្នាំ ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត។ ក្នុងបរិការណ៍ដែលសេដ្ឋកិច្ចសកល និងស្ថានភាពម៉ាក្រូសេដ្ឋកិច្ច កំពុងវិវត្តឆាប់រហ័ស និងចល័តយ៉ាងលឿនពិបាកប៉ាន់ប្រមាណឱ្យបានច្បាស់លាស់ ដោយសារផលប៉ះពាល់ធ្ងន់ធ្ងរនៃការរីករាលដាលនៃជំងឺកូវីដ-១៩។ រាជរដ្ឋាភិបាលបានធ្វើការវាយតម្លៃឡើងវិញលើផលប៉ះពាល់នៃការរីករាលដាលនៃជំងឺកូវីដ-១៩ មកលើក្របខណ្ឌច្បាប់ថវិកាជាតិឆ្នាំ២០២០ និងបានសម្រេចបង្វែរទិសនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈពី "**ថវិកាវិក្ការកម្ម**" ដើម្បីលើកកម្ពស់កំណើនទៅជា "ថវិការឹតបន្តឹងសំដៅបង្កើនប្រសិទ្ធភាពចំណាយ" ដើម្បីឆ្ពោះទៅដោះស្រាយការងារអាទិភាពចំពោះមុខតាមរយៈការធ្វើវិចារណកម្មក្នុងគោលបំណងបម្រើឱ្យការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ រក្សាលំនឹងសេដ្ឋកិច្ច និងទ្រទ្រង់ការងារកែទម្រង់របស់រាជរដ្ឋាភិបាល ក៏ដូចជាបម្រើឱ្យការត្រៀមខ្លួន និងការពង្រឹងសមត្ថភាពផ្ទៃក្នុងឱ្យបានល្អសម្រាប់ត្រៀមទប់ទល់នឹងបញ្ហាប្រឈម និងហានិភ័យទាំងក្នុង និងក្រៅប្រទេស ពិសេសដើម្បីគោលដៅនៃការអនុវត្តឱ្យចេញជាលទ្ធផលជាក់ស្តែងប្រកបដោយប្រសិទ្ធភាព សំដៅឈានទៅសម្រេចបាននូវបំណងប្រាថ្នារយៈពេលវែងរបស់ប្រជាជនកម្ពុជា ក្នុងការក្តាប់យកមកវិញនូវមោទនភាពជាតិ និងការកសាងជាតិមួយដ៏រស់រវើក មានអនាគតដ៏រុងរឿងភ្លឺស្វាងត្រចះត្រចង់ និងជារដ្ឋអធិបតេយ្យមួយរឹងមាំ ដែលគោរពខ្ជាប់ខ្ជួនតាមគោលការណ៍ប្រជាធិបតេយ្យ និងនីតិរដ្ឋ និងមានសន្តិភាពពេញលេញ ព្រមទាំងមានកិត្យានុភាពខ្ពស់ត្រដែតលើឆាកអន្តរជាតិ។ ទោះបីជារាជរដ្ឋាភិបាលបានជួបនូវការលំបាកខាងលើដែលពុំធ្លាប់ជួបប្រទះពីមុនៗមកក៏ដោយ ក៏រាជរដ្ឋាភិបាលនៅតែអាចគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានល្អ ដើម្បីបន្តកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំ ក្នុងគោលដៅពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកម្ពុជា។

តាមរយៈការផ្តល់អនុសាសន៍កែលម្អនូវចំណុចខ្វះខាតនានា និងការចេញផ្សាយរបាយការណ៍សវនកម្មជាសាធារណៈជាបន្តបន្ទាប់មកនេះ អាជ្ញាធរសវនកម្មជាតិកត់សម្គាល់ឃើញថា អង្គភាពរងសវនកម្មនានាបានយកចិត្តទុកដាក់ខិតខំអនុវត្តកែលម្អនូវអនុសាសន៍សវនកម្មបានប្រសើរ។ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា អង្គភាពរងសវនកម្មទាំងឡាយនឹងបន្តខិតខំអនុវត្តកែលម្អនូវរាល់កង្វះខាតនានាឱ្យបានល្អប្រសើរ និងទាន់ពេលវេលា ហើយជៀសវាងបាននូវការបន្តកើតមានកង្វះខាតដដែលៗជាបន្តទៅទៀត ដើម្បីចូលរួមចំណែកយ៉ាងសកម្មក្នុងការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យបានកាន់តែរឹងមាំ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

ក្នុងបរិបទនេះដែរ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានធ្វើរបាយការណ៍គោរពជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា លើលទ្ធផលការងារអធិការកិច្ចហិរញ្ញវត្ថុ ដែលបានរកឃើញនូវកំហុសឆ្គងរបស់ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ និងមន្ទីរជំនាញ និងបានធ្វើលិខិតចាត់វិធានការវិន័យរដ្ឋបាល ដើម្បីកែលម្អកំហុសឆ្គងលើការអនុវត្តនីតិវិធីហិរញ្ញវត្ថុដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរកឃើញក្នុងការគ្រប់គ្រង ការប្រើប្រាស់ចំណូល ចំណាយ

ថវិការដ្ឋ ចំណូលមិនមែនសារពើពន្ធ កាតព្វកិច្ចបង់ចំណូលចូលថវិការដ្ឋ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ និងមន្ទីរជំនាញ ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពតាមនីតិវិធីហិរញ្ញវត្ថុ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ហើយបានចម្លងជូនក្រសួង ស្ថាប័នពាក់ព័ន្ធ ដូចជា ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច អង្គភាពប្រឆាំងអំពើពុករលួយ និងអាជ្ញាធរសវនកម្មជាតិ ដើម្បីចាត់ការបន្ត។

ទន្ទឹមនឹងនេះដែរ អាជ្ញាធរសវនកម្មជាតិមានជំនឿយ៉ាងមុតមាំថា ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធនានា និងសាធារណជនទាំងឡាយនឹងបន្តចូលរួមផ្តល់មតិស្ថាបនាលើរបាយការណ៍នេះ ព្រមទាំងផ្តល់ការលើកទឹកចិត្តចំពោះលទ្ធផលសម្រេចបាន ដែលជាកត្តាជំរុញឱ្យអាជ្ញាធរសវនកម្មជាតិបន្តខិតខំបង្កើនសមត្ថភាពការងាររបស់ខ្លួនប្រកបដោយសីលធម៌វិជ្ជាជីវៈ សំដៅលើកកម្ពស់គុណភាពសវនកម្មឱ្យស្របតាមស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងស្តង់ដារតំបន់ និងអន្តរជាតិ ដើម្បីចូលរួមចំណែកក្នុងការកសាង និងអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។